# កម្លាំង និង ការចេះដឹង ខ្មែរ



ឧប សៅ សង្ហា

## មាតិការឿង


សេចក្តីផ្តើម 1

ការចេះដឹងខ្មែរ 4

បញ្ញវន្តខ្មែរ 17

អក្សរសិល្ប៍ខ្មែរ 29

កម្លាំងខ្មែរ 42

លទ្ធិប្រជាធិបតេយ្យ 65

នៅមានបន្ត 79



## សេចក្តីផ្តើម

ស្រុកខ្មែរ ជា ប្រជាជាតិ មាន អាយុ ជា ច្រើនសហស្សវត្ស នៅក្នុង ដំបន់ អាស៊ី អគ្នេយ៍ បណ្តាប្រជាជាតិ ដទៃទៀត គឺ មន និង ចំប៉ា។ ប្រជាជន ខ្មែរ ក្នុង បុព្វប្រវត្តិសាស្ត្រ មាន ការគោរពជំនឿ[1] «មេ-ប៉ា» ឬ «ម៉ែ-ឪ» គឺជា ជំនឿ គោរព «បុព្វជន» ឬ «ចាស់បុរាណ» មុន ខ្លួន បានជួបប្រទះនឹង ជំនឿថ្មី គឺ ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា មហាយាន។

គួរលើកយក ការគោរពជំនឿ «មេ-ប៉ា» ដែល កវី កេង វ៉ាន់សាក់ បានធ្វើការត្រិះរិះមកពិចារណា ព្រោះថា ទស្សនៈ នេះ ខ្មែរភាគតិចបំផុត មិនបានដឹងឮ ហើយ អ្នកចេះខ្មែរ មិនបានយកវាមកសិក្សា ដូច ការសិក្សា អំពី ជំនឿ លើ «អ្នកតា»។ ក្នុង ចំណុចនេះ យើង យល់ឃើញ ថា មាន តែ កវី កេង-វ៉ាន់សាក់ ម្នាក់ បានសាកល្បង យក ការគោរពជំនឿ «មេ-ប៉ា» ជា គំនិតផ្តើម មក បង្កើត ជា សំណើ មួយ សំរាប់ ខ្មែរយើង យកវា ទៅពិចារណា បន្ថែមតាម ការយល់ឃើញ រៀងៗខ្លួន។ សំណើ នេះ មិនទុក ជា ស្វ័យស័ត្យ[2] នោះឡើយ ដែលនាំឲយើងយកវាមក បំបែង ជា បទតទ្ធិត[3] ដោយ ប្រើ ភាសាសម័យ និង គំនិត «ការគ្រប់គ្រង[4] » ដើម្បី ស្រួលងាយយល់ អំពី ដួង ទស្សនៈ នេះ។

### ការគោរពជំនឿ«មេ-ប៉ា»

**«មេ»** មានន័យ ច្រើន នៅក្នុង ការត្រិះរិះ ខ្មែរ៖ ជា ម្តាយ ជា ភាពឧត្តុងឧត្តម ជាគំនិតជាប្រភព។

**«ប៉ា»** មានន័យ ជា ឪពុក ជា អ្នកការពារ ជា មាគ៌ា ជា គំនិតបណ្ឌិត។ នៅក្នុង ពាក្យប៉ា នោះដែរ មាន ទស្សនៈ បី យ៉ាង៖ **ព្រះ ចៅ និង តា**។ នៅក្នុង វប្បធម៌ ខ្មែរបុរាណ ពាក្យ «ព្រះ» មានន័យ ជា «មាគ៌ា ឬ គោលដៅ», ពាក្យ «ចៅ» មាន ន័យ ជា «អ្នកការពារ» រីឯពាក្យ «តា» មានន័យ ជា «បុព្វបុរស ឬ គំនិតបណ្ឌិត»។

1 ការគោរពជំនឿ= Culte។
2 ស្វ័យស័ត្រ= ដំណើទុកជាការពិតជាក់ស្តែង ; Axiome។
3 បទតទ្ធិត= ដែលក្លាយមកពី វចនៈ វត្ថុ ឬ គំនិត ; Dérivé។
4 ការគ្រប់គ្រង= Management។

នៅក្នុង ការគោរពជំនឿ «មេ-ប៉ា» យើង ឃើញ ថា សង្គម បុរាណ ខ្មែរ ជា សង្គម មាតេយ្យការ[5] ទុក ស្ត្រី ជា សព្វ ប្រភព នៃ ជីវិត រស់នៅ ក្នុង សង្គម ដូច្នេះ ជា ឧត្តមមនុស្សលោក ដែលត្រូវតែគោរព។ បើ ស្ត្រី ក្លាយ ជា មាតា គឺ ជា គំនិត ព្រោះ លោក ជា អ្នក បីបាច់ ថែទាំរក្សា ប្រកប ដោយសេចក្ដី ស្នេហា ចេញពី ដួងចិត្តា ដ៏ បរិសុទ្ធ ពី វ័យ ទារក ដល់ ពេញវ័យ ឲ ស្គាល់ បទដ្ឋាន[6] នូវ អ្វីដែល ជា អំពើ ល្អ អំពើ អាក្រក់ ក្នុង ការរស់នៅ ជា ប្រក្រតិ។ ការគោរព មាតា ជា សាលារៀន នៃសេចក្ដីត្រាប្រណី សេចក្ដីស្នេហា បរិសុទ្ធ ដែល ជា គំនិត[7] នៃ មនុស្សជាតិ។ មនុស្សលោក កើតមក នាំមក នូវ សេចក្ដីស្នេហា រវាង មាតា នឹង ខ្លួន ដែលមាននៅក្នុងច្បាប់ ធម្មជាតិ ដែលជា ច្បាប់ ទី១ នៃ មនុស្សជាតិ។

ដើម្បី រៀបចំ សង្គម ឲមាន សណ្ដាប់ធ្នាប់ ត្រូវការ ចាំបាច់ មាន អ្នកនាំផ្លូវ ប្រកបដោយ គតិតបណ្ឌិត មាន គ្រោងគំនិត ជា លំដាប់ ដែល ទុក ជា «មាគ៌ា» សំរាប់ ដើរ សំដៅ ទៅ រក ទិដៅ។ ការកសាង មាគ៌ា នេះ ជា កិច្ចការ របស់ «ប៉ា»។ ប៉ា មាន ធាតុ បី ដែល យើង បាន លើកមក បង្ហាញ រួចមកហើយ គឺៈ

ទី១. គឺ «ព្រះ»ៈ ជា គោលបំណង កសាង សង្គម ឲមាន សណ្ដាប់ធ្នាប់ ឲមាន វិន័យ, ជា ការដឹកនាំ ឲមាន សីលធម៌, ជា បទដ្ឋាន នៃ យុត្តិធម៌ មាន គោលដៅ ច្បាស់លាស់ ហើយ ត្រូវចាំបាច់ ធ្វើឲសម្រេចបាន ដើម្បី សេចក្ដីចំរើន នៃ មនុស្សជាតិ។

ទី២. គឺ «ថៅ»ៈ ជា អ្នកដឹកនាំ នៃ កម្មវិធី នូវគោលបំណង ដែល ជាបុគ្គល មាន គុណសម្បត្តិ ជាអ្នកប្រមែប្រមូល ជាទី ស្រឡាញ់ នូវ សមាជិក សង្គម ឲមក ជ្រក កាយា ក្រោម ឆាយា ឆ័ត្រ ប្រកប ដោយ សេចក្ដីស្នេហា សំរាប់ការពារ និង ឧបត្ថម្ភ រួមរស់ ក្នុង សេចក្ដីសុខ ដែលនាំឲមាន សិនិទ្ធពល[8] ក្នុងសង្គម ដើម្បី ជ្រោមជ្រែង កសាង សម្មាសង្គម[9] ។

ទី៣. គឺ «តា»ៈ សាស្រ្តា ឬ សតិ នៃ ការចេះដឹង របស់ បុព្វបុរស ដែល លោក ចងក្រងទុក ជាក្បួន ច្បាស់លាស់ សំរាប់ ការរស់នៅ របស់ សមាជិក នៃសង្គម ដើម្បី ឲមាន សុខដុម។ ក៏ជា ប្រជុំវិជ្ជា សំរាប់ រក សេចក្ដីពន្យល់ ដើម្បី ស្វែងរក ដំណោះស្រាយ ចំពោះមុខ វិបត្តិ ណាមួយ ដែលសង្គម ជួបប្រទះ។ ដូច្នេះ «តា» ជា ប្រភព នៃ ការចេះដឹង សកម្ម មាន

---

[5] មតេយ្យការ= Martricat។
[6] បទដ្ឋាន= Norme។
[7] គំនិត= Esprit។
[8] សិនិទ្ធពល= ការរួបរួម ; Cohésion។
[9] សម្មាសង្គម= Société juste។

លក្ខណៈ ជា ប្រភព ជាថាមវន្ត ព្រោះ អ្វី ដែល បាន ធ្វើ រួចហើយ អ្នកដឹកនាំ ពី ជំនាន់មួយ ទៅ ជំនាន់ តែងតែ ចារទុក ជា ក្បួនសាស្ត្រ ថ្មី សំរាប់ សមាជិក ជំនាន់ក្រោយ។

រួមសេចក្តីមក ការគោរពជំនឿ «មេ-ប៉ា» ជា ការត្រិះរិះ ជា ថាមវន្ត មាន កម្លាំង រុញ ទៅរក អ្វីដែល ជា សម័យ ដើម្បី យក របស់ ថ្មី ដែលបាន ជួបប្រទះ មកផ្សំ បង្កើតជា គំនិតថ្មីមួយទៀត សំរាប់ បន្តការរស់នៅ នៃ មនុស្សលោក ក្នុង សង្គមជាតិ។ ហេតុនេះឯងបាន ជា ខ្មែរយើង មាន លទ្ធភាព និង ទេពកោសល្យ អាច កែច្នៃ វប្បធម៌ ឥណ្ឌា តាមសន្តិវិធី បាន ជា វប្បធម៌ ថ្មីមួយ ដែល គេ ឲឈ្មោះ ថា អារ្យធម៌ អង្គរ។ តើ ទេពកោសល្យបែប នេះ មិនមែន ជា កម្លាំងខ្មែរ នោះឬទេ ?



## ការចេះដឹងខ្មែរ

# ការចេះដឹង បុរាណខ្មែរ ឬ មូលដ្ឋាន នៃបញ្ញាខ្មែរ

ខ្មែរយើង មាន ការភាន់ច្រឡំ គឺ យើង នាំគ្នា យក អារ្យធម៌ អង្គរ មកធ្វើ ជា គំនិតសឹក ពូកែ កាប់ចាក់ នៅក្នុង សមរភូមិ ថា ពូជខ្មែរ ជា ពូជ អ្នកចម្បាំង កសាង មហានគរ។ ទស្សនៈនេះ សង្កត់តែលើ អំណាចយោធា ហាក់បីខ្មែរយើងនាំគ្នា ទទួលស្គាល់ នូវ ច្បាប់ នៃ ធម្មជាតិ គឺ «ឯកសិទ្ធិ អ្នកខ្លាំង លើ អ្នកខ្សោយ»៖ អ្នកឈ្នះ ប្រើអំណាច ឲ អ្នកចាញ់ ស្តាប់បង្គាប់ ជាដាច់ខាត។

ទស្សនៈនេះ ដែលនាំ ឲខ្មែរយើងមិនសូវ យកចិត្តទុកដាក់ អំពី គ្រិះ ពិត របស់ ខ្លួន គឺ ការចេះដឹងខ្មែរ ក្នុងវិស័យ «ធនធានមនុស្សលោក» «ធនធានធម្មជាតិ» និង «ការគ្រប់គ្រោង នៃ គតិលោក» ដែលជា ការចេះដឹង ជា មូលដ្ឋាន នៃ ការរស់នៅ របស់ មនុស្សលោក។

«**គតិលោក**៖ និយមន័យ តាម ឧញ៉ា សុត្តន្តប្រីជាឥន្ទ[10] (១៨៥៦-១៩២៤) ៖ **លោក** ជាភារៈ ដែលកើតឡើងដោយ អំណាចប ដិសន្ធិ នៃខន្ធ គឺថា សភារៈមិនទៀង ដោយ មិនជាប់នៅ មិនប្រាកដ ជា អទស្សនភាព។ មួយទៀត ប្រែថា សត្វផែនដី ផ្ទៃមេឃអាកាសទួទៅទាំងអស់, លោក នេះ ប្រែថា ធម្មតា សត្វ ឬ របស់ ដែលប្រព្រឹត្តទៅក្នុងលោក។ ឯ **គតិ** ជាសព្ទ ប្រែបានច្រើនយ៉ាង គឺ ជា ដំណើរទៅ គ្រឿង ដល់ គ្រឿង ដំណើរ ជាបទសេចក្តីកម្លាំងអំណាចផ្លូវចិត្ត ទីពឹងក្តី អត់ធន់ចិត្ត។ កំណើតពាក្យឯណា ហេតុណា វត្ថុណា ដែលកើតឡើង មានឡើង ក្នុងលោកនេះ ហៅថា «គតិលោក» ទាំងអស់»

ការចេះដឹង បុរាណខ្មែរ ជា របៀបប្រើ បែប ទ្រឹស្តី និង បែប ប្រតិបត្តិ។ បុព្វបុរសខ្មែរ លោកមានជំនឿ លើ «អត្ថិភាពនិយម[11]»

---

[10] ឧញ្ញាសុត្តប្រីជាឥន្ទ ជា ទស្សវិទូខ្មែរ (១៨៥៦-១៩២៤)។
[11] អត្ថិភាពនិយម= Existentialisme : Doctrine selon laquelle l’homme n’est pas déterminé d’avance par son essence, mais libre et responsable de son existence។

«អត្ថិភាពនិយម»៖ មនុស្សលោក មិនមាន អត្តភាព ជាមុន ដោយសារ ខ្លួន មាន ធម្មជាតិ ជាមនុស្សលោក នោះទេ តែ ជា អាត្មាធិន[12] ទទួល ខុសត្រូវ លើ អត្តភាព របស់ខ្លួន»

យើងឃើញថា ទស្សនៈ នេះ មាន នៅក្នុង ការគោរពជំនឿ «មេ-បា» ក្នុង សញ្ញាណ «ព្រះ ថៅ តា» គឺថា មនុស្សលោក តែងតែ រស់នៅ មាន គោលបំណង ល្អ (មានព្រះ) សំរាប់ អាត្មាឯង ដូច ឧញ៉ាសុត្តន្តប្រីជាតន្ទ យកមក ធ្វើទ្រឹស្តី ចារថា ហេតុណា វត្ថុណា ដែល កើតឡើង ក្នុង លោកនេះ ហៅថា «គតិលោក» ព្រោះ គតិ ជា ដំណើរ ពី គ្រឿង ដល់ គ្រឿង, ដំណើរ ជា បទ សេចក្តីកម្លាំង អំណាចផ្លូវចិត្ត ទីពឹងក្តី អត់ធន់ក្តី (ថៅ)។ ទ្រឹស្តី នេះ ដែល ខ្មែរ បុរាណ យកមក ប្រព្រឹត្ត ក្នុង ការរស់នៅ របស់ខ្លួន ដែលមាន ប្រភព ច្បាស់លាស់ សំរាប់ ទុក ជា គោល ប្រព្រឹត្ត (តា)។

មនុស្សលោក មាន កាយ ជា រូប ឃើញនឹងភ្នែក មាន អារម្មណ៍ ទាំងពួង ជា គ្រិះ អត្តនោម័តិ (មាននៅក្នុងគំនិត) គ្រប់គ្រាន់ អាចទុកបាន ជា អត្តភាពរូបី មាន នៅក្នុង ពន្លឺបញ្ញា ជាគំនិត ប្រកបទៅដោយវិចារណញ្ញាណ របស់ អាត្មា។ ឧទាហរណ៍៖ ឯង ធ្វើបាបគេ តើគេដែលជាមនុស្ស ដូចឯងដែរ តើគេចេះឈឺចាប់នោះដែរឬទេ ? ការយល់ដឹង អំពី អារម្មណ៍ «ឈឺចាប់» នេះហើយ ជា រូបី មាននៅក្នុង វិចារណញ្ញាណ មាន ការអប់រំ ឲស្គាល់ ដឹងអ្វី ជា បាប (អំពើអាក្រក់) និង បុណ្យ (អំពើ ល្អ)។ បាប/បុណ្យ នៅទីនេះ មិនមែន ជា បាប/បុណ្យ ក្នុង សញ្ញាណ កម្ម/ផល នោះទេ គឺ ជា ការទទួលខុសត្រូវ របស់ អាត្មាជន ចំពោះមុខ អំពើ ដែលខ្លួនបានប្រព្រឹត្ត ដែលមាន អនុភាព ភ្លាមៗ ដោយយក បទដ្ឋាន នៃច្បាប់ ឬ វិន័យ ដែលមាននៅក្នុងសង្គម ជា លក្ខណវិនិច្ឆ័យ។

**អធិប្បាយ អំពី ធនធាន មនុស្សលោក ត្រូវចាំបាច់ ឆ្លើយនឹង សំណួរ ថា អ្វី ជា មនុស្សខ្មែរ ?**

**មនុស្សខ្មែរ** មានកាយ មានកាយវិការ ដែលអាចឲគេសម្គាល់បាន ជាពិសេស រវាង ខ្មែរ គ្នាឯង មានភាសា សំរាប់និយាយទាក់ទងគ្នា មានរបៀប គ្រិះរិះ ជា យថាប្រភេទ[13] និង នៅក្នុងបទដ្ឋាន នៃ មនុស្សទួទៅ ក្នុងលោកិយ ដែលនាំឲ មនុស្សខ្មែរ អាចមានលទ្ធភាព អាចមាន ការវិវឌ្ឍន៍ តាមចរន្ត នៃសេចក្តីចំរើន នៃ មនុស្សជាតិ និង ពង្រឹង លក្ខ

---

[12] អាត្មាធិន= សេរីជន ; Homme libre។
[13] គ្រិះរិះជាយថាប្រភេទ= Penser spécifique។

ណៈ ជា យថាប្រភេទ របស់ខ្លួនផង។ ដូច្នេះ មនុស្សខ្មែរ ជា មនុស្សលោក ធម្មតា ដូច មនុស្សលោកឯទៀត ក្នុងលោកិយ តែ ខុសពី ជនជាតិដទៃ ព្រោះខ្លួន រួមរស់ នៅក្នុង សង្គមជាតិ មាន ប្រវត្តិសាស្ត្រផ្ទាល់ មានភាសាផ្ទាល់ មាន ការត្រិះរិះផ្ទាល់ ខុសពីជាតិសាសន៍ដទៃទៀត ដែល គេមាន លក្ខណៈជា យថាប្រភេទ របស់គេរៀងៗខ្លួន។

ខ្មែរបុរាណ ជា សេរីជន គ្មានចរិត អាត្មានិយម ព្រោះខ្លួនរស់នៅក្នុងដំបន់មួយ ដែល មានធម្មជាតិ សម្បូរទៅដោយ ធនធានគ្រប់បែបយ៉ាង សំរាប់ចិញ្ចឹមជីវិត។ ភោគ នេះ ហើយ ដែលបង្កើតទឹកចិត្ត **ចែកចំណែក** ដល់ អ្នកដទៃ។ គំនិតចែកចំណែកនេះ ដែល ទុកជា ចរិកលក្ខណៈ ទី១ របស់ខ្មែរ។ ការរស់នៅ ក្នុងសភាពសម្បូរ នេះ នាំឲចិត្តខ្មែរមាន **សេចក្តីត្រាប្រណី** ព្រោះ មិនទុក អ្នកខ្សត់ ជា អ្នកដណ្តើមទ្រព្យ។ សេចក្តីត្រាប្រណីនេះ ដែលទុកជា ចរិកលក្ខណៈ ទី២ របស់ខ្មែរ។ សេចក្តីត្រាប្រណី នាំបង្កើតគំនិត **សាមគ្គីភាព** ។ សមាគ្គីភាពនេះ ដែលទុកជា ចរិកលក្ខណៈ ទី៣ របស់ខ្មែរ។ គំនិត សាម្គីភាព នេះហើយ ដែលបង្កើតជាគំនិត **សន្តិភាព**។ សន្តិភាពនេះ ដែលទុកជា ចរិកលក្ខណៈ ទី៤ របស់ខ្មែរ។ កត្តា ទាំងបួន នេះឯង ដែល ចាក់ជា **គ្រិះ នៃសង្គមខ្មែរ** ហើយ ជា ធនធាន នៃ មនុស្សខ្មែរ។

ជនខ្មែរ គោរពធម្មជាតិ ព្រោះវា ជា ធនធាន អាហារណីយ សំរាប់ការរស់នៅរបស់ខ្លួន និងជា ប្រភពដើម នៃការទូន្មាន សំរាប់ជីវិតរស់នៅ ព្រោះធម្មជាតិ ជាប្រភពច្បាប់មួយ នៃមនុស្សជាតិ និង ជា បច្ច័យ បានមកពី អំណាច នៃ គំនិតអរូប ដែលខ្មែរយើង ហៅថា «អ្នកតា» ដែលជា អ្នកថែរក្សា ធនធានធម្មជាតិ។ អ្នកតា នេះ ជា និមិត្តរូប នៃ បរិស្ថានវិទ្យា ដែលអ្នកបរិស្ថាននិយម ក្នុងសម័យបច្ចុប្បន្ន ផ្ញើសកម្មភាព ការពារធម្មជាតិនេះឯង។ ធ្វើអ្វីមួយ ដែលមានទំនាក់ទំនងនឹង ធម្មជាតិ ខ្មែរត្រូវចាំបាច់រៀបចំ ពិធីបួងសួង សូមអនុញ្ញាត ពី អ្នកតា ជាមុនសិន ទើបអាចសម្រេច នូវគោលបំណងបាន។ ខ្មែរបែកចែកធម្មជាតិ ជា បី ចំណែកៈ សត្វលោកនិយម ឧតុនិយម និង ពីជនិយម។ **សត្វលោកនិយម** គឺ មនុស្សលោក និង សត្វទាំងពួង រស់នៅក្បែរគ្នា។ **ឧតុនិយម** គឺ ជាតិ ដី ថ្ម ក្រួស សព្វបែបយ៉ាង ដែលខ្មែរយើងហៅថា ផែនដី ទុកជាទីអាស្រ័យនៅ របស់សត្វលោក។ **ពីជលោក** គឺ រុក្ខជាតិ តិណជាតិ ស្មៅវល្លិ ផ្សេងៗ។ វត្ថុធាតុ ទាំងបីនេះ ជា

ហេតុ ធម្មជាតិ ជា ផល សំរាប់ ការរស់នៅ របស់លោកិយ ដែលមាន គោលការណ៍ សំខាន់ មួយ គឺ សមតាបរិស្ថាន[14] ។

គំនិតជនខ្មែរ ក្នុង ការគ្រប់គ្រោង គតិលោក គឺ ផ្អែកទៅលើ សេរីភាព ការចែកចំណែក សេចក្តីត្រាប្រណី សាម្គីភាព និង សន្តិភាព ដែល មាន ធម្មជាតិ ជា ជម្រងអាស្រ័យរស់នៅ ក្នុងគោលការណ៍ សមតាបរិស្ថាន។ សព្វគំនិតខ្មែរបុរាណ ដែលបានរៀបរាប់មកនេះ គឺ នៅក្នុងគោលបំណងតែមួយគត់ គឺការធ្វើឲមាន សុខដុម ក្នុង លោកិយ ដែលជាសីលធម៌ដើមមួយ នៃ មនុស្សជាតិ។

ទោះបី ជនខ្មែរ ក្នុងសម័យបុរាណ មាន ការត្រិះរិះ ក្នុងការរស់នៅ របស់ខ្លួន លូតច្រើនទៅមុខយ៉ាងណាក្តី តែ ខ្លួន រស់នៅ ជា តួអង្គ  នៃ ធម្មជាតិ[15]។ ប្រព័ន្ធ នៃ ការត្រិះរិះ គឺ មានកំរិតត្រឹមតែ ការចេះសង្កេត របស់ខ្លួន លើ បាតុភូត នៃ ធម្មជាតិ តែប៉ុណ្ណោះ ហើយ យកវាមកធ្វើជា របបរស់នៅ ដើម្បី រក្សាសេចក្តីសុខ ចំពោះ ច្បាប់ធម្មជាតិ ដែលជាច្បាប់មួយ មានភាពប្រក្រតីផង តែក៏វាមាន ភាពមិនទៀងទាត់ដែរ។ អ្វីដែលមិនទៀងទាត់ ខ្មែរយើង យកវាមកបកស្រាយ ជា ទណ្ឌកម្ម ដែល ធម្មជាតិ ដាក់ទោស ព្រោះខ្លួន បានធ្វើអ្វីមួយ ដែលនាំមានការខុសឆ្គងដល់ គំនិតនៃធម្មជាតិ ហើយចម្លើយ នូវ ទណ្ឌកម្មនេះ មានតែមួយគត់ គឺ ពិធីបន់ស្រន់ សូមខមាទោស ពីធម្មជាតិ (អ្នកតា) មានសែនពៃ សូមឲ សព្វ ពិសិដ្ឋវត្ថុ លុបលាងកំហុសខ្លួន។ បើយើងយកពិធីនេះ មកធ្វើការពិចារណាបន្តិច យើងឃើញថាវា មិនមែនជា គំនិតអវិជ្ជមាន ទាំងស្រុងនោះឡើយ ព្រោះក្នុងពិធីបន់ស្រន់ សូមខមាទោស នេះ មាន គោលការណ៍សំខាន់ពីរយ៉ាង៖ ទី១ គឺ ការទទួលស្គាល់ នៃកំហុសរបស់ខ្លួន ទី២ សេចក្តីសន្យា ថាខ្លួនឈប់ធ្វើអំពើ ដែលនាំឲ មានការខុសឆ្គងនោះទៀតហើយ ដូច្នេះ បើយើង យកគោលការណ៍ ទាំងពីរនេះ មក បូករួមគ្នា វាបង្កើតបាន ជា គោលការណ៍ នៃ មេរៀន សំរាប់ការរស់នៅនេះឯង។ គំនិត បន់ស្រន់ សូមខមាទោស មិនមែនជាគំនិត កម្មវាសនា គេចមិនផុត នោះឡើយ ផ្ទុយទៅវិញ វាជាគំនិត នៃការទទួលកំហុស ព្រមនឹង ការជួលជុលជម្ងឺចិត្ត។ ចំណុចនេះ រឹតតែបញ្ជាក់បន្ថែមថា ជនខ្មែរ ក្នុងសម័យបុរាណ ជា ជន មានការទទួលខុសត្រូវ នូវ រាល់អំពើ ដែលខ្លួនបានប្រព្រឹត្តិ។ ការទទួលខុសត្រូវ នេះឯង ដែលនាំបង្កើតឲមាន នៅក្នុង គំនិតខ្មែរ នូវ សញ្ញាណ គំនិតយុត្ត ដែលទុក ជា ព្រំដែន នៃ សេរីភាព បុគ្គល ចំពោះ ជន

---

[14] សមតាបរិស្ថាន= L’environnement équilibré។
[15] តួអង្គនៃធម្មជាតិ= Sujet de la nature។

ដទៃទៀត។ ទស្សនៈ នេះ ជាគ្រឹះ នៃ ដំណើរ នៃការចេះដឹងខ្មែរ ក្នុង ការវិវឌ្ឍន៍ ជា ធម្មជាតិ របស់ ជនខ្មែរ និង សង្គមខ្មែរ។

## ដំណើរ នៃ ការចេះដឹងខ្មែរ

មនុស្សជាតិ មាន ការលូតលាស់ ទាំងផ្លូវកាយ និង ផ្លូវគំនិត ដែលគេនិយមហៅថា អារ្យធម៌។ បញ្ញា មនុស្សលោក ចាំងចែងរស្មី ពីបុគ្គលមួយ ទៅលើបុគ្គលម្នាក់ទៀត រស់នៅក្បែរខ្លួន បន្តរីកសាយពាសពេញលោកិយ ហើយ ញាំង៖ វិស័យមនុស្ស មានអារ្យធម៌ ដែលជា ការផ្សាំង មនុស្សលោក ប្រកបដោយសេចក្តីល្អវិសុទ្ធ។ អំពើនេះ មាន ទិស្សមានាការ ហើយ ដំណើរ ពីទីកន្លែងមួយ ទៅទីមួយទៀត ផ្តើមជារូបភាព នូវ អាយុ នៃ ការជឿនលឿន ដែលបង្កើតឡើង ពីសំណាក់ តួអង្គ ជាច្រើន ដែលគេឲ្យឈ្មោះថា ពួកអ្នកមានទេពកោសល្យ។ ទេពកោសល្យនេះ ជាសកម្មភាពស្ម័គ្រចិត្ត ចាំបាច់ ចេញមកពីទឹកចិត្ត អ្នកមានទេពកោសល្យ ក្នុងគំនិត សេរីភាព មានពីកំណើត នៃ មនុស្សលោក។ ខ្មែរ អ្នកមានទេពកោសល្យ ជា ចារី[16] នៃការវិវឌ្ឍន៍ នូវការចេះដឹងខ្មែរ។

ការវិវឌ្ឍន៍ ពី សម័យបុព្វប្រវត្តិសាស្ត្រ ចូលមកក្នុង សម័យប្រវត្តិសាស្ត្រ ចាប់ផ្តើមបន្ត ពីសម័យ ស្តេច ហ៊ុន ទៀន (ដើមស.វ.ទី៣) ដែលជាអ្នកនាំមកនូវ ការចេះដឹងថ្មី ចូលមកក្នុងស្រុកខ្មែរ តាមសន្តិវិធី មាន របបរាជានិយម និង ជំនឿសាសនា (ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា)។

### អ្វីដែលទុកជា អធិកលាភ[17] នៃ ការចេះដឹងថ្មី ?

ដូចបានជំរាបខាងលើរួចមកហើយថា ខ្មែរបុរាណ ជា តួអង្គ នៃ ធម្មជាតិ រស់នៅក្រោមច្បាប់ធម្មជាតិ ក្នុងឋានៈ ជា សេរីជន ក្នុងក្រុម មាន ទេពកោសល្យ មានប្រាជ្ញា រៀបចំសង្គម ឲមាន សំដាប់តាំងពីសម័យ បុព្វប្រវត្តិសាស្ត្រមកម្លេះ។ ស្តេច ហ៊ុន ទៀន គ្រាន់តែបន្ត ការរៀបចំសង្គម ព្រោះព្រះអង្គ មើលឃើញថា សង្គមខ្មែរ មាន មូលដ្ឋាន មាំទាំ មានការគ្រឹះរិះ ប្រកបដោយវិចារណញ្ញាណ មាន ប្រពៃណី ជា ថាមវន្ត។ ទាំងអស់ នេះ ផ្សំ

---

16 ចារី= អ្នកបង្កើត ; Auteur។
17 អធិកលាភ= ការកើតលើស ; la plus-value។

ជា «**បាតខ្មែរ**[18]» រហូតមកដល់សព្វថ្ងៃនេះ។ តែ «បាតខ្មែរ» នេះ ត្រូវចាំបាច់ មាន យាន ថ្មីដើម្បី ធ្វើដំណើរ តាម ចរន្ត នៃការវិវត្តន៍ នៃ មនុស្សជាតិ។ យាន នេះហើយ ដែល ព្រះបាទហ៊ុនទៀន ជា អ្នកដើរតួ ដោយយក ការចេះដឹង របស់ ព្រះអង្គផ្ទាល់ មកធ្វើជា ខ្សែ សម្រាប់ភ្ជាប់ រវាង ចំណេះថ្មី ជាមួយនឹង បាតខ្មែរ។ អ្វី ជា ចំណេះ ថ្មី ? គឺ៖

- របប រាជានិយម៖ ព្រោះថា មុន ព្រះបាទ ហ៊ុន ទៀន របបដឹកនាំខ្មែរ ជា របប អភិជនឬ មេកន្ទ្រាញ។ ជំនាន់ ហ្នឹង ផែនដីខ្មែរ បែងចែក ជាដី លោក ម្ចាស់ ដែលជា មេកន្ទ្រាញនៃទឹកដី និង កុលសម្ពន្ធ ដែលខ្លួនត្រួតត្រា។ ព្រះនាង លិវ យី ដែលខ្មែរ តែងតែទុកជាមហាក្សត្រី ទី១ ខ្មែរ គ្រាន់តែ ជា មេកន្ទ្រាញម្នាក់ ក្នុងចំណោម មេកន្ទ្រាញ ដ៏ទៃទៀត តែប៉ុណ្ណោះ។ បើយោងតាមរឿងព្រេងខ្មែរ យើងអាចសន្និដ្ឋានបានថា ជ័យជំនះព្រះបាទហ៊ុន ទៀត, ដែលជា ជន ដែលគ្មានអ្នកណាស្គាល់ ប្រាកដ, លើ ព្រះនាងលិវយី គឺជា ជ័យជំនះ សាស្ត្រាវុធ ថ្មី គឺ ធ្នូ លើអាវុធ បុរាណ ខ្មែរ។ ត្រូវទុក ជា អាទ៍ ព្រះបាទ ហ៊ុនទៀន ជាអ្នកចម្បាំង មកដល់ ស្រុកខ្មែរ តាមផ្លូវសមុទ្រ ក្នុងគោលបំណង ពិតប្រាកដ គឺ ច្បាំងដណ្តើម ទឹកដី ដើម្បី ត្រួតត្រា។ ដូច្នេះព្រះបាទ ហ៊ុន ទៀន មាន គ្រោងការមានពួកហើយនិង មាន អ្នកណែនាំ ស្គាល់ដំបន់ ពិតប្រាកដ ទើបអាច ធ្វើឲសម្រេចនូវគោលបំណង របស់ខ្លួនបាន។ ក្រោយ ពីបានទទួល ជ័យជំនះ លើព្រះនាង លិវ យី រួចស្រេចហើយ ព្រះអង្គ ប្រកាស ជា មហោឡារិក តែងតាំង ព្រះនាងលិវ យី ជាមហាសីរបស់ព្រះអង្គ។តរិយាបថ ហ្នឹង ធ្វើឡើង ក្នុងគោលបំណងបង្ហាញដល់ប្រជាជន ថា ការបេះទង្គិចអាវុធដែលមានកើតឡើង គឺជា ការប្រយុទ្ធបន្តិចបន្តួចគ្មានអ្នកឈ្នះ គ្មាន អ្នកចាញ់។បន្ទាប់មក ព្រះអង្គ ចាប់ផ្តើម ពង្រិកទឹកដី តាម សន្តិភាពផងតាម សង្គ្រាមផងគឺទង់ទាញឬ បង្ក្រាប មេកន្ទ្រាញ ដទៃទៀត ឲមកនៅក្រោមការត្រួតត្រា របស់ ព្រះអង្គក្នុង របប ដឹកនាំថ្មីមួយ ហៅថា **រាជានិយម**។

## រាជានិយម ទី១

រាជានិយម របស់ ព្រះបាទ ហ៊ុន ទៀន ជា សំយោគ នៃ ទំលាប់ខ្មែរដើម ជាមួយនឹង ជំនឿសាសនា របស់ព្រះអង្គ គឺ ព្រហ្មញ្ញសាសនា។ តែ របប ដឹកនាំថ្មី ហ្នឹង មិនជា **ទេវារបប**[19]ដាច់ខាត នោះឡើយ ព្រោះនៅក្នុង ព្រហ្មញ្ញាសាសនា មានការបែងចែក ដាច់គ្នា

---

[18] បាតខ្មែរ= Fond Khmer។
[19] ទេវារបប= Régime théologique។

រវាងអ្នកដឹកនាំ និង ទេវជន ហើយ នៅក្នុងជំនឿអាយខ្មែរ ទៀត ក៏គ្មានការលាយលំ រវាងអ្នកដឹកនាំ ជាមួយ អាចារ្យ នោះដែរ។ ព្រះបាទ ហ៊ុន ទៀន មិនបានប្រកាសព្រហ្មញ្ញសាសនាជាសាសនាថ្មី ក្នុងទឹកដី ដែលព្រះអង្គត្រួត្រា នោះឡើយ តែការប្រតិបត្តផ្ទាល់របស់ ព្រះអង្គ វាមានឥទ្ធិពល ជាច្រើន ទៅលើ ថ្នាក់ដឹកនាំជាតិ។ តែ ឥទ្ធិពល ហ្នឹងមិនសូវមានច្រើន ទៅលើ ប្រជាជន ព្រោះ គាត់ មានជំនឿអាយ របស់គាត់ មាំទាំណាស់រួចហើយ ដែល យើងលើកយកបង្ហាញរួចខាងលើនោះឯង។ តែរបប រាជានិយម នាំមកនូវ ទ្រឹស្តី របៀបដឹកនាំ ត្រឹមត្រូវ (rationnel) មួយ ដោយយក បាតខ្មែរ មកបញ្ចូលក្នុងទ្រឹស្តី របៀបដឹកនាំថ្មី។ បាតខ្មែរ «មេ-ប៉ា» ដែលមាន សញ្ញាណ «ព្រះ ចៅ តា» នៅក្នុងគំនិតខ្មែរ បានក្លាយ ជា សីលធម៌ (ព្រះ), មហាក្សត្រ (ចៅ), ក្បួន-ច្បាប់ (តា)។ អ្វីដែលជាសីលធម៌ នៅក្នុង ទ្រឹស្តីថ្មី ខ្មែរ ទុក ជា ព្រះ, អ្នកដឹកនាំ ប្រកបដោយ សីលធម៌ ខ្មែរ ហៅថា ចៅ, អ្វី ជា តា ប្រែក្លាយ ជា ច្បាប់ សំរាប់ ដឹកនាំ ឬ សំរាប់ រស់នៅ។ ដូច្នេះ របប រាជានិយម ដែល ព្រះបាទ ហ៊ុនទៀន ផ្សាំនៅក្នុងសង្គមខ្មែរ គឺជា របប មាន អ្នកដឹកនាំ ប្រកបដោយ សីលធម៌/យុត្តិធម៌ មាន ក្បួន-ច្បាប់ ជា ឧបករណ៍ សំរាប់ ដឹកនាំ។ ហេតុនេះឯង បានជាខ្មែរ ទម្លាប់ហៅ មហាក្សត្រ ថា «ព្រះចៅ» ឬ «ព្រះមហាក្សត្រ»។ ក្នុងអត្ថន័យ ហ្នឹងឯង ដែល ខ្មែរទុក របប រាជានិយម ជា កម្លាំងជាតិ សំខាន់មួយក្នុងចំណោមកម្លាំងខ្មែរ ដ៏ទៃទៀត ដែលមាន បាតខ្មែរ ជា មូលដ្ឋាន។

សួរថាតើ ការបង្កើតមុនដំបូង នៃរបប រាជានិយម នាំមក នូវសេចក្តីចេះដឹងអ្វីខ្លះ ដល់ស្រុកខ្មែរ ?

ទី១ សង្គមនិម្មាណ សម័យ (structure sociale moderne) ;

ទី២ របៀបដឹងនាំជាតិ ;

ទី៣ មន្រ្តីនិយម (fonctionnalisme) និង មុខងារ របស់ ព្រះមហាក្សត្រ។

## រាជានិយម ទី២

ជា របប ដែល ព្រះបាទ ជ័យវរ្ម័ន ទី២ (៨០២-៨៥០) បង្កើតក្នុងដើម សតវត្ស ទី៩ ដែលជាការផ្តើម នៃសម័យអង្គរ។ ប្រវត្តិ ព្រះបាទ ជ័យវរ្ម័ ទិ២ វាស្រដៀងគ្នានឹង ព្រះបាទ ហ៊ុនទៀន ដែរ គឺព្រះអង្គ ចូលមកស្រុកខ្មែរ តាមផ្លូវ សមុទ្រ មានជីវប្រវត្តិ មិនច្បាស់លាស់គ្រាន់តែដឹងថា ជា រាជវង្សានុវង្ស ដែលត្រូវជ្វា ចាប់យកទៅស្រុកគេ តាំងពី វ័យកុមាហើយ វិលត្រឡប់ចូលស្រុកខ្មែរវិញ ដើម្បី ធ្វើ បូជនីយកិច្ច បង្រួបបង្រួម ប្រទេសខ្មែរនៅពេលនោះ បែកជាពីរនគរ គឺ ចេនឡាទឹក (អតិតៈ នគរភ្នំ ឬ ហ្វូណន់) និង ចេនឡា ដីគោក ឬ ខ្មែរលើ និង រំដោះប្រទេស ឲមានឥស្សរភាព ពីនគរជ្វា។ ក្រោយពីបាន បង្រួប

បង្រួម និង សន្តិភាវក្រើត ស្រុកខ្មែរបានវិញ ព្រះអង្គ បានបង្កើត សន្តនិវង្ស និងរបប
រាជានិយម ថ្មីមួយ គឺ រាជានិយម ទេវរាជ។ លទ្ធិ ទេវរាជនេះ មានគោលដៅ ធ្វើឲមហា
ក្សត្រ មានឋានៈជា ចក្រវាតិន (ស្តេចក្រវាល) និង ស្តេចអាទិទេព ពាក្យខ្មែរបុរាណហៅ
ថា កម្រតេងជគតរាជ្យ (ស្តេច ជាម្ចាស់ នៃចក្រវាល)។ លទ្ធិនេះ មាននៅក្នុងព្រហ្ម
ញ្ញសាសនា មានពីធីច្បាស់លាស់ ដែលមាន ព្រាហ្មណ៍ មាន ចំណេះវិជ្ជាខ្ពង់ខ្ពស់ ជាពិធីករ
ក្នុងឋានៈ ជា អន្តរការី រវាង ឋានលោកកីយ នឹង ឋានទេវរាជ ធ្វើពីធីបូជា ឲ មហា
ក្សត្រជា មនុស្សលោក ឲ ក្លាយជា អាទីទេព រស់នៅ ឋានលោកកីយ។ លទ្ធិ ទេវរាជនេះ
គោរពសិវលិង្គ ដែលគេសន្មត់ថាបានមកពីព្រះឥសូរ តាមរយៈព្រាហ្មណ៍ ពីធីករ។ ការ
គោរព សិវលឹង្គ នេះ មានតាំងពីសម័យ នគរភ្នំ និង ចេនឡា (សិលាចារឹកឆ្នាំ៧១៣របស់
ព្រះនាងជ័យទេវី) តែមិនមានលក្ខណៈ ជា លទ្ធិនយោបាយ គ្រាន់តែជាជំនឿ របស់ ព្រះ
មហាក្សត្រតែប៉ុណ្ណោះ។ ព្រះបាទ ជ័យវរ្ម័ន ទី២ នេះឯង ជា អ្នកដូរ ឈ្មោះស្រុកខ្មែរ ទៅជា
កម្ពុជា តែទោះបីយ៉ាងណាក័ដោយ ប្រជាជនខ្មែរ នៅតែហៅ ប្រទេសខ្លួនថា ស្រុកខ្មែរ
ជានិច្ចរហូត មកដល់សព្វថ្ងៃនេះ។ ឈ្មោះ ហ្វូណន់ ក្តី ចេនឡាក្តី ជា ឈ្មោះ ចិន ហៅ ហើយ
អ្នកប្រវត្តិសាស្រ្ត បស្ចឹមប្រទេស គេយកឈ្មោះនេះ ជា ឈ្មោះ ជាប្រត្តិសាស្រ្តនៃស្រុកខ្មែរ
តែម្តងព្រោះវាមាននៅក្នុងឯកសារចិន ដែលជា ព័ស្តុតាង នៃ វិទ្យាប្រវត្តិសាស្រ្ត។

សួរថាតើ របប ទេវរាជ នាំមក នូវសេចក្តីចេះដឹងអ្វីខ្លះ ដល់ស្រុកខ្មែរ ?

ទី១ គឺ **សញ្ញាណ** នៃរដ្ឋខ្មែរ ;

ទី២ គឺ **លទ្ធិដឹកនាំជាតិ** ;

ទី៣ **ឯកភាពជាតិ** ក្នុងខ្សែសីមាជាតិ។

## រាជានិយម ទី៣

យើងអាចចាត់ទុក សម័យ មហានគរ (១១៨១-១៣៤០)  ជា ស្នាដៃនៃរាជានិយមទី៣
ចាប់ផ្តើមពីរាជ្យ ព្រះបាទ ជ័យវរ្ម័នទី៧ មកដល់ រាជ្យ ព្រះបាទត្រសក់ផ្អែម។ ដូចជំរាប
ខាងលើរួចមកហើយ ថា រាជានិយមទី២ (៨០២-១១៨១) បានចាក់គ្រឹះ របបដឹកនាំពោរ
ពេញដោយថាមពលជាតិ មាន និមិត្តរូប នៃឫទ្ធានុភាព គឺ នគរធំ ជា រាជធានី នៃ
មហានគរ និង អង្គរវត្ត ជា ការចងភ្ជាប់ រវាង លោកកីយ ជាមួយ ឋានបរមសុខ របស់
ព្រះសពមហាក្សត្យ។ ព្រះបាទ ជ័យវរ្ម័នទី៧ ព្រះអង្គ បានផាត់ពណ៌ថ្មី ដល់របប រាជា
និយម ជាពណ៍ មនុស្សនិយម លើ បាត នៃពណ៌ ទេវរាជនិយម។ប្រសាទបាយ័នជា សញ្ញា
ល័ក្ខនៃមនុស្សនិយម នេះឯង។ ជា ពិសេស ការលើក តម្លៃ ពុទ្ធសាសនា នៅក្នុងរាជា
ណាចក្រឲស្មើភាពនឹង ព្រហ្មញ្ញសាសនា ក៏ជា ការបញ្ជាក់ នូវការយកចិត្តទុកដាក់ នៃ

បញ្ហាមនុស្សដែលមាននៅក្នុង ជិពជន្ទ (vie quotidienne) នៃមនុស្សលោក។ដូច្នេះ អាថ៌អំពល់របស់ព្រះបាទ ជ័យវរ្ម័នទី៧ គឺ ទុក្ខសោក របស់ប្រជារាស្ត្រ ដែល មានចារទុកលើសិលាចារឹក ជាប្រវត្តិសាស្ត្រថា «ទុក្ខសោក របស់រាស្ត្រ គឺជា ទុក្ខសោក របស់ ព្រះមហាក្សត្រ»។

ទោះបីព្រះអង្គ ជាមហាក្សត្រ មនុស្សនិយម តែព្រះអង្គ ទុកសំណាមក្នុងប្រវត្តិសាស្ត្រខ្មែរ ជាមហាក្សត្រ ធ្វើសញ្ជ័យ (conquérir) ពង្រីក ឬ ដណ្តើមទឹកដី ពីប្រទេសជិតខាងដើម្បី ពង្រីកទឹកដីជាតិ និង អំណាចចក្រ របស់ព្រះអង្គ។ ព្រះបាទជ័យវរ្ម័នទី៧ ជាមហាក្សត្រ មានពហុព្រះភក្ត្រ ដូចជា ពហុភក្ត្រ នៃប្រសាទ បាយ័ន នោះដែរ។ ខ្មែរយើងទុកព្រះបាទ ជ័យវរ្ម័នទី៧ ជា ឬទ្ធានុភាពខ្មែរ ហើយតែងតែ អន្ទងហៅព្រលឹង ព្រះអង្គ មកជួយរំដោះ ទុក្ខខ្មែរ ឬ មកធ្វើជា គំរូ នៃភិយ្យោភាព របស់ជាតិខ្មែរ។

នៅក្នុង រាជានិយមទី៣ បើយោងតាមឯកសារចិន សរសេរ ដោយជនជាតិចិន មួយរូប ដែលបានមកធ្វើទស្សនាការ ប្រទេសកម្ពុជា ក្នុង ឆ្នាំ ១២៩៥ ថា ស្រុកខ្មែរ នៅក្នុង ជំនាន់នោះមានប្រតិបត្តិ សាសនាបីយ៉ាង[20]៖ ព្រហ្មញ្ញសាសនា, ពុទ្ធសាសនា និង ជំនឿលើព្រលឹង។ នេះជាសង្ខេប នៃសំណេរ របស់ជនជាតិចិន ៖

**ព្រហ្មញ្ញសាសនា**៖ ពួកព្រាហ្មណ៍ (Pan-ki)  ពាក់សំលៀកបំពាក់ដូចជនសមញ្ញ តែមាន បន្ទ បង្គិកា (ruban) ព័ណ ស លើ ក រហូតដល់ថ្ងៃស្លាប់។ ពួកនេះ គ្មានសាលារៀន និង គ្មានសៀវភៅសំរាប់សិក្សា តែពួកទាំងនេះ នៅពេលដែលបានចូលទៅបំរើព្រះមហាក្សត្របានក្លាយ ជា ឥស្សរជន ខ្ពង់ខ្ពស់នៅក្នុងបរមរាជវាំង។ ពួកនេះ មានឈ្មោះថា បាគូដែលជា បុព្វបុរស របស់ពួកព្រាហ្មណ៍ មាននៅក្នុងស្រុកខ្មែរ និង សៀម សព្វថ្ងៃ។

**ពុទ្ធសាសនា**៖

ពួកគ្រូ (tchou-koui)   កោរសក់ ពាក់ស្បង់ព័ណលឿង ទុកដៃស្តាំ នៅក្រៅស្បង់។ ពួកគ្រូ ឆាន់ សាច់ តែមិន ឆាន់ស្រា។ ពេល ដើរទៅណាមកណា តែងតែបាំងឆត្រ ជូនជិះលើ គ្រែស្នែង មាន អ្សកសែង។ ពួកគ្រូ មានទីកន្លែងសំរាប់ប្រតិបត្តិធម៌ មានឈ្មោះថាវត្ត តែខ្មែរបុរាណ ហៅថា ក្តី។  អាគារ នៃវត្ត ច្រើនតែប្រក់ក្បឿង ហើយមានបដិមាករតែ មួយគត់គឺ បដិការករ នៃព្រះពុទ្ធ។ ក្នុងវត្តនិមួយៗ មាន សៀវភៅពិសិដ្ឋជាច្រើន សរសេរលើ ស្លឹកថ្នោត ដាក់គរលើគ្នា។ ពួកគ្រូទាំងនោះ ជា សាស្ត្រាចារ្យ បង្រៀន តែកុមា

---

[20] Adhémard LECLERE (Le Bouddhisme au Cambodge) – 1899។

នៅក្នុងវត្ត ដែលអ្នកស្រុក ជាមាតាបិតា បញ្ជូនឲទៅរៀន ដែលបុរាណខ្មែរហៅថា «ឲ កូនទៅនៅក្ដី» ហើយឈប់សិក្សា នៅពេលពេញវ័យ វិលត្រឡប់មករស់ជាបុគ្គលធម្មតា ដែលអ្នកស្រុកហៅថា បណ្ឌិត តែក្រោយមក ពាក្យនេះក្លាយទៅជា អន្ទិតជាពាក្យបន្ថយ នូវតម្លៃ របស់ពាក្យបណ្ឌិត។ តាម លោក A. Leclere ការពិពណ៌នា នេះ គឺ វាគ្មានអ្វីក្រៅ ពី សំដៅទៅពុទ្ធសាសនា និង ព្រះសង្ឃ នោះឡើយ។

**ជំនឿលើព្រាលីង៖**

ចិនហៅថា ពួក មានជំនឿនេះថា ប៉ៅ-ស្សឺ (pao-sse) ពាក់សំលៀលបំពាក់ ដូចជន សាមញ្ញ តែជួនក្បាលក្រណាត់ពណ៌ ក្រហម ឬ ស។ ពួកនេះ មាន វិហារ, អាគារ, រោងជី (couvent) សំរាប់ពួកស្ត្រី។ តែសំណង់ទាំងនោះ មិនល្អដូចវត្ត នៃពុទ្ធសាសនា នោះទេ។ នៅក្នុងវិហារ មានបដិមាករ ជា គំនរថ្ម។ ពួកនេះ មិនបរិភោគ ជាមួយជន ដែលមិន មែន នៅក្នុងពួកខ្លួននោះឡើយ ហាក់បីដូចជាមានការអៀនខ្មាស់ណាស់ នៅពេលខ្លួន បរិភាគ ហើយពួកនេះ មិនហូបសុរាដូចព្រះសង្ឃដែរ។ តាមការសន្និដ្ឋាន របស់លោក A. Leclère ពួកនេះ មាន ដើមកំណើត នៅក្នុងវណ្ណៈសូទ្រ៖ នៃព្រហ្មញ្ញសាសនា ព្រោះវណ្ណៈ នេះមិនឲនរណាឃើញពួកខ្លួន នៅពេលបរិភោគអាហារ។ តែ នៅស្រុកខ្មែរ ពួកនេះ គ្មានលក្ខណៈជា វណ្ណៈទាបជាង វណ្ណៈដ៏ទៃទៀត ដែលមាននៅក្នុងព្រហ្មញ្ញសាសនា នោះ ឡើយ។

សួរថាតើ របប រាជានិយម ទី៣ នាំមក នូវសេចក្ដីចេះដឹងអ្វីខ្លះ ដល់ស្រុកខ្មែរ ?

- ការអប់រំអ្នកដឹកនាំ ;

- មហិច្ឆតាជាតិ ;

- សេចក្ដីថ្កុំថ្កើងជាតិ។

រួមសេចក្ដីមក យើងអាចចាត់ទុកថា របបរាជានិយមទី៣ ជារបបជាតិនិយម វិត្ថារ កម្ម(nationalisme expansionniste)។ របបនេះ ត្រូវការ ធនធាន មនុស្ស និង សម្ភារៈ ច្រើនណាស់ ដើម្បី រក្សាអំណាចមជ្ឈឹម និង ឆព្វណ្ណរង្សី នៃអ្នកដឹងនាំ។ កង្វះធនធាន នេះឯងហើយ ដែលនាំឲ របបរាជានិយមទី៣ រំលស់ នូវឫទ្ធានុភាព របស់ខ្លួនបន្តិចម្ដ ងៗ នៅក្នុងប្រទេស និង នៅ ក្រៅប្រទេស ផង ដែលនាំឲមាន បដិវត្តន៍វាំងមួយកើត ឡើង នៅក្នុងឆ្នាំ ១៣៤០ ដូចមាននៅក្នុងរឿងព្រេងខ្មែរ «តាត្រសក់ផ្អែម»។ ទោះបី រឿងនេះ អ្នកប្រាជ្ញ ប្រវត្តិសាស្ត្រ បរទេស គេចាត់ទុកជារឿងព្រេងខ្មែរ តែខ្មែរយើងវិញ ទុកជាប្រវត្តិសាស្ត្រ របស់ជាតិពិត។

## រាជានិយម ទី៤

របបរាជានិយម ទី៤ ជា រាជានិយមប្រជាមានិត (monarchie populaire) និយមពុទ្ធសាសនា។ ការឡើងគ្រងរាជ្យ នៃ តាត្រសក់ផ្អែម ដែលជារាស្ត្រសាមញ្ញ អ្នកកាន់ពុទ្ធសាសនា ជាការបញ្ជាក់ នៃសារជាតិ នៃរាជានិយមទី៤នេះឯង។ តែរបបថ្មីនេះ នៅរក្សាទម្រង់ចាស់ នៃរបបរាជានិយម ដូចយ៉ាងគ្រប់ពិធី រីតិ (rite) នៃព្រាហ្មបុរោហិត នៅក្នុងព្រះបុរមរាជវាំង ដែលរាជានិយមខ្មែរ ទុកជាពិធីមួយ ដែលពុំអាចជៀសបាន សំរាប់ផ្តល់នូវ ធម្មានុរូប ដល់ព្រះមហាក្សត្រ ទាំងក្នុងលោកកិយ និង ឋានព្រះព្រហ្មណ៍។

**អភិនព** (អ្វីដែលកើតថ្មី) នៅក្នុងរាជានិយមទី៤ គឺ ការទុកពុទ្ធសាសនា ជាសាសនា របស់ព្រះមហាក្សត្រ ដែលជាចំណុចសំខាន់ នូវបំលាស់ប្តូរ សារជាតិ នៃរបបរាជានិយម។ ព្រះមហាក្សត្រ លែងជាអវតា នៃទេវរាជ តែព្រះអង្គជាមនុស្សមានបុណ្យ ទទួលគុណស្រ័យដែលព្រះអង្គ កសាងពីអតិតជាតិ របស់ព្រះអង្គ។

សួរថាតើ របប រាជានិយម ទី៤ នាំមក នូវសេចក្តីចេះដឹងអ្វីខ្លះ ដល់ស្រុកខ្មែរ ?

- អត្តភាពនិយម (existentialisme) គឺ ការឲតម្លៃ ដល់ ជិវិតរស់នៅរបស់មនុស្ស លើភាវៈ(être) នៃមនុស្ស តែវត្ថុធាតុទាំងពីរនេះ វាជា គូរបង្គ្រប់ សំរាប់មនុស្សលោក ;

- សិលធម៌ នៃពុទ្ធសាសនា ;

- ច្បាប់សង្គមជាច្រើន។

បើខ្មែរយើងបានអានប្រវត្តិសាស្ត្រជាតិ ច្បាស់ជាអាចយល់ឃើញថា រាជានិយមទី៤ជាពេលវេលាមួយ ដែលខ្មែរគ្មានការគំរាមពីជម្លោះផ្ទៃក្នុងប្រទេស និងជាមួយប្រទេសជិតខាង តាមផ្លូវសង្គ្រាម។ ដែលទុកឲអ្នកដឹកនាំខ្មែរថ្មី មានពេលវេលារៀបចំ ឡើងវិញ នូវ រចនសម្ព័ន្ធរដ្ឋ សង្គម និងសំដែងនូវមហិច្ឆតាជាតិ ដោយលើក រាជធានី ត្រឡប់ទៅតាំងទីនៅមហានគរវិញ។ ទង្វើរបស់ព្រះបាទតាត្រសក់ផ្អែមនេះ អាចធ្វើបានលុះត្រាតែមានប្រជាជន យល់ស្រប ហើយសុខចិត្ត នាំគ្នាទៅរស់នៅ នៅក្នុងតំបន់មហានគរ ដែលជាកម្លាំងពល នៃសេដ្ឋកិច្ច សំរាប់ការរស់នៅ នៅក្នុងរាជធានី។ តែ នគរខ្មែរក្នុងសម័យរាជានិយមទី៤ ក៏លែងមានរូបភាពជា មហានគរ ក្នុងដំបន់អាស៊ីអគ្នេយ៍ដែរ តែនៅមានសល់ ធនធានមនុស្ស, សម្ភារៈ និង ធម្មជាតិ សំរាប់ការពារជាតិ បានគ្រប់គ្រាន់រហូតមកដល់សម័យ ក្រុងលង្វែក។ ជ័យជំនះ សៀម នៅទីក្រុង លង្វែក ក្នុង

ឆ្នាំ១៥១៥ ជាអន្តកាល (កាលជាទីបំផុត) នៃកម្លាំងអានុភាពខ្មែរ នាំឲស្រុកខ្មែរក្លាយជា អំពា (របស់ដែលគេវាយដណ្តើយក) របស់ប្រទេសជិតខាង។ បន្ទាប់ពី រលំក្រុងលង្វែក ស្រុកខ្មែរ រអិលបន្តិចម្តង ទៅរកភាពជា ប្រទេស ជួនកាលចំណុះសៀម ជួនកាលចំណុះយួនជួនកាលជា សហវិជិតរាជ្យរបស់ ប្រទេស សៀម/យួន។ ក្នុងសត្វវត្សទី១៧ ស្រុកខ្មែរធ្លាក់ទៅក្នុងការអន្តរាយ កើតមកពីសង្គ្រាម នៃពូជពង្សស្តេច ដណ្តើមរាជ្យគ្នា នាំឲប្រទេសយួន ធ្វើអន្តរាគមន៍ក្នុងជម្លោះខ្មែរ ហើយឆ្លៀតចូលមកកាន់កាប់ទឹកដីខ្មែរយ៉ាង ងាយបំផុត៖ ទីក្រុងព្រៃនគរ ក្លាយជា ស៊ើង៉ុង (១៦៩៨) ហើយទឹកដីកម្ពុជា មួយចំណែកធំ ក្លាយជាខែត្រយួន។ មកដល់ឆ្នាំ ១៨៤០, កម្ពុជាក្រោមទាំងមូលត្រូវបានប្រទេសដៃវៀត (យៀកណាម) ភ្ជាប់នឹងទឹកដីគេ ជាដំបន់រណប។ ចំណែកប្រទេសសៀម ក្នុងឆ្នាំ ១៧៩៤ ដណ្តើយក ខែត្រ បាត់ដំបង ដាក់ជាខែត្ររណប។ មហិច្ឆតា នៃសៀម/យួន លេបទឹកដីខ្មែរ មានបន្តរហូតមកដល់ រាជ្យ ព្រះបាទអង្គដួង (១៨៤៧-១៨៦០) ដែលជាមហាក្សត្រ ដែល ប្រទេសសៀម/យួន គេស្រុះស្រួលគ្នា ទុកស្រុកខ្មែរជា សហវិជិតរាជ្យ យកដងទន្លេមេកុង ជាខ្សែបែងចែងស្រុកខ្មែរ ជា២ដំបន់៖ ខាងលិចឋិតនៅក្រោមឥទ្ធិពលសៀម ខាងកើត ឋិតនៅក្រោមឥទ្ធិពលយួន។ ស្ថានភាពនេះត្រូវបានបារាំងបញ្ចប់ តាមសន្ធិសញ្ញា បារាំង/ខ្មែរ ក្នុងឆ្នាំ ១៨៦៣៖ មហាក្សត្រខ្មែរ យល់ព្រមឲប្រទេសបារាំង ជាអ្នកការពារខ្លួន ចំពោះមហិច្ឆតា លេបទឹកដីខ្មែរ ពីសំណាក់ប្រទេសជិតខាង។ ស្រុកខ្មែរ បានចេញរួចពិតពីក្រញាំដៃសៀម/យួន តែឋិននៅជានិច្ចជាប្រទេសចំណុះបរទេស ដដែល។ ស្រុកខ្មែរ បានរស់នៅក្នុងអាណានិគមបារាំង អស់រយៈពេល ៩០ឆ្នាំ (១៨៦៣-១៩៥៣) មានមហាក្សត្រសោយរាជ្យ ៤ព្រះអង្គ (នរោត្តម, សីសុវត្ថិ,សីសុវត្ថិ មុនីវង្ស និង នរោត្តម សីហនុ) ទ្រង់ បានធ្វើ សហប្រតិបត្តការ គ្មានស្មារប្រេះ ជាមួយអាណានិគមបារាំង ដើម្បីរក្សាទឹកដីខ្មែរ ដែលនៅសេះសល់ ប៉ុន្តែស្រុកខ្មែរគ្មានលទ្ធភាព ដណ្តើមយកមកវិញ នូវទឹកដីជាច្រើន ដែល សៀម/យួន គេបញ្ចូលទៅក្នុងទឹកដីគេ។ កម្ពុជា ជំនាន់ អាណានិគមបារាំង មិនមែនទុកជា ប្រទេស នៃ បុនវុឌ្ឍិ (ដំណើរមានសកម្មភាពជាថ្មី នៃចំណេះ) តែជា ប្រទេស អភិរក្ស គ្រាន់តែបានរក្សាអ្វីដែលនៅសេះសល់ ដោយមានបារាំងជាអ្នកជួយថែរក្សា។ ចំណេះ វិទ្យាសាស្ត្រ ដែលបារាំងនាំចូលមកក្នុងស្រុកខ្មែរ ជាចំណេះថ្មីមួយពិត តែវាគ្មានអនុភាពមកលើសង្គមខ្មែរ ដែលជាសង្គមជាប្រពៃណី និង ជាអភិរក្ស ព្រោះបារាំង គេមិនបានជួយខ្មែរឲធ្វើកំណែទម្រង់សង្គមនោះឡើយ។  បើយោងតាម សន្ធិសញ្ញា ឆ្នាំ ១៨៦៣, បេសកកម្មបារាំង គឺជាអ្នកការពារ មិនមែនជា អ្នកកំណែទម្រង់ នោះទេ។ រហូតមកដល់ឆ្នាំ ១៨៨៤ បារាំងបង្ខំ ស្តេចនរោត្តម ឲចុះហត្ថលេខា ប្រគល់សិទ្ធិឲបារាំង ត្រួតត្រា រដ្ឋាភិបាលខ្មែរ មួយចំណែកធំ ក្នុងគោលបំណងធ្វើ នវូបនីកម្មរដ្ឋបាលខ្មែរ ដែលនាំឲមានការបះបោលតាមផ្លូវអាវុធប្រឆាំងនឹងអាជ្ញាធម៌បារាំង។



## បញ្ហាវន្តខ្មែរ

និយាយអំពីដំណើរ នៃការចេះដឹងខ្មែរ គួរខ្មែរយើង លើកយកប្រធានបទ ស្តីអំពីបញ្ហាវន្តខ្មែរ មកសិក្សា ដើម្បីឲស្គាល់ដឹង នូវការអនុវត្តន៍ ចំណេះខ្មែរ នៅក្នុងសង្គម។

### តើ ខ្មែរគ្រប់សម័យ ដែលជាមនុស្សលោក មានការផ្លាស់ប្តូរដែរឬ ?

ការវិវត្តរ៍ នៃអារ្យធម៌ និង វប្បធម៌ ជាមាគ៌ា នៃវិវឌ្ឍនៈ របស់មនុស្សលោក និង សង្គមមនុស្ស។  ដូច្នេះ ខ្មែរ ដែលជាមនុស្សលោក ក៏មានការវិវត្តរ៍ ក្នុងចរន្តមនុស្សជាតិ ដូចជាតិសាសន៍ដ៏ទៃទៀត ដែលជាមនុស្សលោក នោះដែរ។

ខ្មែរតែងនិយាយថា ខ្លួនជា ពង្សាវលីខ្មែរអង្គរ ដែលជា ជាតិសាសន៏ ធ្លាប់មានអារ្យធម៌ និង វប្បធម៌ខ្ពង់ខ្ពស់ ជា វេទីជន ចេះគ្រប់វិជ្ជា សំរាប់ធ្វើ មនុស្សរូបនីយកម្ម និង សង្គមរូបនីយកម្ម ដើម្បីបង្កើត បូរិរម្យ សំរាប់ជាតិសាសន៏ខ្លួន។  តែបើយើងធ្វើការសង្កេតលើភាររូប នៃសង្គមខ្មែរបច្ចុប្បន្ន  យើងឃើញថា  ពណ៌នាខាងលើនេះ  ហាក់បីដូចជាគ្មានធាតុពិតណាមួយ អាចបញ្ជាក់ច្បាស់ថា  ខ្មែរអង្គរ  និង  ខ្មែរបច្ចុប្បន្ន  មានពង្សាវលី  តែមួយ  ព្រោះគំនិត  នៃការកសាងប្រជាជាតិ វាមានភាពផ្ទុយគ្នាស្រឡះ។  ភាពនេះបង្ហាញថា ការវិវត្ត នៃអារ្យធម៌ និង វប្បធម៌ខ្មែរ ហាក់បីដូចបានជួបឧបសគ្គអ្វីមួយ កាត់ចរន្តវិវត្តរ៍  អោយដាច់  ពីភាពថ្កុំថ្កើង  នៃខ្មែរអង្គរ។   យើយសួរថា  មូលហេតុអ្វីដែលនាំឲមានការកាត់ផ្តាច់នេះ ?

នៅទីនេះ  យើងមិនលើកយក  មូលហេតុ  កើតមកពីសង្គ្រាម  ឬ  ការរាតត្បាតបរទេសមកធ្វើអត្តាធិប្បាយនោះទេ  ព្រោះមាន  អ្នកប្រាជ្ញបរទេស  និង  ជាតិ  នៃនវិទ្យាច្រើនណាស់ គេបានយកមកធ្វើការសិក្សាច្បាស់លាស់ តាមវិធីវិទ្យាសាស្រ្ត បង្ហាញអំពី ការយល់ឃើញរបស់គេ នៃហេតុផលទាំងនោះរួចមកហើយ។  ការសិក្សាទាំងឡាយនោះបានក្លាយជា គំនិតតែមួយគត់ ហើយជា ចំណេះសាកល មិនអាចអោយខ្មែរដ៏ទៃទៀត អាចមានលទ្ធភាព  បញ្ចេញជា  យោបល់ផ្សេង  ផ្ទុយអំពីការចេះដឹងនេះ តែ  ខ្មែរយើង  ក៏មិនសូវបានយក  ហេតុផលទាំងនោះ  មកធ្វើការពិចារណា  រកការពិត  ឬ  អ្វីដែលជាគំនិតខ្មែរ ដូច្នេះហើយ បានយើងមិនសូវមានប្រតិកម្ម ជាវិជ្ជមានក្តី ជាអវិជ្ជាមានក្តី លើ មូលធនបញ្ញាខ្មែរ  ដែល  អ្នកប្រាជ្ញបរទេស  គេយកមកធ្វើជា  បញ្ញាផ្តាច់មុខរបស់គេ  ជាពិសេសនៅក្នុងផ្នែក វប្បធម៌ និង អារ្យធម៌ខ្មែរ។  ចំណុចនេះហើយ ដែលនាំឲយើងចង់ពិចារណាអំពីបញ្ញាខ្មែរ ដែលជា គ្រឿងយន្ត នៃការចំរើនលូតលាស់ នៃសង្គមខ្មែរ។

# លក្ខខ័ណ្ឌចាត់ទុកជាបញ្ញវន្ត

## លក្ខខ័ណ្ឌណាខ្លះដែលខ្មែរយើងចាត់ទុកជាបញ្ញវន្ត ?

ក្នុងគំនិតខ្មែរសម័យ បញ្ញវន្ត គឺជាជន ដែលបានរៀនសូត្រ ហើយបានទទួលសញ្ញាប័ត្រ ថ្នាក់ឧត្តមសិក្សា។ ក្នុងទស្សនៈនេះ ខ្មែរយើង ឲតម្លៃទៅលើ ការចេះដឹង កើតមានឡើង ពីការសិក្សា ក្នុងមុខវិជ្ជាណាមួយ ហើយត្រូវរដ្ឋ ឬ អង្គការណាមួយ គេទទួលស្គាល់ នូវការចេះដឹង តាមខ្នាតមួយ ដែលគេបង្កើតឡើង សំរាប់ ឲតម្លៃ នៃការចេះដឹងរបស់អ្នកសិក្សា ហើយបើអ្នកសិក្សានោះ បានរៀនសូត្រចេះដឹងក្នុងកំរិត ដែលគេបានធ្វើការកំណត់ថា អាចចាត់ទុកជាអ្នកចេះដឹង គេសម្រេច ប្រគល់សញ្ញាប័ត្រ ដល់ជននោះ ដើម្បីបញ្ជាក់ពីការទទួលស្គាល់របស់គេ។ ទស្សនៈនេះជា ទស្សនៈចង្អៀតមួយ នាំបន្ថយនូវអត្ថន័យនៃពាក្យបញ្ញវន្ត និង អោយមាន ការភាន់ច្រឡំ ក្នុងការប្រើពាក្យបញ្ញវន្ត។

គួរយើងត្រូវដឹងដែរ អំពីការចាត់ថ្នាក់បញ្ញវន្ត នៅបស្ចឹមប្រទេស គេមាន ចែកបញ្ញវន្តជា៤ថ្នាក់៖

ទី១. គឺជា អ្នកនិពន្ធ សិល្បករ(ការី) និងអ្នកប្រាជ្ញ ;

ទី២. គឺជា សាស្ត្រាចារ្យមហាវិទ្យាល័យ អ្នកស្រាវជ្រាវ និងអ្នកនិទ្ទា (សរសេររិះគន់) ;

ទី៣. គឺជា អ្នកសារព័ត៌មាន និង អ្នកសរសេរ ផ្សាយចំណេះណាមួយ ;

ទី៤. គឺជា វិជ្ជបណ្ឌិត វិស្វករ យុត្តិវិទូ(អ្នកច្បាប់) និង បណ្ឌិតផ្នែកមុខវិជ្ជាណាមួយ។

ក្នុងទស្សនៈនេះ គេបែងខ្ញែង ជាគំនិត មូលដ្ឋាន ធំពីរ៖

១. គំនិតឈរលើ ការចេះដឹង នៃចំណេះអ្វីមួយ ដែលអាចបង្ហាញបានភ្លាម នូវភាពស័ក្តិសិទ្ធិ នៃចំណេះនោះ និង គំនិតឈរលើ វប្បធម៌ នៃការចេះដឹង។

២. គំនិតឈរលើ ការយកមកធ្វើតាម នូវចំណេះណាមួយ និង គំនិតឈរលើ ការបង្កើតជាដំបូង នូវគំនិត ឬ វត្ថុអ្វីមួយ។

បើយើងយកទស្សនៈ បស្ចឹមប្រទេស មកប្រៀបនឹងគំនិតខ្មែរ យើងឃើញថាគំនិតនេះ មានមួយផ្នែកក្នុងគំនិតខ្មែរដែរ ដូចជា គំនិតឈរលើ «ភាពស័ក្តិសិទ្ធិ» (ក្នុងគំនិតទី១) និងគំនិតឈរលើ «ការយកមកធ្វើតាម» (ក្នុងគំនិតទី២)។ ក្នុងគំនិតទី១ ខ្មែរតែងឲតម្លៃទៅលើអ្នកចេះដឹង នៅពេលណាឃើញថា ចំណេះអ្នកចេះដឹងនោះ មានភាពស័ក្តិសិទ្ធិ គឺអាចទាញយកជា ប្រយោជន៍បានភ្លាមៗ សំរាប់ការរស់នៅក្នុងជីវិត ដូចខ្មែរតែងតែយល់ឃើញថា បើចេះទាល់តែមានបុណ្យស័ក្តិ និងលុយកាក់ ទើបទុកជា អ្នកចេះ

ហើយមួយទៀតបើចេះ ទាល់តែចេះសូត្ររត់មាត់តាមគ្រូ ដូចខ្មែរយើងតែងនិយាយថា រៀនសូត្រនោះឯង។

ក្នុងគំនិតនេះ បង្ហាញថា ខ្មែរយើងមិនសូវឲតម្លៃ លើគោលការវប្បធម៌ និងលើ គោលការបង្កើតនូវគំនិត ឬការរកឃើងអ្វីមួយថ្មី សំរាប់សង្គម ព្រោះថា វប្បធម៌ ជាវត្ថុអរូបី ឯចំណែកអ្វីថ្មី ជាការជំទាស់នឹងបរវេណី និង ទំនៀមទម្លាប់។ ទស្សនះនេះ ជាច្បាប់រស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្គមអភិរក្ស មានចែកជាវណ្ណៈពីកំណើត គឺពួកមាន ត្រកូលជាអ្នកធំ ជាម្ចាស់ និងពួកមានវណ្ណៈជា អ្នកតូច ជាឈ្នួល។ វណ្ណៈទាំងពីរនេះ មានព្រំដែនជិតស្លុង មិនអាចឆ្លងកាត់បានពីវណ្ណៈមួយទៅវណ្ណៈមួយ។ ហេតុនេះឯងបានជា ខ្មែរយល់ឃើញថា អ្នកចេះកើតក្នុងត្រកូលតូច គឺនៅតែតូចដដែល លុះត្រាតែជននោះមានភ័ព្វសំណាងពិសេស ក្លាយទៅជាអ្នកមានយសស័ក្តិ ទើបគេទទួលស្គាល់ចំណេះដែលខ្លួនមាននោះ។

ក្នុងទស្សនៈដែលបានរៀបរាប់ខាងលើនេះ យើងសង្កេតឃើញពិតថា នៅក្នុងសង្គមខ្មែរគេពុំឲតម្លៃទៅលើអ្នកនិពន្ធ សិល្បករ(ការិ) អ្នកនិន្ទា អ្នកសារព័ត៌មាន ព្រោះជាពួកមនុស្សរស់នៅក្នុងលោកអរូបី បង្កើតតែគំនិតឥតបានការ សំរាប់តែបំរើ មនោសញ្ចេតនាអ្នកដ៏ទៃ ចេះអត់ប្រយោជន៍ សំរាប់ការរស់នៅរបស់ខ្លួន។ ពួកទាំងនោះច្រើនតែជាមនុស្សក្រលំបាក គ្មានយសស័ក្តិ កើតក្នុងត្រកូលតូច គេទុកជាជនកំប៉ិកកំប៉ុកខ្មែរយើងច្រើនហៅពួកមនុស្សបែបនេះថា «អានេះ អានោះ» ដូចគេនាំគ្នាហៅ លោក ស៊ិន ស៊ីសាមុត អ្នកចំរៀងដ៏ឆ្នើម «អា ស៊ីនស៊ីសាមុត» នោះឯង។ យើងដឹងថា ក្នុងសង្គមសក្តិភូមិខ្មែរ អ្នកកើតក្នុងត្រកូលធំ តែងតែហៅជន ដែលកើតក្នុងត្រកូលតូច ទោះបីអ្នកនោះមានអាយុច្រើនជាងក៏ដោយ ថា «អានេះអានោះ» ជានិច្ច។

ដោយយោងលើគំនិត ភាពស័ក្តិសិទ្ធិ នៃចំណេះសំរាប់ការរស់នៅ យើងសង្កេតឃើញថា យុវជនខ្មែរ ចូលចិត្តរៀន វិស័យវិទ្យាសាស្ត្រ និងបច្ចេកទេស។ ចំនួនយុវជន មានតិចតួចណាស់ ដែលបានជ្រើសរើស នរវិទ្យា ទស្សនវិជ្ជា ព្រោះវិជ្ជាទាំងនេះ គេទុកវាគ្មានស័ក្តិសិទ្ធិ សំរាប់ការរស់នៅ ហើយពិបាករកការងារធ្វើផង។

### ងារ ជាបញ្ញវន្ត

បញ្ញវន្តមិនមែនជាងារដែលជនម្នាក់ៗ អាចតាំងខ្លួនឯងបាននោះឡើយ។ ជនបែបនេះ ក្នុងពាក្យខ្មែរគេហៅ «បណ្ឌិតមានះ»។ ការប្រកាស់ថាខ្លួនជាបញ្ញវន្ត គឺជា មានះរបស់អ្នកល្ងង់ ដែលលើកខ្លួនដោយខ្លួនឯង ថាខ្លួនជាឧត្តមជន។

ងារជាបញ្ញវន្តជាងារ ដែលមិតិសាធារណៈ តាំងឲជនណាមួយ ដែលមាន សកម្មភាពយ៉ាងខ្ចីឃ្នាត ក្នុងផ្នែកគំនិត ប្រកបដោយគុណធម៌ សំរាប់ប្រយោជន៍សង្គម និង

ប្រយោជន៍ នៃមនុស្សជាតិ។ ចរិតលក្ខណៈ នៃបញ្ញវន្ត គឺឋិតនៅលើអ្វី ដែលជា គំនិតបណ្ឌិតការពារសេចក្តីថ្លៃថ្នូរ របស់មនុស្សជាតិ។

គេមានវិធីពីរ សំរាប់ទទួលស្គាល់ងារជា បញ្ញវន្ត

ទី១ គឺ វិធីតាមការចូលរួមក្នុងសកម្មភាព ដែលគេទុកថា មានលក្ខណៈជា សកម្មភាពមានតម្លៃ ក្នុងផ្នែកបញ្ញា (Mode d'affiliation)។

ទី២ គឺ វិធីដែលមានក្នុងតម្លៃផ្ទាល់ទៅលើបុគ្គលម្នាក់ ដែលទុកស្រេចថាគាត់ជាបញ្ញវន្ត ព្រោះមនុស្សនោះ មានចរិតជាសុជន មានចំណេះជាបណ្ឌិត ដែលគេមើលឃើញជាក់ស្តែង ឥតអាចប្រកែកបាន (Mode de légitimation)។

ខ្មែរបុរាណមាន ពាក្យមួយស្របទៅលើ គុណភាព នៃបញ្ញវន្តគឺ «បណ្ឌិត»។ បណ្ឌិតគឺជាអ្នកចេះដឹង ហើយ បានធ្វើអ្វីមួយ ក្នុងគុណធម៌។ ដូច្នេះខ្លឹមសារ នៃ ងារបញ្ញវន្ត គឺផ្អែកលើគោលការណ៍ពីរ «សកម្មភាព និង គំនិត ក្នុងគុណធម៌»។ តែគេមិនទុក បញ្ញវន្ត ជា «គន្ធរចនាចារ្យ» (Moraliste) នោះដែរ ព្រោះបញ្ញវន្ត មិនមែនជាអ្នក ធ្វើការទូន្មានប្រៀនប្រដៅ ដល់ជនដ៏ទៃ ដូចពួកបុព្វជិត ឬភិក្ខុសង្ឃ នោះឡើយ។ អ្វីជាបណ្ឌិតគឺបានធ្វើអ្វីមួយ ដោយឥតយកគំនិត រកប្រយោជន៍ ហើយតម្រូវឲ្យអ្នកដ៏ទៃធ្វើតាមខ្លួន។ បណ្ឌិត ជាបញ្ញវន្ត មានមុខងារសំខាន់បីយ៉ាងៈ ផលិត នៃការចេះដឹង ; ផលិត នៃជំនាញការ និង ជាអ្នកផ្សាយ នូវការចេះដឹង ដល់សាធារណៈជន។

### សួរថាតើក្នុងសង្គមខ្មែរគ្រប់សម័យមានបញ្ញវន្តដែរឬទេ ?

ក្នុងសម័យបុរាណ សង្គមខ្មែរច្បាស់ជាមានបញ្ញវន្ត ដែលមានងារជាបណ្ឌិត។ បណ្ឌិតជាជនមានប្រាជ្ញា ជនអ្នកប្រព្រឹត្តល្អ គឺអ្នកកាន់សុចរិតដោយពិស្តា ដោយខ្ជាប់ខ្ជួនហ្មត់ចត់ជានិច្ច គឺជាអ្នកប្រាជ្ញ ខាងផ្លូវ សុចរិតយុត្តិធម៌។ ក្នុងសម័យ ពុទ្ធសាសនា បណ្ឌិតជាអ្នកបួស ព្រោះអ្នកបួស មានការចេះដឹង មានចរិយាមារយាទត្រឹមត្រូវ។ រួចក្រោយមក ពាក្យបណ្ឌិតនេះ ហៅក្លាយជា «បន្ទិត» ហើយឃ្លាយមកទៀតជា «អន្ទិត»។ សម័យទំនើប គេហៅ អ្នកមានវិជ្ជាថ្នាក់ខ្ពស់ ដែលមានសញ្ញាបត្រ «ដុកតូរ៉ាត» ថា បណ្ឌិត ក្នុងមុខវិជ្ជាអ្វីៗមួយ។ (ដកស្រង់ពីវចនានុក្រមខ្មែរ សម្តេចជួនណាតជោតញ្ញាណោ បោះពុម្ពគ្រាទី៥ក្នុងឆ្នាំ១៩៦៧ ត្រូវនឹងព.ស.២៥១១)។

ការក្លាយឃ្លាតពាក្យបណ្ឌិត មកអន្ទិត ជាការក្លាយថយចុះនូវគុណសម្បត្តិ នៃបណ្ឌិត។ ការក្លាយនេះ ជាសញ្ញា នៃភាពអត្តង្គត នៃសង្គមខ្មែរ។ បណ្ឌិតដែលមានភារៈជា ឧត្តមជន ដែលជាជនឯករាជ្យ ផ្សាយគំនិតខ្ពង់ខ្ពស់ សំរាប់ជាយាន នៃការចំរើន នៃសង្គម បានក្លាយឃ្លាតត្រឹមតែជា សុជន (មនុស្សល្អ) ចេះធម៌ សំរាប់តែធ្វើជា អាចារ្យវត្ត ឬ ពិធិ

ការ តែប៉ុណ្ណោះ។ ការក្លាយនេះជា ការក្លាយឃ្លាតពី «ថាមវិន្តភាព» ទៅ «និច្ចលភាព» ឬ ពីអ្វីដែលមាន រូបភាពជា «សកម្មភាព» ទៅរកអ្វីដែលមាន រូបភាព «អភិរក្សនិយម»។

យើងនិយាយនេះ គ្មានបំណងចង់រិះគន់ព្រះពុទ្ធសាសនានោះឡើយ យើងមានជំនឿជានិច្ចថា ព្រះពុទ្ធសាសនា មានប្រយោជន៍ណាស់សំរាប់សង្គមជាតិ ព្រោះជាសាសនា នាំរំងាប់ នូវអ្វីដែលជា ធាតុ នៃទុក្ខ របស់មនុស្សលោក តែធម៌សាសនាម្នាក់ឯង ពុំអាចឲមនុស្សលោក រកឃើញ នូវអ្វិដែលជាខ្លឹមសារ នៃសុភមង្គល ក្នុងធាតុខ្លួនជាសត្វលោក ដែលជា ធាតុចាំបាច់ សំរាប់ជីវិតជា សត្វលោក គឺមាន ឃ្លាន និង ចង់សុខក្សេមក្សាន្ត។ ធម៌សាសនាជា យោងនៃមនុស្សធម៌ ឯចំណែក វប្បធម៌ជា យាននៃការចំរើនរបស់មនុស្សលោក។ យានទាំងពីរ ត្រូវការយោងគ្នាទៅវិញទៅមក ដើម្បីធ្វើអភិវឌ្ឍន៍ នៃសង្គមមនុស្សក្នុងគន្លងធម៌។

## នរណាទៅជាបណ្ឌិតនៅស្រុកខ្មែរ ?

ក្នុងសម័យព្រហ្មញ្ញសាស្នា បណ្ឌិតមាននៅក្នុងពួកព្រាហ្មណ៍ ដែលជាវណ្ណៈទី១ ក្នុងចំណោមវណ្ណៈទាំងបួន នៃលទ្ធិព្រាហ្មណ៍។ វណ្ណៈទាំងនោះមាន៖ ទី១. ព្រាហ្មណ៍ ទី២. ក្សត្រិយៈ ទី៣. វេស្សៈ ទី៤. សូទ្រៈ។

ព្រាហ្មណ៍ជាបណ្ឌិត ជាគ្រូរអាចារ្យថ្នាក់ឧត្តម នៃមហាវិទ្យាល័យ បង្ហាត់បង្រៀន វិជ្ជាផ្សេងៗដល់យុវជន ដែលមានវណ្ណៈជាព្រាហ្មណៈ និង ក្សត្រិយៈ ; ជាពិសេសជា វរៈគ្រូរ របស់ព្រះមហាក្សត្យ បង្ហាត់បង្រៀនវិជ្ជា មនុស្សសាស្ត្រ នយោបាយ យុទ្ធសាស្ត្រ និងគ្រប់មុខវិជ្ជាឯទៀត សំរាប់ធ្វើការដឹកនាំប្រទេសជាតិ។ ពួកព្រាហ្មណ៍ ក៏ជា អ្នកសិក្សាស្រាវជ្រាវ និង បង្កើតវប្បធម៌ និងគ្រប់ច្បាប់រដ្ឋ សំរាប់រាជការ និង ប្រជារាស្ត្រ។ ព្រាហ្មណ៍បណ្ឌិតចូលរួមយ៉ាងសកម្មក្នុងកិច្ចការលោកកិយ កិច្ចការប្រាជ្ញា ក៏ដូចជា កិច្ចការសាសនាក្នុងព្រះរាជអាណាចក្រ ជា នាដការ មានចេស្តា ក្នុងសង្គមខ្មែរ។

មកដល់ពោធិសម័យ ចេស្តាព្រាហ្មបណ្ឌិត មានការអន់ថយក្រៃលែង។ ក្នុងតួនាទីជាបណ្ឌិត ត្រូវគេផ្លាស់យក ពួកភិក្ខុសង្ឃ មកដើរតួជំនួស។ ការផ្លាស់បន្ទុកនេះ កើតមកពីការផ្លាស់ជំនឿសាសនា របស់ព្រះមហាក្សត្រ។ ជាការផ្លាស់ប្តូរ នាំឲមាន ការកែប្រែជាខ្លឹមសារ នៃអត្ថន័យ នៃតួនាទី របស់បណ្ឌិត។ គោលការណ៍ និង គោលដៅ របស់រាជអំណាច ក្នុងពោធិសម័យ គឺចង់ធ្វើ ប្រជាធិតេយ្យបនីយកម្ម ក្នុងវិស័យសិក្សាធិការជាតិ ដោយបន្ថយ ឯកាធិភាព ពួកព្រាហ្មណ៍ ក្នុងវិស័យនេះ។ អំពើនេះ គឺជាការធ្វើបដិវត្តន៍វប្បធម៌មួយក្នុងជំនាន់នោះ។

ព្រះមហាក្សត្រ ដែលបានធ្វើអំពើនេះ មានប្រជាប្រិយភាពក្រៃលែង ដូចយ៉ាង ព្រះបាទជ័យវរ្ម័នទី៧។ ភិក្ខុសង្ឃណា ដែលមានចំណេះជ្រៅជ្រិះក្នុងធម៌ព្រះពុទ្ធ ត្រូវគេទទួលស្គាល់

ថាជាបណ្ឌិត ស្មើមុខនឹងព្រាហ្មណ៍បណ្ឌិត នាំឲពួកទាំងនោះមានការអាក់អន់ចិត្តក្រាស ក្រែង ហើយពួកព្រាហ្មណ៍បណ្ឌិត ដែលជាគ្រូអាចារ្យធំៗ និង ជាបាគូរ នាំគ្នារត់ចេញពីស្រុកខ្មែរ ដោយនាំយកទៅជាមួយពួកគាត់ នូវគម្ពីធម៌ និងយុទ្ធសាស្ត្រនយោបាយសំខាន់ៗ ជាច្រើន(សូមអានរឿង តាត្រសក់ផ្អែម ក្នុងឯកសារ «មហាបុរសខ្មែរ» ស្រាវជ្រាវដោយលោក អេង សុត)។

ដល់មកដល់សម័យទំនើប ខ្មែរយើងទុកអ្នកមានសញ្ញាប័ត្រមហាវិទ្យាល័យជា បញ្ញវ័ន្ត។ ការសំគាល់តាមលក្ខណ:នេះ នាំឲមានការផ្លាស់អត្ថន័យ នៃបញ្ញវន្ត ពី «អ្នកធ្វើជីវិត នៃគំនិតប្រាជ្ញា អោយមានដង្ហើមជាអចិន្ត្រៃ» ក្នុងសង្គម មកត្រឹមតែជា «អ្នកចេះដឹងនៃមុខវិជ្ជាវិទ្យាសាស្ត្រអ្វីមួយតែប៉ុណ្ណោះ»។ ក្រៅពីនេះទៅទៀត អត្ថន័យ នៃបញ្ញវន្ត បានក្លាយទៅជាឋានៈ ឬ វណ្ណៈថ្មីមួយ នៅក្នុងសង្គមខ្មែរ។ បញ្ញវន្ត បំពាក់ដោយសញ្ញាប័ត្រ តាំងខ្លួនជាលោកធំ រស់លើភាពល្ងង់ខ្លៅ របស់អ្នកតូច ដែលជារាស្ត្រសាមញ្ញ ដោយទុកខ្លួនជាឧត្តមជន ឬ ឯកឧត្តម។ ពាក្យចេះបែបនេះ នាំបែរ គំនិតថ្មី នៃបញ្ញវន្ត ដូចលោក ប៉ុន ចន្ទម៉ុល និយាយថា «គំនិតមានតែអញ» ឬ «អញនិយម»។ ចេះមុខវិជ្ជាណាមួយ មិនមែនមានសេចក្តីថា ខ្លួនចេះអ្វីៗគ្រប់បែបយ៉ាង លើសអ្នកដ៏ទៃនោះឡើយ។

## មរតក នៃបញ្ញាខ្មែរ

បុព្វបុព្វបុរសខ្មែរបានទុក «មរតក នៃបញ្ញា» ច្រើនឥតគតនា ដល់កូនខ្មែរ។ មរតកនោះ មានគ្រប់ផ្នែក ដូចជាអក្សរសាស្ត្រ អក្សរសិល្ប៍ ក្បួនច្បាប់គ្រប់បែបយ៉ាង សំរាប់កូនខ្មែរសម័យក្រោយ យកវាមកធ្វើការពិចារណា ក្នុងការរស់នៅជារៀងរាល់ថ្ងៃរបស់ខ្លួន និង សំរាប់អានទុកជាការកំសាន្តអារម្មណ៍។ នៅចំពោះស្នាដៃដែលប្រកបទៅដោយគុណភាព នៃបញ្ញា នៃបុព្វបុរសខ្មែរដ៏ច្រើននោះ យើងជាកូនខ្មែរជំនាន់ក្រោយ ហាក់បីមានភាពជាកុមារមួយ រស់ក្នុងភាពងងឹតងងល់ លើគំនរសម្បត្តិ នៃវប្បធម៌ជាតិ។ ពេលណាខ្មែរយើង ស្គាល់តម្លៃ មរតកនៃបញ្ញា ដែលមាននៅក្នុងវប្បធម៌ជាតិយើង ច្បាស់ជានឹកយល់ដឹងអំពី តម្លៃសាសន៍ជាតិខ្លួន ក្នុងចំណោម សាសន៍ជាតិដ៏ទៃទៀត មាននៅក្នុងសង្គម នៃមនុស្សជាតិ។

ខ្មែរពិតមែនតែមាន បេតិភ័ណ្ឌជាតិ ប្រកបទៅដោយកិត្តិនាមជាច្រើន តែជាប្រជាជាតិមួយ ធ្លាក់ខ្លួនខ្ញុំគេអស់ច្រើនសតវត្ស។ ថ្មីៗនេះ ស្រុកខ្មែរធ្លាក់ក្នុង អាណានិគមយួន (១៩៧៩-១៩៨៩) ដែលជាការរលំជាតិមួយ ហួសនូវការនឹកស្មានរបស់ខ្មែរម្នាក់ៗ។ តើជាកំហុសនរណា ? ឬក៏ជា កម្មវាសនា គេចមិនផុតរបស់ជាតិខ្មែរ ? មោទនភាពខ្មែរបាត់សាបសូន្យ ធ្វើឲខ្មែររស់នៅតែក្នុងស្រមោល នៃភាពរុងរឿងពីអតីតកាល និង ការ

ចងគំនុំ ឬ ការតូចចិត្ត លើវាសនារបស់ខ្លួន។ វិនាសកម្មថ្មីៗនេះ នាំបន្ថែមឲវប្បធម៌ និង អារ្យធម៌ខ្មែរ រិតតែចុះអន់ខ្សោយបន្តទៅទៀត។ តែហាក់បីដូចជាគ្មាន នរណាជាអ្នកទទួលខុសត្រូវ នូវទុព្វពលភាពជាប្រវត្តិសាស្ត្រ នេះឡើយ ?

តែយើងត្រូវយល់ដឹងដែរថា មរតក នៃវប្បធម៌ខ្មែរ មិនសុទ្ធតែ គំនិតវិជ្ជមាន សំរាប់ការរស់នៅរបស់ខ្មែរ នៅក្នុងសម័យថ្មីដែរ ដូច្នេះ ត្រូវចាំបាច់យក មរតកនេះ មកពិចារណា ដើម្បីអោយដឹងថាអ្វីជា គុណភាព និង គុណវិបត្តិ សំរាប់សង្គមសម័យ។

លោក វ៉ាន់ ឌី កាអុន បញ្ញវន្តខ្មែរមួយរូប បានលើកយកមកធ្វើការពិចារណាឡើងវិញ នូវគំនិតបុរាណខ្លះៗ ដែលជាគំនិត សំរាប់កាច់បំបាក់ចិត្តគំនិតខ្មែរទុនខ្សោយ ឲរស់នៅក្នុងផ្នត់គំនិត ជាអ្នកចេះគោរពអ្នកមានអំណាច ឬ អ្នកប្រាជ្ញ។ អ្នកខ្លាំងទាំងនោះ នាំគ្នាតាក់តែងមេរៀនចរិយាសាស្ត្រ ឬ ដំបូន្មានផ្សេងៗ ដោយខ្លួនឯង សំរាប់ប្រយោជន៍ខ្លួនឯង។ ឧទាហរណ៍ មានដូចតទៅៈ

ចូលស្ទឹងតាមបទ ចូលស្រុកតាមប្រទេស ; ខ្លួនទាបកុំតោង ដៃខ្លីកុំយោងស្រវាឪបភ្នំ ; នំមិនធំជាងនាឡិ ។ ល។

ក្នុងសង្គមកំពុងចុះអន់ខ្សោយក្នុងផ្នែកគំនិត តម្រូវឲបញ្ញវន្ត មានភារកិច្ច យកគំនិតចាញ់គេដើបមុខមិនរួច មកធ្វើការពិចារណាឡើងវិញ ដើម្បីប្រឌិតគំនិតថ្មី សំរាប់រកភាពប្រសើ ដើម្បីជាតិខ្លួន។

បើខ្មែរណាបានអានសៀវភៅ លោក ឃីន ហុកឌី (អក្សរសាស្ត្រខ្មែរ) ច្បាស់ជាធ្វើឲអ្នកអាននោះ មានមោទនភាព លើភោគទ្រព្យ នៃវប្បធម៌ខ្មែរ។ តែភោគទ្រព្យ នាបច្ចុប្បន្ននេះ វាស្ថិតនៅតែក្នុងសារមន្ទីរ នៅតែក្នុងសៀវភៅ និងនៅក្នុងតែគំនិតអ្នកចេះដឹងខ្មែរមួយចំនួនតូច វារហូតក្លាយទៅជាស្រមោល គ្មានសារៈប្រយោជន៍អ្វីសោះ សំរាប់ការរស់នៅរបស់ខ្មែរ។ ជាពិសេសទៅទៀត ដូចជំរាបខាងលើរួចមកហើយ ខ្មែរយើងមានទម្លាប់ទុកគំនិត នៃវប្បធម៌ជាវត្ថុអរូប ជាវត្ថុបន្ទាប់បន្សំ សំរាប់ជាតិ ដូច្នេះ ភោគទ្រព្យនៃវប្បធម៌ ដែលជាមរតកជាតិខ្មែរ វាគ្មានតម្លៃជាប្រយោជន៍ជាតិ ក្រៅតែជាតម្លៃនិមិត្តរូប នៅក្នុងចិត្តគំនិតខ្មែរ។

ក្នុងកំឡុងឆ្នាំ១៨៩០ ពេលដែលបារាំងត្រួតខ្មែរដាច់មុខ គេឥតសូវយកចិត្តទុកដាក់ធ្វើការស្រាវជ្រាវក្នុងផ្នែកអក្សរសាស្ត្រនោះប៉ុន្មានទេ។ ក្នុងចំណុចនេះ លោក ឃីន ហុកឌី សរសេរក្នុងសៀវភៅថា៖ «អ្នកប្រាជ្ញបារាំង គេមិនបានធ្វើការស្រាវជ្រាវអ្វីបានច្រើន លើវិស័យអក្សរសាស្ត្រខ្មែរព្រោះវិស័យនេះ មានទំហំធំវែងអន្លាយពេក ធ្វើអោយអ្នកស្រាវជ្រាវបរទេសអស់សង្ឃឹម ព្រោះដើម្បីអាចសិក្សាអក្សរសាស្ត្របាន គឺត្រូវរៀនភាសាខ្មែរឲមានចំណេះខ្ពង់ខ្ពស់ទើបយល់អត្ថបទទាំងនោះ»។

ក្នុងផ្នត់គំនិតនេះ ខ្ញុំមិនសូវជាយល់ស្របទាំងស្រុង ប៉ុន្មានទេ តាមយោបលខ្ញុំ មាន ត្រូវ មាន ខុស ព្រោះបារាំងជាចៅហ្វាយខ្មែរដាច់មុខជិតមួយសតវត្ស បើចង់យកផ្នែកអក្សរសាស្ត្រ មកធ្វើជាកម្មវិធីសិក្សា ច្បាស់ជាគេខ្វះខ្នែងបង្ហាត់បង្រៀនខ្មែរ ជាបឋមឲចេះរបៀបរៀបចំ កម្មវិធីសិក្សាអក្សរសាស្ត្រ តាមរបៀបវិទ្យាសាស្ត្រ ដើម្បីធ្វើជាសហការីក្នុងកម្មវិធីសិក្សា ឬ ជួយជម្រុញ អ្នកប្រាជ្ញខ្មែរក្នុងកម្មវិធីសិក្សានេះមានលទ្ធភាពធ្វើបាន។ បើបារាំង គេចង់ជួយខ្មែរ គឺប្រាកដ ជាគេអាចធ្វើបានជាពុំខាន ក្នុងឋានៈគេជាចៅហ្វាយខ្មែរទាំង វិស័យេ របៀបគ្រួតត្រា អប់រំជាតិ និងការរៀបចំ នៃជីវិតរស់នៅ។ យើងគួរដឹងដែរថា គ្រាន់តែបោះពុម្ពឯកសារ ប្រវត្តិសាស្ត្រខ្មែរក្រោយសម័យអង្គរ រចនាឡើងដោយ ឧកញ្ញាវាំងជួន ក៏ស្ដេចខ្មែរជំនាន់នោះ ត្រូវចាំបាច់សុំអនុញ្ញាតពីបារាំងដែរ។ និយាយថាភាសារជា រនាំង គឺ ទុកដូចជា អ្នកធំបង្គាប់ឲអ្នកតូចមានអំណគុណដល់លោកធំ ព្រោះយល់ថា៖ «លោកធំ លោករវល់ណាស់ បានជាមិនបានធ្វើ ដូច្នេះកុំអន់ចិត្តនឹងលោកធ្វើអ្វី»។

## បញ្ញវន្តខ្មែរ ពីសម័យអាណានិគម រហូតដល់ សម័យឯករាជ្យជាតិ

ក្នុងសម័យក្រោយអង្គរ (ពីស.ត.ទី១៥ ដល់ ស.ត.ទី១៨) ស្រុកខ្មែរបានធ្លាក់ក្នុងអត្ថង្គត ហើយអត្ថង្គតនេះ បានបផ្លាញប្រព័ន្ធនៃគំនិតបញ្ញាខ្មែរ នាំឲ សង្គមជាតិរស់ខ្វះអាហារសតិ។ ផលវិបាកជាក់ស្ដែង គឺការភ្លេច ប្រវត្តិសាស្ត្រជាតិ អស់រយៈពេលជាងបីសតវត្ស។ ក្នុងរយៈពេលនោះ ជាតិខ្មែររស់ក្នុងឥទ្ធិពលប្រទេសជិតខាង គ្រប់វិស័យ។ អ្វីដែលឆ្ងាញ់ អ្វិដែលល្អ ខ្មែរតែងតែតែនិយាយថា ជារបស់សៀម ឬ យួនជានិច្ច ឧទាហរណ៍៖ សម្លម្ជូយួន នឹង ចំណីសៀម។ ល។ គំនិត ចៀមជាំដោយមិនដឹងខ្លួននេះ វារស់នៅក្នុងសតិខ្មែរច្រើនសតវត្ស នាំឲខ្មែរបាត់សេចក្ដីទុកចិត្តលើខ្លួនឯង ហើយដូរចរិយាសម្បត្តិ ពីជនខ្ញីឃ្លាត ទៅជា ជនក្រអែស ក្នុងកិច្ចការសាធារណៈ។ ឧទាហរណ៍ៈក្នុងពាក្យពេជ្យអស់សង្ឃឹមមួយនិយាយថា៖«ខ្លួនមួយមិនអាចទូលផែនដីម្នាក់ឯងបានទេ»

ក្នុងគំនិតនេះ បើកឱកាសឲបរទេស គេយកទឹកដីខ្មែរដោយមិនចាំបាច់ខំប្រឹងអ្វីច្រើននោះឡើយ ព្រោះគេយល់ថា ផ្លែឈើដល់ទុំស្អុយរលួយ គង់តែវាជ្រុះខ្លួនឯង។ នៅក្នុងគំនិតបរាជ័យនិយម មាននៅក្នុងគំនិតខ្មែរ វាក្លាយជាពុម្ព នៃការអប់រំ របស់ខ្មែរ។ ជនជាតិមួយ ខ្វះសេចក្ដីសង្ឃឹមក្នុងគំនិតទៅលើអនាគតរបស់ខ្លួន គឺជាជាតិរស់ចាំតែស្លាប់តែប៉ុណ្ណោះ។ កង្វះនេះ នាំឲយើងសួរជាសំណួរថា តើជាភាពបង្ហាញ នូវ «ភារៈមិនល្អជាទូទៅ នៃមនុស្ស របស់ខ្មែរនោះឬ ? ឬ ជា កម្មពៀរព្រហ្មលិខិត របស់ជនជាតិខ្មែរដែលខ្មែរយើងតែងតែនិយាយលេងប្រឡំ មែនថា៖ «ខ្លួនជាជាតិមានកម្ម» បានជាស្រុកខ្មែរមានឈ្មោះថា «កម្មពូជជា» ដែលក្លាយជាពាក្យ «កម្ពុជា»។ ក្នុងកំឡុងជាងបីសតវត្ស ជនជាតិខ្មែរ មិនត្រឹមតែបាត់ជំនឿលើខ្លួនឯងតែប៉ុណ្ណោះទេ គឺខ្មែរបាត់ថែមទៀត

នូវអ្វីដែលជា ចក្ខុនិមិតលើរូបភាព ទាំងមូល នៃប្រជាជាតិ របស់ខ្លួន ដោយហេតុនេះ ខ្មែរមើលឃើញរូបភាពស្រុកនៅក្នុងសម័យនោះ ត្រឹមតែស្រុក របស់ស្ដេច ឬ លោកម្ចាស់ ឬ មួយត្រឹមតែជាវត្ថុអ្វី ដែលមានកម្មសិទ្ធិករ តែប៉ុណ្ណោះ។

ជនជាតិខ្មែរ ក្រោយពីបានរស់នៅអស់ច្រើនសតវត្ស ក្នុងបរាជ័យនិយម គ្រប់ប្រការមក ហើយដល់មកចុងសតវត្សទី១៩ មានរស្មីដោគមួយ សើចរកខ្មែរ គឺ «អាណាព្យាបាលបារាំង» នេះឯង។ តែខ្មែរយើងអាចចោទសួរជាសំនួរថា សន្ធិសញ្ញាអាណាព្យាបាលនេះ (១៨៦៣) តើពិតជា រនាំងទប់ មហិច្ឆិតា នៃវិត្ថារកម្មទឹកដី របស់ប្រទេសជិតខាងមកលើស្រុកខ្មែរបានដែរឬទេ ?

ការបើកទំព័រថ្មីនេះ វាគ្រាន់តែជា «លាភ» សំរាប់ខ្មែរ ដូច្នេះ សន្ធិសញ្ញាអាណាព្យាលបារាំងនេះ វាជា ធាតុវិជ្ជមានផង អវិជ្ជមានផង ដូច្នេះស្ថាភាពនេះ តើវាមានអនុភាពអ្វីខ្លះដែរទៅលើគំនិតនៃបញ្ញវន្តខ្មែរ ?

## ១.គំនិតថ្មីនៃបញ្ញវន្តខ្មែរ

ការជួបប្រទះជាដំបូងរបស់ជាជាតិខ្មែរ ជាមួយនឹង វប្បធម៌ នៃបស្ចឹមប្រទេស វាគ្មាននាំមកនូវគំនិតអ្វី ដែលបស្ចឹមប្រទេសគេទុកជា តម្លៃសជ្ឈនិកៈ របស់សង្គមគេ គឺ «សេរីភាព» និង «សទ្ធិមនុស្ស»។ ត្រូវយើងដឹងថា សទ្ធិសញ្ញាអាណាព្យាបាលបារាំង វាមានធាតុជានយោបាយ និង យោធា ហើយក្នុងនោះ គ្មាននិយាយអ្វីអំពីគំនិតមនុស្សជាតិនោះឡើយ។ ហត្ថលេខីទាំងពីរ គ្មានសមភាព នៃកម្លាំងនោះឡើយ។ ជាសទ្ធិសញ្ញា រវាងអ្នកខ្លាំង ជាមួយនឹង អ្នកខ្សោយ ដែលអាចឲអ្នកខ្លាំង គេទាញបានផលប្រយោជន៏ ពីអ្នកខ្សោយ បានងាយស្រួល។ តែទោះបីមានសភាពការណ៏ អសមភាព បែបនេះក៏ដោយ ក៏អាចឲខ្មែរទាញយកប្រយោជន៏បាន ពីរយ៉ាងដែរ គឺៈ ការពារបូរណទឹកដីខ្មែរ ផ្នែកខាងលិច និង ការកាត់បន្ថយឥទ្ធិពលសៀម មកលើមហាក្សត្រខ្មែរ។ អ្វីៗឯទៀតគឺគ្រាន់តែជាគ្រឿងតុបតែងលំអរផ្ទះខ្មែរតែប៉ុណ្ណោះ។ សទ្ធិសញ្ញាអាណាព្យាបាលបារាំងនេះ យើងអាចចាត់ទុកវាជា «អំពើអវិជ្ជមាន ចាំបាច់មួយ» សំរាប់សង្គ្រោះជាតិខ្មែរ ឲគេចផុតបានពី វិនាសកម្ម កំណត់ដោយកម្មវាសនាជាតិខ្មែរ ក្នុងសតវត្សទី១៩ គឺឥទ្ធិពល ប្រទេស សៀម និង យួន មកលើស្រុកខ្មែរ រហូតគេនាំគ្នាចែកដីខ្មែរ ដោយយកទន្លេមេកុង ជាព្រំដែនធម្មជាតិ។

អស់រយៈ៩០ឆ្នាំ (១៨៦៣-១៩៥៣) ស្រុកខ្មែរ រស់នៅក្រោម របបអាណានិគមបារាំង ដែលជារបប មានទិសនយោបាយច្បាស់លាស់ សំរាប់អនុវត្តន៏ ផែនការ អាណានិគម ក្នុងគោលគំនិត លោក Jules Ferry (១៨៣២-១៨៩៣) ជាបញ្ញវន្ត នាយករដ្ឋមន្ត្រី សំភី ក្នុងនយោបាយអាណានិគម ដោយប្រើទស្សនៈ «បេសកកម្ម អារ្យធម៌បនីយកម្ម នៃបស្ចឹ

មប្រទេស»។ ទស្សនៈនេះ ជាមូលដ្ឋាន នៃការបង្កើត រូបីបញ្ញាថ្មីរបស់ខ្មែរ ក្នុងនោះ មានវិទ្យាស្សង្ស ជាសេចក្តីសំអាង នូវឧត្តមភាពរបស់អ្នកអាណានិគមនិយម។ ក្នុងរយៈ៩០ឆ្នាំ ប្រទេសខ្មែរបានក្លាយជាភូមិមួយ របស់ប្រទេសបារាំង នៅក្នុងភូមិនេះ យុវជនខ្មែរបានទទួលការអប់រំ តាមកម្មវិធី របស់អ្នកអាណានិគមនិយម តាំពីកុមារភាព ក្នុងផ្នែកវិទ្យាស្សង្ស។ តែយើងដឹងថា វិទ្យាស្សង្ស គ្រាន់តែជាឧបករណ៍ នៃគំនិត សំរាប់ធ្វើឲបានសម្រេច នូវគោលបំណង របស់គំនិតតែប៉ុណ្ណោះ។ អវត្តមាន នៃការឲតម្លៃ នៃបុព្វបញ្ញាខ្មែរ ក្នុងកម្មវិធីសិក្សាថ្មី នាំឲមានការផ្តាច់ចំណេះថ្មី ពីមូលដ្ឋានជាតិខ្មែរ ដែលធ្វើអោយវិទ្យាស្សង្ស ស្ថិតនៅត្រឹមតែជាចំណេះវិជ្ជាសំរាប់វណ្ណៈ ច្រើនជាង ជាវិជ្ជាបំភ្លឺការចេះដឹងរបស់បុគ្គល។ តែសេចក្តីសន្និដ្ឋានរហ័យបែបនេះ វាអាចនាំអោយមានការយល់ច្រឡំដែរ បើគ្មានការពិចារណាអំពី ការអប់រំខ្មែរ ពីសម័យដើម។

## ការអប់រំនៅក្នុងសម័យអង្គរ

សង្គមមនុស្សលោកនិមួយៗ អាចក្លាយជា ប្រជាជាតិបាន សុទ្ធតែមាន បញ្ញាជាតិ ជាថាមវន្ត។ ក្នុងចំណុចនេះឯង ដែលយើងចង់លើកមកពិចារណាអំពីរបៀបអប់រំខ្មែរ មុនសម័យបារាំងចូលស្រុកខ្មែរ ដើម្បីទុកជាយោងសំរាប់សំគាល់នៃដំណើរជឿនលឿន នៃបញ្ញាខ្មែរ មាននៅក្នុងសម័យអាណានិគម។

ការអប់រំក្នុងសម័យអង្គរ ដូចយើងបានជំរាប់ជាសង្ខេបខាងលើរួចខ្លះមកហើយ ជាការអប់រំ នៃវណ្ណៈ។ អ្នកដែលបានទទួលការអប់រំ ក្នុងសម័យនោះ គឺ ជាបុគ្គលកើតនៅក្នុងវណ្ណៈព្រាហ្មណ៍ ឬ វណ្ណៈក្សត្រ។ ដូច្នេះ ការចេះដឹង ជាបុព្វសិទ្ធ នៃវណ្ណៈ។ ក្នុងកម្មវិធីអប់រំសំរាប់វណ្ណៈព្រាហ្មណ៍ គឺ សិក្សា អំពី លទ្ធិព្រាហ្មញ្ញសាសនា ឯចំណែក វណ្ណៈក្សត្រមានកាតព្វកិច្ចសិក្សា វិជ្ជាដឹកនាំជាតិ ដែលមាននៅក្នុងលទ្ធិព្រាហ្មញ្ញសាសនា។ វណ្ណៈទាំងពីរនេះឯង ជាវណ្ណៈ នៃ វរភាពជាតិ វណ្ណៈទី១ ក្នុងផ្នែកគំនិត រីឯ វណ្ណៈទី២ ក្នុងផ្នែកនយោបាយដឹកនាំជាតិ។ ឯចំណែក ប្រជារាស្ត្រ ទទួលបានការអប់រំ ក្នុងផ្នែក វិជ្ជាជីវៈនៅក្នុងចង្កុំគ្រួសារ។ ផ្លូវចូល ទៅក្នុង មជ្ឈដ្ឋាន នៃការអប់រំ របស់ វណ្ណៈព្រាហ្មណ៍ និងក្សត្រៈ គឺជាផ្លូវបិទជិត មិនអាចចូលបាននោះឡើយ។ ចំពោះ ព្រាហ្មញ្ញសាសនា ការបែងចែកវណ្ណៈនេះ ជាគោលការណ៍សំរាប់រក្សាសុខដុមក្នុងសង្គម ឬ ជា ការចែកមុខនាទីដល់ វណ្ណៈនិមួយៗ ក្នុងការរកសុខដុម សំរាប់ការរស់នៅ នៅក្នុងសង្គមមនុស្សផង និងសង្គមជាតិផង ដែលពួកព្រាហ្មណ៍ទុកជា អសមភាព មាន អាណាប្រយោជន៍។

ក្នុងរបៀបអប់រំ នៃវណ្ណៈ បែបនេះ បង្កើតឲមាន បញ្ញវន្តមានវណ្ណៈ មានឋានៈជាអ្នកចេះដឹងផង ជាឧត្តមមនុស្សផង ដែលជា ជនមានបុព្វសិទ្ធិពីកំណើត មានកាតព្វកិច្ចទទួលមរតក នៃចំណេះ របស់វណ្ណៈ ដែលខ្លួនជាសមាជិកជាសិទ្ធិ ។ បញ្ញវន្តមានវណ្ណៈនេះឯង ជា

ក្រុមអ្នកកសាង វប្បធម៌រុងរឿងជាតិខ្មែរ និង មហានគរខ្មែរ មានឈ្មោះល្បីល្បាញ ច្រើនសតវត្ស នៅក្នុងដំបន់អាស៊ីប៉ែកអគ្នេយ៍។ ដូច្នេះ គេអាចទុកបានថា ព្រហ្មញ្ញសាសនា នៅក្នុងសម័យអង្គរ ជាឃ្លាំងនៃចំណេះ របស់បញ្ញវន្តខ្មែរ ចងប្រទាក់ឆ្វាត់គ្នា ជា បណ្តាញនៃការអភិវឌ្ឍន៍ នៃប្រទេសខ្មែរ ក្លាយជា មហានគរ នៃវប្បធម៌ និង មហានគរយោធាផង។ វរជនខ្មែរ នៅក្នុងសម័យអង្គរ ត្រូវមាន លក្ខណៈ ជា អ្នកចេះដឹងផងជា មេទ័ពផង និង ជា អភិបាលផង ហើយ មានទំនាក់ទំនងរវាងគ្នានឹងគ្នាជា អង្គកាយនៃគំនិត និង ជាបណ្តាញ នៃក្រុមសមគំនិត រួមរស់ជាមួយគ្នា ដើម្បីការពារប្រយោជន៍វណ្ណៈ ជាអ្នកចេះដឹង និង ជាអ្នកដឹកនាំជាតិ។ ហេតុនេះឯង បានជាគេឃើញមានការរួបរួម រវាង វណ្ណៈព្រាហ្មណ៍ ជាមួយ វណ្ណៈក្សត្រ រួមជា វណ្ណៈបញ្ញវន្ត ក្នុងលក្ខណៈ ជាទំនាក់ទំនងចាំបាច់ ដើម្បីរក្សា អធ្យោត្តមភាព នៃវណ្ណៈទាំងពីរ លើវណ្ណៈដទៃទៀត ក្នុងឋានៈខ្លួនជា អ្នក កសាងជាតិ និង ជា ម្ចាស់នៃអំណាចជាតិ។ យើងអាចសន្និដ្ឋានបានថា ការអប់រំនៅក្នុងសម័យអង្គរ មានគោលបំណង មិនត្រឹមតែ ជាការផ្ទេរចំណេះ ពីគ្រូដល់ សិស្ស វាមានលើសពីការនេះទៅទៀត គឺ ជាការបណ្តុះបញ្ញាអោយដុះនៅក្នុងគំនិតរបស់សិស្ស ដឹងយល់ អំពី សិទ្ធិ និង ករណីយកិច្ច នៃវណ្ណៈ របស់ខ្លួន។

ស្របគ្នានឹងការអប់រំ នៃព្រហ្មញ្ញសាសនា ក៏មានការអប់រំ នៃពុទ្ធសាសនា នៅក្នុងសង្គមខ្មែរ។ ការអប់រំ បែបព្រហ្មញ្ញសាសនា អាចប្រដូចបានជាការអប់រំ នៃវរជន រីឯការអប់រំ បែបពុទ្ធសាសនា ជាសាលា នៃរាស្ត្រ បង្ហាត់បង្រៀន កូន របស់ រាស្ត្រឲដឹងក្តី គឺៈ ចេះអានអក្សរ ចេះសូត្រធម៌ព្រះពុទ្ធ ស្គាល់ដឹងអំពីក្បួនសុជីវធម៌និង គ្រប់ពិធីការមាននៅក្នុងពុទ្ធសាសនា។ ការអប់រំ បែបពុទ្ធសាសនា ជាការអប់រំ នៃវិជ្ជាជាន់ដំបូង សំរាប់ការរស់នៅជាមនុស្សមានធម៌។ បន្ទាប់មក កុមាដឹងក្តី (ចប់ការសិក្សា)ដែលជានេនមានជម្រើស ឬ បន្តសិក្សា ជាជម្រៅ នូវធម៌ព្រះសម្ពុទ្ធសមគោតមក្នុងឋានៈជាភិក្ខុ ឬ លាចាកពីនេន វិលត្រឡប់ទៅរស់ជាគ្រហស្ថនៅក្នុងសង្គមមនុស្សលោកប្រើការចេះដឹងរបស់ខ្លួន សំរាប់ប្រយោជន៍សង្គម។

### សតិសម្បជញ្ញៈជាតិ ក្នុង សម័យ អាណាព្យាបាលបារាំង

ក្រោយឆ្ងាយមកទៀត ចាប់ពីឆ្នាំ ១៩១១ មានចំហាយឥទ្ធិពល បដិវត្តន៍នៅស្រុកចិនមកក្នុងដំបន់ឥណ្ឌូចិន នាំឲយុវជនខ្មែរមួយចំនួន ចាប់ផ្តើមមាន «មនសិការជាតិ» ចំពោះអានាគត នៃប្រជាជាតិខ្លួន។ មនសិការជាតិនេះ គឺជាគំនិតថ្មី នៃអ្នកចេះដឹងខ្មែរ អានាមិក មួយចំនួន ចិញ្ចឹមគំនិតជាតិគ្រប់ទីកន្លែង ជាពិសេស នៅក្នុងវត្តអារាមដែលជាមជ្ឈមណ្ឌល នៃវប្បធម៌ខ្មែរជំនាន់នោះ។ បាតុភូតនេះ គឺកើតមានពីការសេពគប់ រវាងវប្បធម៌បុរាណ ដែលដេកលក់នៅក្នុងវត្តអារាម និងចំណេះវិទ្យាសាស្ត្រថ្មី។ អ្នកចេះធម៌សាសនា និងអ្នកចេះវិជ្ជាវិទ្យាសាស្រ្ត យល់ស្របគ្នាថា ត្រូវបង្កើតគំនិតថ្មីមួយ

ដើម្បីការពារប្រយោជន៍ជាតិ។ ជាបឋមគឺត្រូវបង្កើតសេចក្តីសង្ឃឹម លើកម្លាំងជាតិ ដែលជាផលកើតពីឆន្ទៈរួម។ សេចក្តីសង្ឃឹមនេះ នាំឲខ្មែរមានការទុកចិត្ត លើតម្លៃខ្លួនឯង ដែលដេកលក់នៅក្នុងការអស់សង្ឃឹមរាប់រយឆ្នាំមកហើយ។ ចរន្តនៃគំនិតនេះ ជ្រាបចូលក្នុងសតិសម្បជញ្ញៈ នៃយុវជនខ្មែរ នាំបង្កើតសេចក្តីក្លាហាន ហ៊ានធ្វើគម្រោងការលើកស្ទួយវប្បធម៌ខ្មែរឲរស់វិញបាន ជារូបភាពពិតនៃកម្លាំងជាតិ។

ក្នុងឆ្នាំ១៩៣៦ ខ្មែរអ្នកស្នេហាជាតិមួយចំនួន មានគំនិតបង្កើតសាពត៌មាន ឲឈ្មោះថា«អង្គរវត្ត» ក្នុងគោលបំណង អប់រំគំនិតខ្មែរ ឲមានការចាប់អារម្មណ៍លើសេចក្តីសង្ឃឹម គឺគំនិតរំដោះជាតិពីអាណាព្យាបាលបារាំង ដើម្បីឯករាជ្យជាតិ។ ពេលនោះមានមហាបុរសបីរូប ហ៊ានងើបឈរឡើង កាន់អាវុធដងប៉ាការ នាំគ្នាសរសេរអំពីគំនិតជាតិ ដែលជារស្មីពន្លឺចន្លុះ បំភ្លឺមាគ៌ា នៃមនសិការជាតិ ក្នុងភពអាធ្យាត ឥតមានផ្កាយរះ។ គំនិតនេះ បង្កើតជា រងើកភ្លើង ក្នុងគំនិតខ្មែរគ្រប់ស្រទាប់ ដុតចិត្តខ្មែរឲក្តៅក្រហាយ មិនសុខចិត្តសុខកាយ រស់ជាជនជាតិខ្ញុំបរទេស នាំគ្នាតាមអានកាសែតអង្គរវត្ត ព្រោះទុកវាជាអ្នកនាំផ្លូវបដិវត្តន៍ចិត្តគំនិតខ្មែរ ឲស្គាល់តម្លៃសេរីភាព និងឯករាជ្យជាតិ។ មហាបុរស់ទាំងបីនោះ គឺលោក ស៊ឹង ង៉ុកថាញ់ ប៉ាក ឈឺន និង អៀវ កើស លោក ខំប្រឹងប្រែង ខាបព្រលឹងជាតិ ឲមកស្ថិតក្នុងព្រលឹងប្រជាពលរដ្ឋខ្មែរ ដើម្បីឲខ្មែរងើប ហើយនាំគ្នារត់ដូចទឹកហូរ ទៅលំអន់ រនាំងបារាំង បិទជាតិខ្មែរឲរស់ជាជាតិខ្ញុំគេ រស់តាមដង្ហើមបរទេស។ គំនិតបួន ដែលមហាបុរសទាំងបី មានគោលបំណងដាំក្នុគំនិតខ្មែរ គឺសាមគ្គីភាព សកម្មភាពសតិបញ្ញា សុជីវធម៌ និងចរិយាសម្បត្តិល្អ។

១.យកសាមគ្គីភាព ធ្វើជាអាវុធ សំរាប់ប្រឆាំងនឹងអាត្មានិយម ;

២.យកសកម្មភាពសតិបញ្ញាធ្វើជាអាវុធសំរាប់ប្រឆាំងនឹងការអស់សង្ឃឹមនិងគំនិតអានាមិក ;

៣.យកសុជីធម៌ ធ្វើជាអាវុធ សំរាប់ប្រឆាំងនឹង ភាពគ្មានការថ្លៃថ្នូរ នៅក្នុងជីវភាពរស់នៅក្នុងសង្គម ;

៤.យកចរិយាសម្បត្តិល្អ ធ្វើជាអាវុធ សំរាប់ប្រឆាំងនិងអញ្ញនិយម និងភាពគ្មានការទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត និងសោកនាកម្មជាតិ។



## អក្សរសិល្ប៍ខ្មែរ

តាមទស្សនៈ លោក កេង វាន់សាក់ អក្សរសិល្ប៍ ជា វិទ្យាស្បង្ស ដែលចោទនិងដោះស្រាយបញ្ហាមនុស្ស ដោយសិល្ប៍វិធី ទៅតាមសង្គមនិមួយៗ។ ទោះបី អក្សរសិល្ប៍ខ្មែរ មានតិចតួតក្តី តែវាមានចរិតលក្ខណៈសំខាន់ អាចឲយល់ដឹងច្បាស់ពិតប្រាកដ អំពីតួនាទីរបស់ខ្លួន ដែលអាចទុកជាជំនួយ សំរាប់ បំភ្លឺឲឃើញថា អ្វីជា លក្ខណៈពិសេស របស់ខ្មែរ តែវាក៏បង្ហាញឲឃើញដែរ នូវការមិនគ្រប់គ្រាន់ របស់ខ្លួនឯងដែរ ជាពិសេសនៅពេលណាដែលអក្សរសិល្ប៍ ប្រាថ្នាថាខ្លួនជា ជិពវិញ្ញាតិ (expression vivante) នៃសង្គមខ្មែរ ហើយក្លាយជា សោភណវិទ្យា (science esthétique) នៃបញ្ហាមនុស្សលោក នៅពាក់កណ្តាលសតវត្សទី ២០។

នៅបស្ចិមប្រទេស ពាក្យ «អក្សរសិល្ប៍» ចាប់ផ្តើម មាន អត្ថន័យសម័យ ក្នុងមជ្ឈដ្ឋាននៃវរជន នៅក្នុងសតវត្សទី១៨ តែប៉ុណ្ណោះ ព្រោះ សៀវភៅ ជា ផលិតផល កម្រ រកបានមានតម្លៃថ្លៃណាស់ហើយ ទុកសម្រាប់តែ ក្រុមបញ្ញវន្តអក្សរសាស្ត្រ និង អ្នកប្រាជ្ញ។ មកដល់សតវត្សទី១៩ អក្សរសិស្ប៍ ចាប់ផ្តើម មាន វិត្ថារកម្ម ឥទ្ធិពល ក្នុងមជ្ឈដ្ឋាន សាធារណជន ដោយសារមានការចំរើនលូតលាស់យ៉ាងច្រើន នៅក្នុងវិស័យ សាធារណសិក្សា។ ហេតុនេះហើយ បានជា សៀភៅ ក្លាយជាផលិតផល ធម្មតា សំរាប់ សាធារណជន ទោះបីនៅមានតម្លៃថ្លៃនៅឡើយ។ អ្នកអានសៀវភៅមិនចាប់ មានឋានៈ ជា បញ្ញវន្ត ឬ អ្នកប្រាជ្ញ ដូចសតវត្សមុននោះឡើយ ; នរណាម្នាក់ក៏អាចអានសៀភៅបាន បើគេចេះអក្សរ និង មាន គំនិត ចង់ដឹងចង់យល់ អំពីអ្វីដែល សសេរនៅក្នុងសៀវភៅ។ សតវត្សទី១៩ ជាការចាប់ផ្តើម នូវ ប្រជាវូបនីយកម្ម នៃ ការអានសៀវភៅ។

មានសៀភៅ គឺត្រូវមាន អ្នកសសេរ ហើយ អ្នកសសេរ ច្រើនមាន គតិសេរី សំរាប់ សសេរគំនិតរបស់ខ្លួន ព្រោះ សេរីភាព ជា គំនិតសំខាន់ នៃ ការត្រិះរិះ របស់មនុស្ស។ ហេតុនេះឯងហើយ បានជា អ្នកកាន់អំណាច នៅក្នុងសម័យបុរាណ តែងតែមានការបារម្ភចំពោះឥទ្ធិពល នៃ អក្សរសិល្ប៍ ហើយ ស្អប់ខ្ពើម ព្រោះវាច្រើនតែបង្កើតទំនាស់ប្រឆាំងនឹង ប្រពន្ធនយោបាយ។ អក្សសិល្ប៍ តាមធម្មតា តែងតែ ធ្វើអោយ រញ្ជួយប្រពន្ធនយោបាយ ដែលជាប្រពន្ធ យកជំនឿឥតសមហេតុផល មកធ្វើ ជា យុត្តិកម្ម នៃ អំណាចរបស់ខ្លួន និង ជា ប្រពន្ធបង្កើតឡើង សំរាប់ រក្សាបុព្វសិទ្ធិ វណ្ណៈអ្នកដឹកនាំ។ ឆន្ទៈ របស់អក្សរសិល្ប៍ គឺ ពិនិត្យ និង អង្រួន ចុះនាម (s’inscrit) ក្នុងគោលបំណង ធ្វើការកែទម្រង់ លំដាប់ចាស់ ដើម្បីសុខុមាលភាព នៃមនុស្សលោក និង មនុស្សជាតិ។

គេស្គាល់ អក្សរសិល្ប៍ខ្មែរ តិចជាង សិល្បៈខ្មែរ ទោះបី មានកំណើត ក្នុងពេលវេលាជាមួយគ្នាក្ដី។ គ្រប់មហាក្សត្រ ស្ថាបនិក មហានគរខ្មែរ ព្រះអង្គបានចារទុក អត្ថបទ ជាច្រើន លើផ្ទាំងប្រាសាទ លើ ស្លឹករឹត ជាហូរហែបន្តគ្នា មាននៅក្នុង មហារយៈពេល នៃប្រវត្តិសាស្ត្រខ្មែរ ដែលជាការបញ្ជាក់ នូវអត្ថិភាព នៃអក្សរសិល្ប៍ខ្មែរ ទោះបីអក្សរសិល្ប៍ទាំងឡាយនោះ គ្មានរូបី ជា **ទិស្សមាន**[21] ដូចមហាប្រាសាទ អង្គរ ដែលទាក់ទាញ អារម្មណ៍ អ្នកសិក្សាវិជ្ជា ខាងបូព៌ាប្រទេស។ ចំណារ ដែលមានចារទុក ជាទូទៅនោះ អាចជា ជំនួយ សំរាប់ បភ្លឺនូវប្រវត្តិសាស្ត្រ វប្បធម៌ និងអារ្យធម៌ ខ្មែរ បាន ដូច រូបភាព នៃ ប្រាសាទ នោះដែរ។

ហេតុដូច្នេះ មន្ទិល អំពី អត្ថិភាព នៃអក្សរសិល្ប៍ខ្មែរ ទុកជាមោឃភាព។ តែ បញ្ហា នៅមានចោទ គឺថិននៅលើ សំណួរថា តើ អក្សរសិល្ប៍ខ្មែរ ជា វិទ្យាសង្ស ដែរឬទេ ដែលមានចារទុកក្នុងប្រវត្តិសាស្ត្រ របស់ខ្លួន។ តែ ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ខ្មែរ ជា វិទ្យាសង្សមិនដូចជា វិទ្យាសង្ស ដែលគេយកមកសិក្សា នៅមស្ចឹមប្រទេសនោះឡើយ។ ហើយ ចុះបើវិទ្យាសង្ស នៃអក្សរសិល្ប៍ខ្មែរ ទើបតែចាប់ផ្ដើមមាន ក្រោយ កំណើត នៃ អត្ថបទចំណារ រឿងនិទាន រឿងព្រេង កំណាព្យអណ្ដែតអណ្ដូង អត្ថបទជាឧបទេស រឿងល្ខោនប្រលោមលោក សសេរសាកល្បង មានលក្ខណៈ ជាសាសនាក្ដី ជាទស្សនវិជ្ជាក្ដី  បញ្ចេញឲដឹងនូវមនោសញ្ចេញនា របស់ខ្មែរ តាំងពីយូរយារមកហើយ សួរថា ការចង់ដឹងអំពីអក្សរសិល្ប៍ខ្មែរ ជា វិទ្យាសង្ស មានសារប្រយោជន៍អ្វី ?

ប្រយោជន៍ គឺថិតនៅលើ ការសិក្សា ឲយល់ដឹង អំពី តម្លៃ នៃអក្សរសិល្ប៍ តាមវិទ្យាសង្សនោះឯង។ ជាការងាយស្រួល ក្នុងការសិក្សា អំពី អក្សរសិល្ប៍ខ្មែរ តាមការបង្ហាញ នូវទ្រង់ទ្រាយ ជា ការសង្ខេប ឬ ជាគ្រោងរាង ដូចជាធ្វើការរៀបរាប់ ជា ឈុត នាម នៃសៀវភៅ ជា ឈ្មោះ នៃ អ្នកនិពន្ធ ជា ប្រធានបទសិក្សា។ តែ ការបង្ហាញបែបនេះ នូវតែមិនមានភាព ទូលំទូលាយ ស្មើនឹង រូបចតបង្ហាញប្រាសាទនានានៅអង្គរ។ ដូច្នេះ មានតែ ចំណេះ ជា វិទ្យាសង្ស និង សិក្សារិះគន់ អត្ថបទ ទើបអាចបង្ហាញ ប្រភពដើមនិងតម្លៃ នៃអក្សរសិល្ប៍ខ្មែរ បាន។

---

[21] ទិស្សមាន= អាចមើលឃើញ ; visible។

អក្សរសិល្ប៍ ជាវិទ្យាសង្ស អាស្រ័យ ទៅលើ ចំណេះ ដទៃច្រើនទៀត ហើយ ចំណេះនិមួយៗ សុទ្ធតែមានសារៈសំខាន់ទាំងអស់។ ជា ការសំដែកគំនិត តាមការសសេរ នូវ វប្បធម៌ និងអារ្យធម៌សព្វអក្សរសិល្ប៍ សម្តែងដោយខ្លួនឯង ដូចជា វិទ្យាសង្ស នៃ បញ្ហាមនុស្ស ដែលខ្លួន សាកល្បង ដោះស្រាយ តាម វិធីសិល្បៈ ទៅតាមសង្គមនិមួយៗ។ ដូច្នេះ វិទ្យាសង្ស នៃអក្សរសិល្ប៍ ជា វិជ្ជា សាំញ៉ាំមួយ កើតចេញមកពីសំយោគ សព្វ នរវិទ្យាសង្ស។ហេតុនេះឯង វិទ្យាសង្ស នៃ អក្សសិល្ប៍ខ្មែរនឹងអាចមាន ការជឿនលឿនបន្តិចម្តងៗ នៅក្នុងដំណើរឈានមុខ នៃ ការសិក្សា វិទ្យាសាស្ត្រគ្រប់មែក នៃ វប្បធម៌ និងអារ្យធម៌ ខ្មែរ ដែលជាបាតសំខាន់មួយ នៃ អក្សរសិល្ប៍ខ្មែរ។

ដូច សព្វ អក្សរសិល្ប៍ របស់ ខ្មែរ មិនមែន ជា ការណ៍[22] ឯកោ នោះឡើយ ប៉ុន្តែ ជា អំពើរួម នៃជំនួប នៃវប្បធម៌ និង អារ្យធម៌ ជាច្រើន។ លើសទៅទៀត វា ការសំដែង ក្នុង ភាសាដែលសម្រោះយក ភាសាសំសក្រ៏ត បាលី និង ភាសាប្រជាជន នៃប្រទេសជិតខាង ដូចយ៉ាង ភាសា ចាម សៀម លាវ ចិន ។ល។

នៅក្នុង ប្រភព ដ៏ច្រើននេះ ក្នុង **បរិបទ**[23]ខ្មែរ គួរដឹងដែរថា ហេតុអ្វី ដែលអាចអោយប្រភពដើមខ្មែរ សំដែងបាន នូវទេពកោសលផ្ទាល់ខ្លួន។ បញ្ហាពិតនេះ អាចមានចម្លើយបាន តាមការអោយតម្លៃច្បាស់ អំពី ភាពក្លៀវក្លា នូវ ការចាក់គ្រិះ នៃវប្បធម៌ **មន-ខ្មែរ** ដែលទុក ជា ទម្រ និង ជា ថាមពល ខ្មែរ សំរាប់ ពង្រិក វប្បធម៌និងសង្គមខ្មែរ។ ពិតមែនតែប្រភព ភាសា សំស្រ្កឹត បាលី ថៃ និង ចិន, ឈ្មោះ តួអង្គ ក្នុងរឿង **រាមាយាណា** ឬ **ជាតាកាស** (ប្រវត្តិ នៃជាតិព្រះពុទ្ធ) ដូច ប្រធានបទ ដកស្រងចេញមកពី អក្សសិល្ប៍ពុទ្ធិក ដែរ អ្វីដែលបានរៀបរាប់មកនេះ ដែលនាំអោយ អ្នកប្រាជ្ញជាច្រើន ធ្វើសេចក្តីសន្និដ្ឋាន យ៉ាងរហ័សក្នុងបំណង ដាច់ថ្លៃ ថាអក្សរសិល្ប៍ខ្មែរ ក្លាយមកពី អក្សរសិល្ប៍បរទេស។

វាគ្មានអ្វី ជាការមិនល្អ ដែល អារ្យធម៌ ធំៗ ដកស្រង់យក ប្រធានបទ  ពី អារ្យធម៌ដទៃទៀត មកធ្វើសំយោគ ជាមួយនឹង ប្រធានបទ របស់ខ្លួន ព្រោះ អក្សរសិល្ប៍ នៃ គ្រប់

---

[22] ការណ៍= Fait។
[23] បរិបទ= Un contexte។

ជាតិសាសន៍ ចាំងបង្ហាញ និង សម្រួល នៃការជ្រៀតជ្រែក រវាង ចរន្ត នៃ អារ្យធម៌។ តែសារៈសំខាន់មិនស្ថិតនៅលើ កម្មវិធី ប្រធានបទ អ្វីមួយ ដែល គ្រប់ជាតិសាសន៍ទុកជាសម្បត្តិរួម យកវាមកធ្វើ «**ជាតូបនីយកម្ម**» តាម វិធីសមានកម្ម ឬ ផ្លាស់ទ្រង់ទ្រាយជាថ្មី យ៉ាងជម្រៅ អស់រយៈពេលយូរអង្វែង ហើយ បន្តជាថ្មីមិនចេះចប់។

ការប្រែប្រួលនេះ ជាការបង្កើត ចរិកពិសេស និង តួអង្គផ្ទាល់ របស់ អារ្យធម៌ និមួយៗ។ កំណើតនេះ គឺជាលទ្ធផល នៃអភិក្រម (ដំណើរ) នៃឥទ្ធិពល នៃ សមានកម្ម និង សមិទ្ធិកម្ម ជាថ្មី ខុសពីគំរូចាស់ ដែលក្លាយជា **ជិពវិញ្ញាតិ** (expression vivante) នៃ ទេកោសល្យជាតិ។ ការទាំងនេះឯងហើយ ដែលមានកើតឡើង នៅក្នុង អក្សរសិល្ប៍ខ្មែរ ដែលបានរំលាយបាន នូវ គំរូចាស់ តួអង្គ និង ប្រធានបទជា កម្មវិធី ដើម្បី ធ្វើអ្វីមួយថ្មី អោយមានប្រភេទជាខ្មែរ។

ដូច្នេះ រឿងរាមាយាណា ឥណ្ឌា បានក្លាយជា រឿងរាមកេរ្តិ៍ខ្មែរ ហើយទោះបី ចំណងជើង សៀភៅ តួអង្គ និង ទីកន្លែង នៅរក្សារហិរហៀង នូវ ឈ្មោះឥណ្ឌា នៅឡើយ តែថា អន្តរវត្ថុ (contenu) វិញ មិនដូចគ្នាទាល់តែសោះនឹង ស្នាដៃរបស់ អ្នកនិពន្ធ **វាលមីគី**នោះឡើយ។ អត្ថបទ ទី១ នៃរឿងរាមកេរ្តិ៍ខ្មែរ មិនបានបង្ហាញឲយើញ នូវ ការបកប្រែ ការត្រាប់តាម ការយកលំនាំតាម នៃអត្ថបទ ឥណ្ឌា សោះឡើយ តែ ស្នាដៃខ្មែរ ជា ទម្រង់ក្តីជាគ្រិះក្តី ឃើញមានភាពផ្ទុយ ពិស្នាដៃ រាមាយាណា (Ramayana) ឥណ្ឌាទៅវិញ។

ក្នុងសង្គមខ្មែរ គ្មានមាន វណ្ណៈព្រាហ្មណ៍ ដើម្បីការពារ មនោគមវិជ្ជា វណ្ណៈព្រាហ្មណ៍ហើយ នៅក្នុងរឿង រាមាយាណា មាន ព្រះរាមា ចុះពីឋានសួគ៌ មកការពារ មនោគមវិជ្ជានៃវណ្ណៈ រួចយាងត្រឡប់ទៅឋានព្រះអង្គវិញ។ ចំណែក រឿងរាមកេរ្តិ៍ខ្មែរ ប្រែ «ព្រះ» អោយក្លាយជាមនុស្ស រស់នៅយ៉ាងមាំ ជាមនុស្ស នៅក្នុង **សាន់វ័ណ្ឌ**[24] នូវ បដិវាទកម្ម មាននៅក្នុងសង្គម និង **ប្រេមាការ**[25]។ ស្នាដៃខ្មែរ ចាំងបង្ហាញ នូវ ទំនាស់ រវាង ព្រហ្មញ្ញសាសនាជាមួយពុទ្ធសាសនា មានកើតឡើងនៅក្នុងសម័យអង្គរ ពីសំណាក់ អ្នកគាំទ្រ ពុទ្ធសាសនាប្រឆាំងនឹង ព្រហ្មញ្ញសាសនា។

---

24 សាន់វណ្ឌម= មិនអាចកែបាន ; inextricable។
25 ប្រេមាការ =ដែលសំដែងសេចក្តីស្រឡាញ់ ; affective។

នៅចំពោះមុខ អក្សរសិល្ប៍ពុទ្ធសាសនា ការប្រែប្រួល គ្មានលក្ខណៈដាច់ខាតនោះឡើយ ទោះជាយ៉ាងណា, រឿង ជាតក ខ្មែរ មិនទទួលយល់ព្រម ទាំងស្រុង ព្រោះ ទម្រង់ និង គ្រឹះសាច់រឿង វាមិនសមស្របតាមលក្ខណៈប្រពៃណី និង គំនិតដើមខ្មែរ។

ដូចគ្នានឹង ការផ្លាស់ទ្រង់ទ្រាយជាថ្មី មានមូលដ្ឋាន **ខ្មែររូបនីយកម្ម** ក្នុងវិស័យ អក្សរសិល្ប៍ សិល្បៈនិង ភាសា ដែលធ្វើឡើង តាម និន្នាការ សំខាន់ ពីរយ៉ាង  នៃ អារ្យធម៌ខ្មែរៈ **ប្រាកដនិយម** និង **សនិទាននិយម**[26]។ និន្នាការ ទាំងពីរ នេះឯង នៅក្នុង រឿង រាមកេរ្តិ៍ខ្មែរ ដែលអ្នកនិព័ន្ធខ្មែរ យកមកធ្វើវិធី មនុស្សរូបនីណកម្ម នៃអាទិទេព រាមា អោយក្លាយជា មនុស្ស ឥតលំអៀង។

អក្សរសិល្ប៍ខ្មែរ មាន តួអង្គ ជាច្រើន ជា តួអង្គ មិនពិត ដូចជា ទេវតា យក្ស ខ្មោច រុក្ខជាតិ សត្វ ចេះនិយាយ ភាសាមនុស្ស ដែលខ្មែរ   យល់ឃើញ ជា ទម្លាប់ ក្នុងចរិតជាក្មេង ជា អច្ឆរិយ ឬ បញ្ឆោតលេង។ តែបើយើងយកអត្ថបទ មកសិក្សារកការពិត យើងឃើញថា ទេវតា ក្តី តួអង្គព្រះពុទ្ធ ក្នុងជាតិមុនៗរបស់ព្រះអង្គ ក្តី គឺជា មនុស្ស ពិតប្រាកដណាស់។ ហើយនៅក្នុង រឿងព្រេងនានា មានតួអង្គ ជាសត្វជាច្រើន តែ តួអង្គ និមួយៗ ជាបុគ្គលសង្គម ដូចគ្នានឹងមនុស្សនោះដែរ។

ខ្មែរ ស្អប់បំផុត គឺ **ការឲតម្លៃសំខាន់ទៅលើមនោសញ្ចេញនា**[27] **ភាពវិសេសវិសាល**[28] និង **របស់គ្មានខ្លឹមសារ**[29] ដែលពិបាកយល់។ អាទិទេព តែមួយគត់ ដែលខ្មែររាប់អានគោរពយូរជាងគេទាំងអស់ គឺ សីលាលីង្គ ព្រះឥសូរ ឯចំណែក អាទិទេព រាមា ដែលជាអវតាព្រះវិស្ណុ ខ្មែរតែងតែទុក ជា មនុស្សា រស់នៅ ក្នុងច្រវាក់ទុក្ខ របស់មនុស្ស មិនចេះចប់ ដូចមនុស្សលោក។

ខណៈពេលដែល អាទិទេព ក្លាយ ជាមនុស្ស ហើយ  វិរបុរស វិសេសវិសាល នាំមកវិញ នូវធម្មជាតិពិត របស់ខ្លួន ដូចយ៉ាង ជាៈ មនុស្ស កំសាក អំនួត ពិបាកយល់ : ឧទាហរណ៍ៈ

---

[26] សនិទាននិយម= ចំណេះទាំងឡាយ មានមកពី វិចារណញ្ញាណ ; Rationalisme។
[27] ការឲតម្លៃសំខាន់ទីលើមនោសញ្ចេញនា= Le mysticisme។
[28] ភាពវិសេសវិសាល (អតិសេដ្ឋភាព)= La transcendance។
[29] របស់គ្មានខ្លឹមសារ= La mystification។

បុរស គង់-ហ៊ាន ជា វិរបុរស វិសេសវិសាល តែមាន ធម្មជាតិ ជា មនុស្ស នៅចំពោះមុខគ្រោះថ្នាក់ គាត់ រាកអាចម៍ លើក្បាល សមិតដំរី ដែលខ្លួនកំពុងជិះ ហើយ ដំរីនោះដើម្បីធ្វើឲជ្រុះអាចម៍ ពីលើក្បាលវា ក៏បោលសំដៅ ទៅរកទ័ពសត្រូវ។ ឃើញដូច្នេះ នឹកស្មានតែបុរស គង់-ហ៊ាន បញ្ជាឲដំរីសឹក បោលចូលវាយសំរុក សត្រូវនាំគ្នាភិតភ័យ រត់ប្រសេកប្រសាចចោលជួរទ័ព។ ទង្វើនេះ នាំឲ គង់-ហ៊ាន ជា ឧត្តមសេនីយ មានជ័យជំនះលើសត្រូវ ហើយបានទទួលរង្វាន់ ជាច្រើន ពីព្រះមហាក្សត្យខ្លួន។ តាមពិតបុរសគង់-ហ៊ានជាមនុស្ស កម្លាច បំផុត តែជាចៃដន្យ ទទួលបានជ័យជំនះលើសត្រូវ ក្នុងភាពខ្លាំងពូកែជា វិរបុរស។

ដូចការស្វែង ភាពដាច់ខាត បិតថេរចិរកាល ក្នុង សេចក្តីស្រឡាញ់ នូវការមិនទៀងទាត់ មាននៅក្នុងរឿង ជាតិព្រះពុទ្ធ ចំនួន ៥០ រឿង ដែលខ្មែរយក មកធ្វើ ខ្មែរូបនិយកម្ម គេឃើញមានលក្ខ   ណៈ ជារឿង ផ្សងព្រេង រឿងស្នេហា របស់មនុស្ស ជាច្រើន ដែមិនអាចរាប់បាន ជាង រឿងស្តីអំពីនិព្វានរបស់ព្រះពុទ្ធ។ ក្នុងរឿងទាំងឡាយនោះ មានរឿង ព្រះពុទ្ធជា វិរបុរស ប្រកបដោយសោកនាដកម្ម ឬ ប្រកបដោយ អាថ៌កំបាំង មិននាំឲខ្មែរ ឲយកចិត្តទុកដាក់ ហើយក៏ មិនយកមកទុកជាសករៈ នោះផង។ ជាតិព្រះពុទ្ធជាទស្សនវិទូ ជាអ្នកតស៊ូប្រឆាំងនឹង អ្នកកាន់សាសនាជេន និង ព្រាហ្មណ្ណសាសនាត្រូវបានខ្មែរគ្រាន់តែយកមកសិក្សារ តែមិនមានប្រជាប្រិយភាពនោះទេ។ រឿងតែមួយគត់ដែលខ្មែរយើងចូលចិត្ត គឺរឿង **មហាវេស្សន្តរជាតក** ព្រោះជា ជារឿងបង្ហាញនូវបដិវាទកម្មរវាង ការស្វែងរកសុក្រឹតភាព នឹងកាតព្វកិច្ច សង្គម គ្រួសារ និង មនោសញ្ចេតនា។

បើខ្មែរ ទទួលស្គាល់ បញ្ញា មាននៅក្នុង រឿង **មហាជាតក** ថា មានតម្លៃខ្ពស់បំផុត មិនមែននៅត្រង់ចំណុច ថាជា វិទ្យាស្សង្ស នោះទេ គឺ នៅលើ បញ្ញា ប្រតិបត្តិ និង ប្រាកដនិយមដែលធ្វើមិនឲសត្រូវ ក្រៅ ឬ ក្នុង ក្តី អាចមានជ័យជំនះបាន ហើយជាពិសេសនៅត្រង់ថា បញ្ញានេះ ជា សម្ភារៈការពារ ដ៏ប្រសើរ និង ជា ជាតិស្ថាបនកម្ម។

ហេតុដូច្នេះឯង ក្នុងចំណោម ១០ ជាតក ដែលខ្មែរយកមកធ្វើ ខ្មែរូបនីយកម្ម មានតែរឿងមហាវេស្សន្តរជាតក និង មហាជាតក   នេះឯង ជាពិសេសរឿងទី១ តាមរបៀបបកស្រាយខ្មែរ គឺអោយសារៈសំខាន់ ទៅលើ ភាពគួរឲសង្វេក។ ហើយចំណុច ដែលខ្មែរចូលចិត្តបំផុត គឺ ព្រះវេស្សន្តរ ធ្វើបញ្ច័យ កូនទាំងពីរ និង ភរិយា រួចហើយ ព្រះអង្គបដិសេធមិនព្រមទៅរស់សោយសុខ ឯកោ នៅឋានសួគ៌ សុខចិត្តបន្តរស់នៅក្នុងឋានមនុស្ស

ដើម្បីបន្តដាក់ទាន ព្រោះថា នៅឋានសួគ៌ ព្រះអង្គមិនអាចធ្វើទានឡើយ ព្រោះគ្មាននរណាត្រូវការកុសល។

ហេតុដូច្នេះហើយ បានជានៅក្នុងរបៀបបកស្រាយខ្មែរ គេឃើញថា ពួកអាទិទេព មាននៅក្នុងរឿងឥណ្ឌា ត្រូវខ្មែរយកមកធ្វើ មនុស្សូបនីយកម្ម។ តាមភាពប្រាកដនិយម ជាវិចារណញ្ញាណ នេះទៀត គេឃើញមានដែរ នៅក្នុង អត្ថបទអក្សរសិល្ប៍ខ្មែរ សមិទ្ធិកម្ម ខាងចម្លាក់ ខាងស្ថាបត្យកម្ម ដែលមានទំនង ជាអាថ៌កំបាំង។

តែ ប្រាកដនិយមខ្មែរ មិនឋិតនៅត្រឹមតែ ធ្វើអាទិទេព ឲក្លាយជាមនុស្ស ភាពខ្ពង់ខ្ពស់បំផុត ឲក្លាយមកជាភាពធម្មតា ភាពអច្ឆរយ ឲមកជាភាពពិត ប៉ុណ្ណោះទេ គឺ បង្កបង្កើតដែរ ជាមធ្យបាយសំរាប់ធ្វើសកកម្មភាព។ ប្រសិទ្ធិភាព មិនមែនជាការសំដែងរបស់ **បរមត្ថវិជ្ជា**[30] នោះទេ តែជា ការណ៍និយម[31] ផ្អែកលើ «ចំណេះចេះដឹង»ពិតប្រាកដ និងការប្រុងប្រយ័ត្ន «**ក្នុងការរស់នៅ និង ការមានប្រយោជន៍**»។

ហេតុទាំនេះឯង ដែលខ្មែរយកមក ធ្វើប្រធានបទសំខាន់ៗ នៅក្នុង «ច្បាប់ខ្មែរ» កំណាព្យជាឧបទេស ជាសង្ខេប នៃ ប្រជាសីលធម៌ខ្មែរ។ នៅក្នុងភាសា ប្រកបដោយមនោគតិ សំរាប់គ្រប់ស្រទាប់សង្គមៈ បុរស ស្ត្រី ក្មេង ពិក្ខុ គ្រហស្ថ មន្ត្រី ប្រជាពលរដ្ឋ មហាជន ឲយល់ដឹង អំពីវិធីធ្វើឲមានជោគជ័យក្នុងការរស់នៅ និង ការស្វែងរកសុភមង្គល។

តែ វិធាន ក្នុងលក្ខណ: ជា **ច្បាប់បទដ្ឋាន**[32] គ្មានប្រសិទ្ធិភាព ព្រោះខ្លួនឯងកើតឡើងពី **ច្បាប់យថាវត្ថុ**[33] នៃធម្មជាតិ ដែល រៀបរាប់ ខាងក្រោមនេះៈ

- ធម្មជាតិ អាចដូរបាន

- មនុស្សលោក អាចបត់បែនបាន

---

[30] បរមត្ថវិជ្ជា= Métaphysique។
[31] ការណនិយម= ដែលសំអាងលើ**ការណ៍** (Fait) ; pragmatique។ ការណ៍អ្វីដែលបានសម្រេចទុកជាពិត ទោះបីវាគ្មានសេចក្តីពិតជាដាច់ខាតក៏ដើយ។
[32] ច្បាប់បទដ្ឋាន= Lois normatives។ ច្បាប់ធម្មនិយម។
[33] ច្បាប់យថាវត្ថុ= Lois objectives។ ច្បាប់មានភាពពិត។

- ជាសង្គម អាត្មានិយម

- ជាចិត្តសាស្ត្រ ឥតអាចកែបាន បែប ផ្ទត់គំនិត ប្រដូចបានទៅនឹង កន្ទុយខ្មៀន របស់ឆ្កែដែលគេមិនអាចពុតឲវាត្រង់វិញបាន។

អ្វីទាំងអស់ គឺផ្អែកលើ បដិវាទកម្មះ អ្នកមានទ្រព្យ និង អ្នកក្រខ្សត់ អ្នកមានរិទ្ធិនិង អ្នកទន់ខ្សោយ អ្នកប្រាជ្ញ និង អ្នកល្ងង់ខ្លៅ អ្នកចំអែត និង អ្នកឃ្លាន ដែលនាំឲមាន ការស្អប់គ្នា តែម្នាក់ៗ ត្រូវការគ្នាទៅវិញទៅមក ដូចមានចែងនៅក្នុង ច្បាប់ចាស់ បុរាណថាះ

អ្នកមានរក្សាខ្សត់ ដូចលំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ
អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាឆ្មារ។.......

មានទូកហើយមានថ្នោល មានបង្គោលមានយុថ្កា
ទាំងពួរទាំងច្រវា ក្រដីងចាប់ដោយនូវគ្រប់។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់ នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ជាជីវិត។......

វិធានសីលធម៌ បែបនេះ គឺ ក្នុងបំណង ដោះស្រាយទំនាស់ជាអនន្តរវាង **អាត្មា** នឹង **អ្នកដទៃ**មាននៅក្នុង វណ្ណៈសង្គម។ ប៉ុន្តែ អ្នកដទៃ ត្រូវទុកវា ដូចជា **របស់ផ្ទាល់សំរាប់តែខ្លួនឯង**[34] គ្រាន់ជា ការពិបាកយល់ នូវបរមត្ថវិជ្ជា ពីព្រោះ អ្នកដទៃ តែងតែនៅក្រោម អាត្មាក្នុងភាពជាស្រមោលចាំងចេញ ឬ មធ្យោបាយធម្មតា នៃ សមិទ្ធិកម្ម និង ការ ការពារដល់ខ្លួន។

---

[34] របស់ផ្ទាល់សំរាប់តែខ្លួនឯង= La fin en soi។

ព្រោះថា គេធ្វើអំណោយ មិនមែន សំរាប់តែអោយនោះទេ។ ភាពបរិសុទ្ធ និង ការមិនគិតដល់ប្រយោជន៍ ក្នុង បច្ច័យ គឺជា **បរិកប្បសុទ្ធសាត**[35]។ សេចក្ដីមេត្តាករុណា ដូចជាអ្វីៗឯទៀតដែរ ជាការស្វែងរកផលៈ ដូចយ៉ាង គេចិញ្ចឹមឆ្កែ ព្រោះវា ជា សត្វចេះចាំផ្ទះ។ ហើយការសុំទាន ជាមធ្យោបាយ ប្រាកដ ដើម្បី រកការឧបត្ថម្ភ ពីអ្នកដទៃ សំរាប់ជីវិតក្នុងជាតិនេះ ហើយជៀសវាង កុំអោយមាន សេចក្ដីត្រូវការចាំបាច់ នូវទុគ៌តភាព ហើយជាពិសេស ការប្រកបការងារយ៉ាងពិបាក នៅក្នុងជាតិក្រោយ។
ជីវិតការរស់នៅ គឺគ្មានមានសោះ នូវការឧបត្ថម្ភ តែពោរពេញ ទៅដោយ ការខ្វះខាត ហើយនៅគ្រប់ទីកន្លែង មានកើតឡើង នូវការតស៊ូ ស្វែងរកប្រយោជន៍។ មនុស្សម្នាក់ៗ ជា ជនអាត្មានិយម ជាដំបូង ដល់ អាត្មាឯង តែម្ដង។ មានតែ ការវាយតម្លៃលើការប្រាកដនិយម និង ការប្រុងប្រយ័ត្ន នៃ ស្ថានភាព និង **កាលានុវត្តភាព**[36] នាំអាចឲកែតម្រូវ តាម មធ្យោបាយ សំរាប់អនុវត្ត រកគោលបំណង ក្នុង គោលការណ៍ «ការប្រុងប្រយ័ត្ន និង ប្រសិទ្ធិភាព»។
តែ ការមិនទុកចិត្ត មានជានិច្ចៈ ការមិនទុកចិត្ត ហើយ ការមិនទុកចិត្តទៀត !។ ធម្មជាតិមិនបានកើតឡើង ជា «ខ្សែត្រង់» នោះឡើយៈ ក្នុងព្រៃ មានដើមឈើជាច្រើន មានមែកត្រង់ វៀចវេច ច្របូកច្របល ជាមួយគ្នា ក៏ដូចគ្នានឹង គុណសម្បត្តិ និង គុណវិបត្តិ របស់ មនុស្ស ការធ្វើខុស ការធ្វើត្រូវ របស់ អ្នកដឹកនាំជាតិ នោះដែរ។
ជាការពិតណាស់ហើយ ការជួយគ្នាទៅវិញទៅមក រវាង អ្នកធំ អ្នកតូច ជាការសមស្របនឹងច្បាប់ធម្មជាតិ។ តែ ត្រូវប្រយ័ត្នៈ «ប្រយ័ត្ន អ្នកខ្សត់ គិតតែរស់នឹង ជំនួយ !ៈ *វក៏អាចធ្វើ ឲដើមឈើធំមួយដើម ដែលវាទុកជាទម្រ របស់វា ស្លាប់បាន»*
ត្រូវប្រយ័ត្ន អ្នកមានទ្រព្យច្រើន ដែលមានសទ្ធាជ្រះថ្លាៈ *សេចក្ដីទុកចិត្តទាំងងងឹតងងល់លើអ្នកឧបត្ថម្ភ ដល់អ្នកខ្សត់ ស្រេចឃ្លាន អំណោយ ព្រោះវានាំឲអ្នកឃ្លានអាចមានទុក្ខទៅវិញ។*
ព្រោះថា ធម្មជាតិ គ្មានការទៀងទាត់ ដែលគេទុកថា មានពុត ដូចជា គុណភាព **មជ្ឈន្តិកៈ**[37] របស់មនុស្សលោក និងសង្គមដែរ មានបរិយាយ ក្នុងច្បាប់បុរាណថា ៖ «*ផ្លូវបត់*

---

[35] បរិកប្បសុទ្ធសាត= ផ្សាយគំនិតរកកម្រៃសុទ្ធសាត ; pures spéculations។
[36] កាលានុវត្តភាព= ការផ្ដល់ឳកាសឲ ; opportunité។
[37] មជ្ឈន្តិកៈ= ដែលមានតម្លៃខាងក្នុង ; intrinsèque។

*បែនកុំបោះបង់ចោល*»។ ដែលទុកជា អនុសាស ព្រោះអាច ឲមានលំនំ តាមបានល្អនឹង ច្បាប់បទដ្ឋាននិង ច្បាប់ យថាវត្ត នៃមនុស្សលោកនេះឯង។
ក្នុងរឿងនិទានខ្មែរ សារ័ក ទី១ ដែលឲគម្រាប់ នៃការអនុវត្ត នូវច្បាប់កិរិយានេះ គឺ « សុភាទន្សាយ» ដែលខ្មែរទុកជា វិរបុរសមួយ ព្រោះហ៊ាន ប្រើល្បិត ឬ កុហក ដើម្បី យករួចខ្លួនពីបញ្ហា ដែលខ្លួនបានជួបប្រទះ ឬ ជួយអ្នកដទៃ ជាពិសេស សុជន ឲរួចខ្លួនពី អំពើការជិះជាន់ពីសំណាក់ជនទុច្ចរិត មានអំណាច។

ដូច្នេះការប្រតិបត្តិ នូវសីលធម៌ ខ្មែរយើងតែងតែប្រតិបត្តិ ឲស្របតាមស្ថានភាពពិត ដែលមានកើតឡើង៖

- ការវាយតម្លៃ ពិត និង គិតពីប្រយោជន៍
- ការប្រុងប្រយ័ត្ន និង ការប្រមាណ ឲត្រូវ
- សកម្មភាពត្រូវនឹងកាលៈទេសៈ និង មានប្រយោជន៍។

គំនិតទាំងនេះ គឺ នៅក្នុងគោលបំណង ឲងាយស្រួល ដល់ការ ប្រតិតបត្តិ ដែលជា ខ្សែបន្ទាត់នៃ សីលធម៌ ប្រាកដនិយម ដែលមាននៅក្នុង ច្បាប់អប់រំខ្មែរ។

ប៉ុន្តែ ប្រាកដនិយម ដ៏ស្រស់ៗ ជាច្រើន នេះ វាមានលក្ខណៈជា អសីលធម៌ ដូច្នេះ សួរថា តើត្រូវធ្វើដូម្តេច អាចជៀសវាង កុំឲវា ធ្លាក់ចូលទៅក្នុងតែ **ការណ៍និយមសំរាប់យកមកប្រើប្រាស់**[38] ឬ ប្រើសំរាប់តែរកប្រយោជន៍ ? ចម្លើយ នឹងសំណួរ នេះ គឺស្ថិតនៅលើ ការបិនប្រសព ប្រកបដោយទេពកោសល្យ របស់ កវីសីលធម៌និយម ក្នុងការឆ្នៃ ការណ៍និយម ឲក្លាយជា វាចារវិទ្យា ប្រកបដោយគុណធម៌ និង សុភនិច្ឆ័យ។ តែជួនកាល កវីទាំងនោះ គាត់ទ័លច្រកដែរ ព្រោះគាត់មិនចង់យក បរមត្ថវិជ្ជា មកធ្វើជាដំណោះស្រាយ ក្នុងបញ្ហាដែលចោទឡើង សុខចិត្តប្រតិស្ឋាន ក្នុង ការពិតនៃសង្គម ដែលប្រកបទៅដោយ បដិវាទកម្ម គ្មានចម្លើយ។

38 កាណ៍និយមសំរាប់តែយកមកប្រើប្រាស់= Pragmatisme utilisatrice។

តែជាសំណាងល្អមួយ នូវ ការសង្គ្រោះ សីលធម៌ខ្មែរ ពីសភាព ខ្យល់និយម ជា **អាស់ក្រាម**[39]និងអសីលធម៌ ដែលកវីខ្មែរគ្មានដំណោះស្រាយគឺ **ការបញ្ជោក**[40] នូវតម្លៃនៃ **គតិបណ្ឌិតប្រជាប្រិយ**[41] ដែលមាននៅក្នុងសង្គមខ្មែរច្រើនពាន់ឆ្នាំ មុនសម័យអង្គរមកម្លេះ។

ការបដិសេធ នូវ **ឧត្តមគតិនិយម អភិសមាចារ**[42] ការស្អប់ខ្ពើម នូវ **សន្ទុះ គ្មានការពិសោធ ឬ អាទកំបាំង**[43] និង បរមត្ថវិជ្ជា ជាមួយគ្នានឹង ការចូលចិត្ត នូវ ភាពពិតបញ្ជាក់បង្ហាញ មួយចំណែកនូវ លក្ខណៈ ការរីករាយ, ការចំអកឡកឡើយ និង ការកំប្លែងសួត ខ្មែរ។ មានជា ភស្តុតាង នៅក្នុង អក្សរសិល្ប៍ខ្មែរ ដូចជាអវត្តមាននូវ **សោកនាដកម្ម**[44] (រឿងកំសត់) និង **សុខនាដកម្ម** (រឿងកំប្លែង) ឬ សោកនាដកម្ម-សុខនាដកម្ម (រឿងកំសត់ លាយ កំប្លែង) ច្រើននោះដែរ។ សួរថា មកពីហេតុអ្វី ?

ដូចជា អច្ឆរិយៈ ឬ បរមត្ថវិជ្ជា, ទុក្ខសោក ចំពោះខ្មែរ ជា **អតិរេកភាព**[45] ហេតុនេះឯងបានជាអក្សរសិល្ប៍ខ្មែរ បដិសេធ នូវ អច្ឆរិយៈ អាទកំបាំង, សោកនាដកម្ម មែនទែន និង អតិរេកភាព ដទៃទៀត មាននៅក្នុង អារម្មណ៍, ការត្រិះរិះ[46] និង អំពើ នៃមនុស្សលោក។ នៅក្នុងរឿងកំសត់ នៃជនជាតិ grecque តួឯង ជាវិរបុរស តែងតែស្លាប់ជានិច្ចបន្ទាប់ពីបានធ្វើការតស៊ូ ក្រៃលែង នាំឲ្យអ្នកអាន មានការតានតឹងក្នុងចិត្ត ស្ទើរទ្រាំពុំបាន។

ឯចំណែក ក្នុងរឿងខ្មែរវិញ ដែលមាន ធម្មជាតិ រីករាយ, សុទិដ្ឋិនិយម, ចំអកឡកឡើយ, សើចសប្បាយ, ប្រាកដនិយម តែ មាន មនោសញ្ចេតនា ស្អប់ខ្ពើម នូវអំពើឃាតកម្ម។ ហេតុនេះឯងបានជានៅក្នុង អក្សរសិល្ប៍ នៃ សោកនាដកម្ម ឬ រឿងជីវិតពិត ខ្មែរយើង មិនងាយធ្លាក់ ក្នុងអន្ទាក់ នៃការកំសត់នេះឡើយ។ ធម្មជាតិ ដែលបានរៀបរាប់ខាង

---

39 អាស់ក្រាម= Vulgaire។
40 ការបញ្ជោក= Imprégnation។
41 គតិបណ្ឌិតប្រជាប្រិយ= Sagesse populaire។
42 ឧត្តមគតិនិយម អភិសមាចារ= Idéalisme moral។
43 សន្ទុះ គ្មានការពិសោធ ឬ អាទបំបាំង= Elan transcendantale។
44 សោកនាដកម្ម= Tragédie។ សុខនាដកម្ម= Comédie។
45 អតិរេកភាព= ភាពហួសកំណត់ ; Excès។
46 ការត្រិះរិះ= Pensée។

លើនេះជូនកាល នាំឲអ្នកអាន បែរជាសើច ដោយបង្ខំ នៃ ការកំសត់ របស់តួឯកទៅវិញ។ នេះ ជា អារម្មណ៍ នៃមនុស្ស គ្មាន បញ្ហា ឬ ជា មនុស្ស ទាល់ច្រក ក្នុង ជីវិតរស់នៅ ឬ មកពី ភាពកំសត់នោះ វាមានភាពហួសហេតុពេក។

ជានិច្ចកាល អតិរេកកម្ម និង **អច្ចន្តភាព**[47] គ្រងជា តម្លៃ អវិជ្ជមាន នៅក្នុង អក្សរសិល្ប៍ខ្មែរ។ គេសង្កេតឃើញថា តួអង្គនៅក្នុងរឿងខ្មែរ យំ រហ័យណាស់ ជូនកាល រហូតដល់សម្លប់តែម្តង ហើយអ្នកនិព័ន្ធពិពណ៌នា ការសូរយំអណ្តឺតអណ្តន់ នេះ ជូនកាលមួយទំព័រទាំងស្រុង។ តែទឹកភ្នែកនេះ ជូនកាលមិនមែនជា ការយំ ពីទុក្ខនោះឡើយ តែជាសញ្ញានៃសេចក្តីត្រេកអរ ក្នុងសុភមង្គល ណាមួយ។ ដូច្នេះ តួអង្គ ក្នុងរឿងខ្មែរ គាត់យំព្រោះមានទុក្ខផង និង យំព្រោះជួបប្រទេះនឹង សេចក្តីសុខផងដែរ។ ទឹកភ្នែក សំរាប់ខ្មែរ មានតួនាទី ជា **សរីរសាស្ត្រ**[48] ច្រើនជាង ជា **សោភ័ណ**[49]។ សួរថា តើសេចក្តីរីករាយដូចគ្នានឹងការឈឺចាប់ គ្មានភាគដើម (seuil) នៃ ចិត្ត-សេរីរៈ[50] តាមផ្លូវនេះ នាំឲកំប្លែងអាចទៅជា កំសត់ ឬ កំសត់ អាចទៅជា កំប្លែង វិញដែរ ? ចំណុចនេះ អាចពន្យល់បានអំពីទម្រេត របស់ខ្មែរ ទៅក្នុង សោកនាដកម្ម-សុខនាដកម្ម (យំផង សើចផង) ដូចមាននៅក្នុង៖

- ភាពអណ្តែតអណ្តូង នាំមកនូវទឹកភ្នែក តែ មានសំណើច ;

- ភាពរំជួលចិត្ត តែគ្មានមរណភាព និង គ្មាន «ទុក្ខប្រចាំជីវិត» ;

- ភាពអន្លង់អន្លោច តែគ្មាន ភាពសង្រេងសង្រៃ ហើយបញ្ឈាន់ជាថ្មី ដែលសម្លាប់ បន្តិចម្តងៗ ឲក្ស័យចិត្ត !

ដោយគិតតែពីសម្រក់ទឹកភ្នែក ដើម្បីរក សមតា នូវ ចិត្ត-សេរីរៈ គេលែងដឹងថាតើសម្រែកយំ នោះ វា ពិតប្រាកដមែនដែរឬទេ។ តែនៅក្នុងរឿងទុំទាវមាន ភាពប្រក្រតិព្រោះ ជារឿង សោកនាដកម្ម គួរឲរន្ធត់ ពិតប្រាកដ ដែលពិបាកនឹងយល់ស្របបាន

---

47 អច្ចន្តភាព= ហួសក្រៃពេក ; Extrême។
48 សរីរសាស្ត្រ= Physiologique។
49 សោភ័ណ= Esthétique។
50 ចិត្រ-សេរីរៈ= Psycho-physiologique។

ចំពោះខ្មែរ។ ទុំ និង ទាវ មិនប្រពៃ យកសេចក្ដីស្នេហាគ្នា តាមចិត្តស្រឡាញ់[51] ហើយយក សេចក្ដីស្លាប់ដាច់ខាត ជា ចម្លើយ ចំពោះមុខបញ្ហា ដែលខ្លួនបានជួបប្រទះ។ ភាពអច្ឆរិយ ហួសហេតុ នេះហើយ ដែលខ្មែរមិនសូវអោយតម្លៃ ដល់សេចក្ដីស្នេហា រវាង នេនទុំ និងនាង ទាវ ថាជា សេចក្ដីស្នេហា មិនគួរយកជាគំរូ ដែលនាំអោយមាន ការអត់អោន ខ្លះដល់អ្នកធ្វើឃាត ដល់គូរស្នេហ៍។ ហេតុនេះឯង បានជា យុវជនខ្មែរ មិនដែលទុកទុំ និងទាវ ជា វរបុរស និង វរនារី ហ៊ានបូជាជីវិត សំរាប់ សេចក្ដីស្នហា ពិមល នេះឡើយ។ មិនតែប៉ុណ្ណោះ ជួនកាល រហូតដល់ចោទ ទុំ ថាជា មនុស្ស គ្មានការទទួលខុសត្រូវ ព្រោះ យក សេចក្ដីប្រថាន់ ហួសហេតុ ដាក់ក្នុងចិត្ត ផឹកសុរា ស្រវឹង នាំឲខ្លួនភ្លេចអស់ នូវ បញ្ហាស្ដេចជាលាយលាក់អក្សរ ដែលជាអាជ្ញា សំរាប់ រំដោះ នាង ទាវជា ភរិយា ពី អំណាចមាតារបស់នាង។ ហេតុនេះឯង បានជាមាន មតិខ្លះ ទុក មរណភាព ទុំ និង ទាវជា មរណភាពឥតប្រយោជន៍ មិនគួរយក តម្រាបតាម។

រឿងនេះ ក៏ដូចគ្នានឹង នាង សុីតា ខឹងនឹង ស្វាមី (ព្រះរាម) បញ្ចប់នូវ ការរក សព្វ ការសម្របសម្រួល ជាដាច់ខាត ជាមួយស្វាមី ព្រោះតែព្រះអង្គ ចោទប្រកាន់ដល់រូបនាង ថាធ្លាប់សេពមេថុធម្ម ជាមួយ រៀប ជាស្ដេចយក្ស។ ការបដិសេធ នេះ ដែលខ្មែរ ភាគច្រើន មិនទុក នាង សុីតា ជា វីរនារី ក្នុងរឿង រាមកេរ៍ខ្មែរ។

---

51 ស្នេហាតាមចិត្តស្រឡាញ់= Coup de foudre។



## កម្លាំងខ្មែរ

# បញ្ញវន្តខ្មែរ នៅលើផ្លូវ លទ្ធិប្រជាធិបតេយ្យ (១៩៤៥-១៩៥៦)

ដើមគំនិត នៃគំនិត អ្នកជាតិនិយមខ្មែរ កើតចេញ ពី សាព័ទ្ធមាន «អង្គរវត្ត»ដូច្នេះគឺ កើតចេញ ពី បញ្ញា។ ពន្លឺបញ្ញានេះហើយ ជាប្រភព នៃ **បស្សាសៈ** (inspiration) នៃអ្នកស្នេហាជាតិខ្មែរ។

**អ្នកស្នេហាជាតិខ្មែរ**

វណ្ណកម្មប្រកបដោយ មនសិការជាតិ នៃសារពត៌មានអង្គរវត្តជាស្នាដៃរខ្មែរគ្រប់ស្រទាប់ ដែលមានបញ្ញាវន្តមួយក្រុមជាអ្នកនាំផ្លូវ ក្នុសកម្មភាពនៃសេក្តីស្នេហាជាតិ។ អ្នកនាំផ្លូវ ទាំងនោះមានឈ្មោះ ភិក្ខុ ហែម ជៀវ, ខៀវ ជុំ, ប៉ាង ខាត់, លោក ស៊ឹម វ៉ា, ទេព ប៉ាន់, ឈៀង លៀង, មឹច ណាត្រី, ងោ ហុង, ជុំ មួង, នួន ដួង, ប៉ុណ្ណ ចន្ទម៉ុល។ វណ្ណកម្មនេះ ជារងើកភ្លើងក្នុងគតិខ្មែរ ត្រូវខ្យល់កាលណា ច្បាស់ជាឆាបឆេះជា អណ្ដាតភ្លើង ដែលជា ឋាមពល សំរាប់ដុតឲ មាស៊ីនជាតិខ្មែរ ដើរទៅមុខ។ ដំណើរនេះ មានកើតឡើងក្នុងឆ្នាំ១៩៤២។ ភ្លាមនោះ មានខ្មែររាប់ពាន់នាក់ ជាខ្មែរអ្នកស្នេហាជាតិ នាំគ្នាធ្វើបាតុកម្មនៅទីក្រុងភ្នំពេញ ប្រឆាំងនឹងបារាំង ធ្វើការទាមទារឲអាជ្ញាធរ ដោះលែងភិក្ខុ ហែម ជៀវដែលគិញបារាំង គេចាប់ឃុំ ដោយចោទថាប្រឆាំងនឹងបារាំង។

«ថ្ងៃជ័យត្រូវចងចាំ ព្រោះជាថ្ងៃប្រវត្តិសាស្ត្រសំរាប់ប្រជាជាតិខ្មែរ គឺ ថ្ងៃទី២០ កក្កដា ឆ្នាំ ១៩៤២ មានក្បួនដង្ហែរ មួយយ៉ាងវែង មានអ្នកក្លាហានដើរក្នុងជួរ មានអ្នកបញ្ញវន្ត ដើរពីមុខ គឺ លោក ស៊ឹង ង៉ុកថាញ់ និង ប៉ាច ឈឿន នាំគ្នាដើរទៅមុខ មានទឹកមុខជា ជាអ្នកស្នេហាជាតិ ហើយនាំគ្នាស្រែកតវ៉ា ឲបារាំងដោះលែង ភិក្ខុ ហែម ជៀវ តែបារាំងបិទផ្លូវ រួចស្រែកកំញោញ កុំហោក ដោយកំហល់ ឲខ្មែរខ្លាច តែខ្មែរមិនញញើត រុកចូលទៅមុខជានិច្ច ពួកភិក្ខុ យកឆ័តបុកសម្រុក ឲតែឈ្នះបានទៅមុខ ពួកបារាំង និង ប៉ូលិសខ្មែរ ភ័យនាំគ្នាថយ នៅពេលទាល់ច្រក គេបាញ់កាំភ្លើងដៃទៅលើមេឃ ដើម្បីកំញោញ។ លើកនេះខ្មែរភ័យម្ដង នាំគ្នារត់ តែបារាំង តាមដេញចាប់អស់មួយយប់ ហើយចាប់បាន ភិក្ខុ ប៉ាង ខាត់ និង លោក ប៉ុណ្ណ ចន្ទម៉ុល រួចគេនាំភ្លាម ទៅស្រុកយួន បន្ទាប់មកកាត់ទោសដាក់គុកនៅកោះត្រឡាច ឯចំណែកអ្នកឯទៀត នាំគ្នារត់រួចទៅ បួនលាក់ប្រាណតាមកន្លែងរៀងៗខ្លួន។ លោក ស៊ឹង ង៉ុងថាន់ រត់ទៅប្រទេសជប៉ុ

ន។ ភិក្ខុ ហែម ចៀវ ព្រះអង្គ បានទទួលមរណៈភាព យ៉ាងអាណោចអាធម្ម ជាទីបំផុត នៅក្នុងគុកបារាំង ដោយជម្ងឺ ឥតបានទទួល ការព្យាបាលអ្វីទេពីបារាំង។ មរណៈភាព នៃវិរបុរស ហែម ចៀវ គឺជាឃាតកម្ម ដោយចេតនា ដែលយើងអាចចាត់ទុកជា បទឧក្រិដ្ឋ ប្រឆាំងនឹងមនុស្សជាតិ។

ពេលនោះ បារាំងបានឈ្នះកម្លាំងខ្មែរមែនពិត គេឲ្យភ្នាក់ងារប៉ូលិសគេ ទៅវាយបំផ្លាញ ការិយាល័យ និង រោងពុម្ពកាសែតអង្គរវត្ត ប៉ុន្តែគេពុំអាចកំទិច គំនិតស្នេហាជាតិខ្មែរ បាននោះឡើយ។ ប្រទេសបារាំងចាប់ពីឆ្នាំ១៩៤០ រស់ក្នុងរបបផ្តាច់ការ ក្រោមការ ត្រួតត្រាប្រទេសអាឡឺម៉ាញណាស៊ី ព្រោះ «សាធារណរដ្ឋបារាំង» ចាញ់សង្គ្រាមគេ។ កាល នោះ អាជ្ញាធរបារាំងនៅឥណ្ឌូចិន បានធ្វើសច្ចាប្រណិធាន ស្មោះត្រង់ចំពោះលោក សេនាប្រមុខ ប៉េតាំង ប្រមុខរដ្ឋថ្មី នៃ «រដ្ឋបារាំង» តែនៅឥណ្ឌូចិន ត្រូវបានកងទ័ពរាជាធិរាជ ជប៉ុន កាន់កាប់ ស្របទៅតាមសទ្ធិសញ្ញាសហប្រតិបត្តិការ «ជប៉ុន បារាំង» ធ្វើឡើងរវាង អាជ្ញាធរបារាំង នៅឥណ្ឌូចិន នឹង កងទ័ព បេសនកម្ម ជប៉ុន នៅអាស៊ី។

លោក **ដឺវីលែស**, អ្នកប្រាជ្ញបារាំងល្បីមួយ នៅប្រទេសបារាំង, គាត់សរសេរដោយភ្លេចខ្លួន ភ្លេចគិត ធ្វើឆ្ងល់ ចម្ងល់ ថា «**បើថា អាណានិគម អាក្រក់នោះ ចុះហេតុអ្វី បានជានាំគ្នាយកធ្វើជាគំរូ**» ក្រោយពីប្រទេសអាណានិគមទទួលបានឯករាជ្យ។ គំនិតនេះហើយ ដែលជាអំពើអាណានិគមនិយម មួយ ដែលបានវាយបំបាក់ គំនិត បញ្ញា របស់ ជនជាតិ រស់ នៅក្រោមអំណាចអាណានិគម ដែល លោក ដឺវីលែស ទុកជាជនជាតិ «ខ្ញុំគេ»។ អានប្រយោគនេះកាលណា ធ្វើឲខ្ញុំមានការឆ្ងល់ស្រឡាំងកាំង រួចហើយ មានការអាណិតអាសូរ ទៅវិញ ដល់ លោក ដឺវីលែស ដែលលោក មានតួនាទីជាបញ្ញវន្ត។

ត្រូវដឹងថា នៅស្រុកខ្មែរ ក្នុងរយៈពេល៩០ឆ្នាំ អាជ្ញាធរ បារាំង បង្កើតបាន វិទ្យាល័យ តែមួយគត់ សំរាប់ យុវជនខ្មែរ ហើយបើខ្មែរ បង្កើតចលនាយុវជន លោក អគ្គទេសាភិបាល ប្រចាំនៅឥណ្ឌូចិន លោក ដឺគូ គាត់តែងតាំង វិរសេនីយ៍ឯក បារាំងម្នាក់ ឈ្មោះ ឌុកូរ៉រ ឲត្រួតមើលចលនានោះ ថែមទៀត។ យើងឃើញថា អាជ្ញាធរ បារាំង បិទជិត នូវអ្វី ដែល ទុកជាសេរីភាព សំរាប់ប្រជាជន ជាពិសេស សំរាប់ យុវជន។

ដល់ លោក ដឺវីលែស ធ្វើឆ្ងល់ ចម្ងល់នេះ បង្ហាញ បន្ថែមនូវភាព ក្រអឺតក្រអោងមួយ ទៀត ដូចជាគាត់ ចង់និយាយចំអក។ តែលោកភ្លេចគិតថា បើមិនយកធ្វើគំរូ តើខ្មែរ នៅមានសល់អ្វីទៀត ដែលជា បញ្ញាខ្មែរ នៅក្រោម របប អណានិគម ព្រោះអាជ្ញាធរ បារាំង តាំងខ្លួនជាចៅហ្វាយ និង គ្រូដាច់មុខ បង្ខំឲរៀនភាសា ឲស្លៀកពាក់ ឲធ្វើផ្ទី តាមខ្នាតបារាំ។ ចរិយាសម្បត្តិ ដែលបារាំង គេទុកជា អ្នកបម្រើល្អ ទី១. ត្រូវចេះគោរព

កោតក្រែង ទី២. ត្រូវចេះភាសាបារាំង ទី៣. ត្រូវធ្វើ ថ្លង់ គ ខ្វាក់ ទី៤. ត្រូវហ៊ានវៃរាស្ត្រឯង ទី៥. ត្រូវដឹងគុណ និង ចេះអស់គុណគេ។ នេះហើយជាធម៌៥ ដែលរជនខ្មែរ ត្រូវរៀនសូត្រឲចាំ ដើម្បីផ្តិតក្នុងគំនិត ជាចិរកាល ព្រោះថា បើមិនចាំទេ គេមិនទទួលស្គាល់ខ្លួន ជាបញ្ញវន្តថ្មី ក្នុងខ្នាត ជាបាវបំរើគេនោះទេ។ ដូច្នេះ គំរូ អាណានិគម ថិតនៅក្នុងគំនិត របស់ អ្នកចេះដឹងខ្មែរជានិច្ច ដូច លោក ដឺវីលែស សរសេរ តាំងពីឆ្នាំ១៩៦១ មកម្លេះ។សួរថា អ្នកស្នេហាជាតិខ្មែរ កើតចេញពីពុម្ព អាណានិគមនិយម នោះឬ ?

ក្នុងវណ្ណកម្ម របស់ អ្នកស្នេហាជាតិខ្មែរ យើងឃើញមានការដូរន័យក្នុងការសេសេរពីន័យបញ្ញើអ្នកធំ មកក្នុងឧបទេស ដល់ប្រជារាស្ត្រខ្មែរ ឲមាន សេចក្តីសង្ឃឹមលើកម្លាំងរបស់ខ្លួន។

អាជ្ញាធរ អាណានិគម យល់ច្បាស់អំពីគ្រោះថ្នាក់ នៃលក្ខណៈសម្បត្តិនេះ ព្រោះជនជាតិខ្លួនជា អ្នកបង្កើត បដិវត្តន៍ ឈរលើបញ្ញា តាំងពីសតវត្សទី១៨មកម្លេះ។ គេបិទការសែត គេបាញ់សម្លាប់ អ្នកចេះដឹងខ្មែរ ក្នុងគោលបំណងតែមួយគត់ គឺលុបចោលនូវ «**សេចក្តីសង្ឃឹមខ្មែរ**» ពីព្រលឹងខ្មែរ។ យើងដឹងថា សេចក្តីសង្ឃឹម របស់មនុស្ស ជា សទ្ធិ ដែលធម្មជាតិ បង្កើតឲមនុស្ស ទុកវាជាកូនសោ សំរាប់បើកទ្វាររ រកចម្លើយដោះស្រាយគ្រប់បញ្ហា ដែលមាននៅក្នុងជីវិតរបស់មនុស្ស។ ក្នុងសម័យអាណានិគម បញ្ហារបស់ជាតិ គឺ «ឯករាជ្យជាតិ» ដែលជាកម្មសិទ្ធិ របស់ប្រជាពលរដ្ឋនិមួយៗ ឥតមាននរណាអាចទិញដូរបាននោះឡើយ។ ក្នុងពេលដែលជាតិមាន ឯករាជ្យ បញ្ហារបស់ជាតិ គឺបញ្ហាការកសាងសង្គមជាតិ ឲមានភាពក្សេមក្សាន្ត។ ការកសាងសង្គមជាតិថ្មី នេះ រុញឲបញ្ញវន្ត ចូលរួមកម្លាំងបញ្ញា ធ្វើការពិភាក្សា ជាមួយ អ្នកដ៏ទៃទៀត ដើម្បីរកជូនដល់ ប្រជាពលរដ្ឋ នូវរបៀបសង្គមជាតិមួយ ដែលនាំបង្កើត ឲមានសុខដុមរមនា។ ក្នុងការពិភាក្សានេះ អ្នកខ្លះ លើកយក ខ្លឹមលក្ខណៈសម្បត្តិ នៃសង្គមចាស់មកធ្វើការរិះគន់ អ្នកខ្លះទៀត ទុក សង្គមចាស់ ជាមូលដ្ឋានជាតិ។ ការដាក់ចែកដោយឡែក (Typologie) ក្នុងការពិភាក្សានេះ អ្នកប្រាជ្ញ ផ្នែកមនុស្សវិទ្យា បានបែងចែក ជាពួក ពីរគូរ៖ «បញ្ញា-ប្រាជ្ញា» និង «អ្នកកែប្រែ-អ្នកបញ្ចូល»។

(កំណត់ក្នុងការប្រើពាក្យ៖ បញ្ញា= Intellect ; ប្រាជ្ញា= Intelligence ; អ្នកកែប្រែ= Innovateur ; អ្នកបញ្ចូល= Intégrateur)។

**បញ្ញា**៖ បង្ហាញ នូវគំនិតរិះគន់ និង គំនិតបង្កើត ; **ប្រជ្ញា**៖ បង្ហាញ នូវគំនិតការណ៏និយម (pragmatisme) និង គំនិតការប្រមាណ ; **អ្នកកែប្រែ**៖ គឺគំនិតឈរលើអ្វីដែលថ្មី ; **អ្នកបញ្ចូល**៖ គឺគំនិតឈរលើការថែរក្សាអ្វី ដែលមានរួចហើយ។ បើនិយាយ ឲខ្លី ពួកពីរ

គូរនេះ គឺ មួយជាពួក «អ្នកសម័យនិយម» ហើយពួកមួយទៀតជាពួក «អ្នកអភិរក្សនិយម» នោះឯង។

ក្រោយពីចប់សង្គ្រាមលោក លើកទី២មក ពិភពលោក បានចែកជាពីរ ប្រតិព័ន្ធ (bloc) ៖ ប្រតិព័ន្ធសេរី និង ប្រតិព័ន្ធកុម្មុយនិស្ត។  សង្គ្រាមត្រជាក់ បានផ្ទុះឡើង រវាង ប្រតិព័ន្ធទាំងពីរនេះ ដែលនាំឲមានការលំបាកដល់ប្រទេសតូចៗ ក្នុងជម្រើសយក មហាអំណាចមួយ មកធ្វើជាសម្ពន្ធមិត្ត ដោយគ្មានការនាំបង្កើត បញ្ហាផ្ទៃក្នុង ក្នុងប្រទេសខ្លួន។ នៅ ឥណ្ឌូចិន ក្រោយពីជប៉ុនចាញ់សង្គ្រាម កងទ័ព សម្ពន្ធមិត្ត អនុញ្ញាត ឲទ័ពបារាំងសេរី ត្រឡប់មកឥណ្ឌូចិនវិញ ដើម្បីដកហូតអាវុធ ពីកងទ័ព ជប៉ុន។  លោក ឧត្តមសេនីយ ឡឺក្លែរ៍ ជានាយកទ័ពបារាំង មកដល់ស្រុកខ្មែរភ្លាម ឥតបានសួរឲដឹងច្បាស់ អំពីសន្ដានភាពនយោបាយ នៅស្រុកខ្មែរនោះឡើយ ជាបន្ទាន់ លោក បញ្ជាឲទាហ៊ានលោក ចាប់ លោកស៊ឹង ង៉ុកថាន់ នាយករដ្ឋមន្ត្រីខ្មែរ (១៥តុលា១៩៤៥) និង អ្នកស្នេហាជាតិ ជាច្រើននាក់ទៀត ពីបទចូលដៃនឹង ជប៉ុន ប្រឆាំងនឹង ទ័ពសម្ពន្ធមិត្ត ក្នុងពេលសង្គ្រាម។ លោកឧត្តសេនីយនេះ ភ្លេចគិតថា អ្នកដែលចូលដៃជប៉ុន គឺ អាផ្ទាធរអាណានិគមឯនោះទេ តែពួកទាំងនោះបែរជារួចខ្លួន ហើយនៅបន្តត្រួតខ្មែរដដែល។

តែទោះបីយ៉ាងណា ខ្យល់សេរីភាព បានបក់មកដល់ស្រុកខ្មែររួចហើយ ដែលធ្វើឲបារាំងពិបាក ធ្វើអ្វី បានដូចចិត្ត ដូចពីដើម ព្រោះខ្លួនលែងមានថេស្ដាជាមហាអំណាចអាណានិគម នៅក្នុងពិភពលោកថ្មី ដែលមាននិន្នាការ គោរពលើ សិទ្ធិស្វ័យប្រណិធាន នៃ ប្រជាពលរដ្ឋនិមួយៗ លើវាសនារបស់ខ្លួន។  ក្នុងនិន្នាការថ្មីនេះ បារាំង ចាប់បាច់ ត្រូវ ធ្វើកិច្ចសញ្ញាបណ្ដោះអាសន្នថ្មីមួយ សំរាប់លុបចោល នូវសិទ្ធិសញ្ញាឆ្នាំ១៨៦៣ និង ១៨៨៤ រវាង បារាំង-ខ្មែរ។  ក្នុងកិច្ចសញ្ញានេះបារាំង ទទួលស្គាល់ស្រុកខ្មែរ ជាប្រទេសមាន ស្វ័យរាជ្យនៅក្នុង សហពន្ធបារាំង (៧ មករា ១៩៤៦)។

អនុលោម ស្របតាម លក្ខន្តិកៈថ្មី របស់ស្រុកខ្មែរ នៅក្នុងថ្ងៃទី ១៥ មេសា ឆ្នាំ១៩៤៦ រាជរដ្ឋាភិបាលខ្មែរ បានប្រកាសក្រម (ច្បាប់) ជាច្រើន ក្នុងគោលបំណង ផ្ដល់សេរីភាពដល់ ប្រជារាស្ត្រ ក្នុងព្រះរាជ្យអាណាចក្រ ដូចយ៉ាង៖ សេរីភាពនយោបាយ សេរីការសែត សេរីភាពប្រជុំជាសាធារណ: និង សេរីភាពបង្កើតសមាគម។  ជាលើកទី១ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលប្រជារាស្ត្រ ឮពាក្យ សេរីភាព ជា សិទ្ធិ របស់ខ្មែរម្នាក់ៗ ដែលមានច្បាប់សំរាប់ការពារ។  នេះជាជំហ៊ានទី១ដែរ ដែលរដ្ឋខ្មែរ ប្រែក្លាយជានីតិរដ្ឋ រៀបគ្រោងការ ធ្វើ ការបោះឆ្នោត តែងតាំងសភាជម្មនុញ្ញ ដើម្បីតាក់តែច្បាប់កំពូល របស់រដ្ឋ ដែលហៅថា

ច្បាប់រដ្ឋធម្មនុញ្ញ។ គណបក្សនយោបាយធំបី ដាក់លក្ខន្តិកៈ ដើម្បីចូលរួមក្នុងការបោះឆ្នោត៖ គណបក្សប្រជាធិបតេយ្យ គណបក្សសេរីភាព និង គណបក្សវឌ្ឍននិយម។

ក្នុងដំណើរលើផ្លូវនៃលទ្ធិប្រជាធិបតេយ្យនេះ ត្រូវបាន អ្នកទទិដ្ឋិនិយម ទាំងខ្មែរ និង បារាំង បាននិយាយប្រាប់ទុកថា ការបោះឆ្នោតជាសេរីនេះ អាចបង្កើតជា បញ្ហាច្រើន ដល់ប្រទេសខ្មែរ ដែលមិនធ្លាប់ស្គាល់ថាអ្វីទៅ ដែលជារស់ជាតិ នៃលទ្ធិប្រជាធិបតេយ្យ។ តែអ្នក សុទ្ធិដ្ឋិនិយមវិញ មានជំនឿថា អ្វីក៏ដោយ ត្រូវមាន ជំហ៊ានទីមួយជានិច្ច ប្រជារាស្ត្រខ្មែរ មិនមែន ជាប្រជារាស្ត្រ ឥតស្គាល់អ្វីដែលហៅថា អារ្យធម៌នោះឡើយ។ ជនជាតិដែលមានអារ្យធម៌ ជាជនជាតិ មានធម្មជាតិ ជាជនជាតិ មានស្វ័យអភិវឌ្ឍន៍។ បញ្ហាដែលសំខាន់នោះ គឺធ្វើយ៉ាងណា បង្កើតឲមានបរិយាកាសមួយ សំរាប់ឲ ស្វ័យអភិវឌ្ឍន៍ ផ្នែកសេរីភាព ឲអាចដុះដាលកើតមានឡើងបាន។

លទ្ធផល នៃការបោះឆ្នោតលើកទិ១ បង្ហាញថា អ្នកសុទិដ្ឋិនិយម មានជំនឿ លើប្រជាពលរដ្ឋខ្មែរ ក្នុងការជ្រើសរើស តំណាងរាស្ត្រខ្លួន ដើម្បីទៅរៀបចំតាក់តែងច្បាប់រដ្ឋធម្មនុញ្ញ ជាការភ្ញាល់មួយប្រកបដោយជោគជ័យ។ គណបក្សប្រជាធិបតេយ្យ ជាគណបក្សឈ្នះឆ្នោត ជាអ្នកមានអំណាច តាក់តែងច្បាប់កំពូលជាតិ ដោយផ្អែកទៅលើ គោលការណ៍ លទ្ធិប្រជាធិបតេយ្យសេរី។ ស្នាដៃនេះ ជាស្នាដៃ របស់ បញ្ញវន្តខ្មែរ ជំនាន់នោះ ដែលមានឈ្មោះគួរចងចាំទុកជាវិរបុរស៖ ទ្រង់ យុទ្ធវង្ស, លោក ឈៀងវ៉ម, ធុន អ៊ុក, ឆិន ការរេត, អ៊ីវ កើស, ហាក់ ម៉ុងសេង ។ ល។

លោក គៀង គុន នៅក្នុង និក្ខេបបទ សំរាប់សញ្ញាប័ត្របណ្ឌិត[52] មានចំណងជើងថា « វិបត្តិខ្មែរ» លោក ធ្វើការរិះគន់ ច្បាប់ធម្មនុញ្ញ ឆ្នាំ ១៩៤៧ ដែលតាក់តែង ដោយ សភាធម្មនុញ្ញ ដែលមានអ្នកឯកទេសបារាំង ជាច្រើន ជាទីព្រឹក្សា ថាជាច្បាប់ធ្វើឡើង ដោយ មិនយកការពិតខ្មែរមកធ្វើជាយោង ហើយជាច្បាប់ចំឡងទាំងស្រុង ពីច្បាប់រដ្ឋធម្មនុញ្ញបារាំង ជំនាន់សាធារណរដ្ឋទី៣ ហេតុនេះឯង បានជាច្បាប់នេះ គ្មានប្រសិទ្ធិភាពនិង គ្មានផលអ្វីសំរាប់ខ្មែរនោះឡើយ ព្រោះជាច្បាប់ គ្មានធាតុជាខ្មែរ។ ទស្សនៈ លោកបណ្ឌិត គៀង គុន ជាផ្លូវបែកពីរ នៃទស្សនៈនយោបាយខ្មែរ មាននៅពេលដែលស្រុកខ្មែរបាន ទទួលឯករាជ្យ ហើយក៏ជាមូលដ្ឋានមួយ របស់ពួកអ្នកឆ្វេងនិយមខ្មែរ ដែរ។ ការវិភាគ

---

[52] មហាវិទ្យាល័យនៅប្រទេសបារាំង ឆ្នាំ១៩៥៤។

នេះ មានត្រូវ មានខុស ដែលអាចយកមកធ្វើជាប្រធានបទមួយ សំរាប់សិក្សាជាជម្រៅ ដើម្បីស្វែងរកភាព វិជ្ជមាន និង អវិជ្ជមាន នៃនិក្ខេបបទនេះ។

នៅស្រុកខ្មែរ ក្រោយឆ្នាំ ១៩៤៥ ក្នុងមជ្ឈដ្ឋាន បញ្ញវន្ត មាន និន្នាការ លទ្ធិនយោបាយធំបីៈ ក្រុមអ្នកអភិរក្សនិយម ក្រុមអ្នកប្រជាធិបតេយ្យ និង ក្រុមអ្នកវឌ្ឍននិយម។ ក្រុមនិមួយៗ គេមានទស្សនៈលើធាតុសង្គមខ្មែរ ខុសគ្នាៈ

**ក្រុមអ្នកអភិរក្សនិយម**ៈ យល់ឃើញថា សង្គមខ្មែរ ជា «**សង្គមប្រពៃណី**» ធាតុនេះ អាចទុកជា គុណសម្បត្តិមួយរបស់សង្គម ជាមូលដ្ឋាន សំរាប់ រក្សាស្ថិរភាពសង្គម។ ស្ថិរភាពនេះ មានឫសពីរ គឺៈ រាជានិយម និង ពុទ្ធសាសនា ដែលជាមុំធ្វើឲសង្គម មាន សមតា។ អ្វីដែលត្រូវធ្វើសំរាប់អានាគតជាតិ ត្រូវយកមុំពីរនេះ ជា ទម្រ ព្រោះរាជានិយម ជាតំណាង នៃប្រពៃណី ឯចំណែក ពុទ្ធសាសនា វិញ ជាតំណាង នៃវប្បធម៌ជាតិ។ ប្រពៃណី ជាអង្គកាយ របស់ជាតិ រីឯ ពុទ្ធសាសនាវិញ ជាព្រលឹងជាតិ បើសិនគ្មានធាតុទាងពីរនេះទេ គឺមិនអាចឲសង្គមខ្មែរ ពុំអាចការចំរើនលូតលាស់បាននោះឡើយ។

**ក្រុមអ្នកប្រជាធិបតេយ្យ**ៈ យល់ឃើញថា សង្គមខ្មែរ មានធាតុជា «**សង្គមសក្តិភូមិ**»ធាតុនេះជាឧបសគ្គ នៃការជឿនលឿន របស់សង្គមខ្មែរ។ ស្ថិរភាពសង្គមសក្តិភូមិ ជាស្ថិរភាពសំរាប់ បំរើអ្នកកាន់អំណាច ដែលគេទុកជា ស្ថិរភាពអវិជ្ជមាន នាំបង្កើតឲមានអយុត្តិធម៌ និង វិសមភាព ក្នុងសង្គម។ ដូច្នេះ អ្វីដែលត្រូវធ្វើសំរាប់ អានាគតជាតិ ត្រូវចាំបាច់ ធ្វើកែទម្រង់ ដកហូតអ្វី ដែលមិនល្អ ហើយ បញ្ចូលអ្វីដែលល្អ ដើម្បីលំអសង្គម។ បដិរូបការនេះ ជាផ្លូវ នៃសេចក្តីចម្រើនមួយ ធ្វើឲសង្គម ក្លាយជាសង្គមសម័យឈរលើលទ្ធិប្រជាធិបតេយ្យ ដែលជាលទ្ធិនយោបាយ ទុកប្រជាពលរដ្ឋ ជាម្ចាស់ នៃអំណាច។

**ក្រុមអ្នកវឌ្ឍននិយម**ៈ យល់ឃើញថា សង្គមខ្មែរ មានធាតុជា «**សង្គមចោលម្សៀត**» ធាតុសង្គមបែបនេះ ត្រូវចាំបាច់ រំលាយចោល ព្រោះឥតអាចកែតម្រូវបានឡើងវិញឡើយ។ត្រូវមានបដិវត្តន៏មួយ ដើម្បី រៀបចំបង្កើត សង្គមថ្មី ក្រោមការណែនាំ នៃអំណាចបដិវត្តន៏។ ត្រូវទុក សង្គមថ្មី ជា សត្រូវនឹង សង្គមចាស់ ដែលមានកំអែល ជាសង្គមអវិជ្ជមាន។កំអែលបី សំរាប់ប្រជាជន គឺៈ រាជានិយម ទុកជាបន្ទុកធំ របស់ប្រជាជាតិ, ពុទ្ធសាសនាជា ជំនឿឥតប្រយោជន៏ សំរាប់ការរស់នៅ របស់ប្រជាជន ជាអាភៀន នាំបំផ្លាញប្រាជ្ញាមនុស្ស ឯចំណែកប្រពៃណី វិញ ជា «ផ្សិតមានធាតុពុល» ត្រូវដុតកំទេចចោល ដោយប្រើភ្លើងបដិវត្តន៏។

## សាលា «គំនិតជាត» របស់ បញ្ញវន្ត

នៅដំបន់អាស៊ី ក្នុងដើមសតវត្សទី២០ មានព្រឹត្តិការណ៍ធំពីរ កើតមានឡើង៖ ១. ជ័យជំនះកងទ័ពជប៉ុន លើកងទ័ពរុស្ស៊ី ក្នុងឆ្នាំ ១៩០៥ ; ២. ការរំលំរបបរាជានិយមអាជ្ញាសិទ្ធិ នៅប្រទេសចិនក្នុងឆ្នាំ ១៩១១ ហើយបន្ទាប់មក មានបង្កើត របបសាធារណៈរដ្ឋ។ ព្រឹត្តិការណ៍ទាំងពីរនេះ នាំដាស់ទឿន សតិសម្បជញ្ញៈ ប្រជាជនអាស៊ី ឲមានជំនឿថាខ្លួនអាចឈ្នះលើ មហាអំណាច និងអាចរំលំ របប រាជានិយម អាជ្ញាសិទ្ធិ បាន។ គេអាចទុកព្រឹត្តិការណ៍ទាំងពីរនេះ ជាការភ្ញាក់ឡើងដំបូង នៃប្រជាជនអាស៊ី ហើយមានចំហាយមកដល់ដំបន់ឥណ្ឌូចិន ដែលជាដើមប្រភព នៃចលនារំដោះជាតិ នៅវៀតណាម ដែលមាន លោក អៀង អៃកុក ហៅ ហូ ជីមិុញ ជាអ្នកដឹកនាំ ពីកោះ ហុងកុង ក្នុងនាមគណបក្សកុម្មុយនិស្ត បង្កើតឡើងក្នុងឆ្នាំ ១៩៣០ ដើម្បីរំដោះជាតិចេញពីអាណានិគមបារាំង។ គំនិតទាមទារ ឯករាជ្យជាតិ បានជ្រួតជ្រាប ចូលមកដល់ស្រុកខ្មែរបន្តិចម្តងៗ រហូតមកដល់ឆ្នាំ ១៩៣៦ មាន អ្នកស្នេហាជាតិ មួយក្រុមតូច នាំគ្នាបង្កើត សារពត៌មាន មានឈ្មោះថា «អង្គរវត្ត»។ ដូច្នេះ គំនិតជាតិខ្មែរ ក្នុងសតវត្សទី២០ គឺកើតចេញពី **គំនិតរំដោះជាតិ ដើម្បី ឯករាជ្យជាតិ**។ លោក កេង វាន់សាក់ បញ្ញវន្តខ្មែរមួយរូប តែងនិយាយបញ្ជាក់ថា លោក ស៊ឹង-ង៉ុកថាញ់ ក្នុងគំនិតជាតិ របស់គាត់ នៅជំនាន់នោះ មានតែត្រឹម ការតស៊ូរំដោះជាតិ ពិបារាំង ដើម្បី ឯករាជ្យ។ ចំពោះគាត់ រឿងនយោបាយ ជា ដំណាក់កាលទី២ ដែលខ្មែរត្រូវធ្វើ។ ហេតុនេះឯង បានជាគ្មានមានអ្វីច្បាស់លាស់ ក្នុងទស្សនៈនយោបាយ របស់ លោក ស៊ឹង ង៉ុកថាន់។ កង្វះ ចក្ខុវិស័យនយោបាយនេះ នាំឲមាន ព្យាកុលភាព ក្នុងជួរ អ្នកគាំទ្រ គំនិតរបស់លោក។

ប្រយោជន៏ជាតិ ក៏ដូចពាក្យ ឯករាជ្យជាតិដែរ គឺត្រូវដឹងឲច្បាស់តាំងពីដើមដំបូង ថាអ្វីជា ប្រយោជន៏ជាតិ ហើយ បង្កើតដើម្បី នរណា ? ការពិភាក្សា ក្នុងគំនិតនេះហើយ ត្រូវចាំបាប់ ឲអ្នកចេះដឹងខ្មែរ ស្វែងរក ភព នៃគំនិតជាតិ ដើម្បីយកមក ធ្វើជាសេចក្តីសំអាងរបស់គំនិត។ យើងគួរ ដឹងដែរថា ៩០ឆ្នាំ ក្រោម អាណានិគមបារាំង តើអ្នកចេះដឹងខ្មែរ ចេះដឹងអ្វីខ្លះ ? ប្រវត្តិសាស្ត្រជាតិ ? វិទ្យាស្សាស្ត្រ ? គំនិតលទ្ធិប្រជាធិបេតយ្យ ?

នៅស្រុកខ្មែរ គំនិតរំដោះជាតិ មិនមានកើតឡើងពីវិទ្យាស្សាស្ត្រ តែមានប្រភព នៃបស្សៈ ឬ ប្រាជ្ញាផុស របស់វា គឺ ចរន្តថ្មី ក្នុងពិភពលោក ក្នុងដំបន់អាស៊ី និង នៅក្នុងទ្វីប ដ៏ទៃទៀត គឺ៖ គំនិតស្វែងរកឯករាជ្យជាតិ របស់ប្រជាជន ដែលរស់នៅក្រោមរបបអាណានិគម នៃមហាអំណាច។ នៅស្រុកខ្មែរ គំនិត **អ្នកជាតិនិយម** ជាគំនិតទទួលឥទ្ធិពល ពី បដិវត្តន៏ចិន ក្នុងឆ្នាំ១៩១១ ដែលជា បដិវត្តន៏ ដឹកនាំដោយ លោកវិជ្ជបណ្ឌិត ស៊ុ

ន យ៉ាន់សេង។ គោលគំនិតធំបីរបស់លោកគឺៈ ១. ទុកប្រជារាស្ត្រ ជាធិបតេយ្យ, ២. ទុកលទ្ធិប្រជាធិបតេយ្យ ជាលទ្ធិដឹកនាំជាតិ ទី៣. ធានាការពារ សមភាព នៃពលរដ្ឋ ក្នុងការធ្វើសកម្មភាព នយោបាយ។ ទ្រឹស្តីនេះ បានជ្រាបចូលក្នុងគំនិត លោក ស៊ឺង ង៉ុកថាន់ ហើយ លោកយកវាមកធ្វើសកម្មភាព ប្រឆាំងនឹងអាជ្ញាធរបារាំង ដែលនាំឲបារាំងទុកលោកជាសត្រូវទី១ របស់គេ ហើយគេធ្វើអ្វីគ្រប់បែបយ៉ាង កុំឲលោកមានឳកាសគ្រប់គ្រាន់ ធ្វើឲបានសម្រេច នូវគោលបំណងរបស់លោក។ ក្នុងគោលដៅនេះហើយបានជាបារាំងចាប់លោក យកទៅដាក់គុកនៅស្រុកគេ អស់រយៈពេលយ៉ាងយូរ គឺដល់ទៅ ៦ ឆ្នាំ (១៩៤៥-១៩៥១) ឯណោះ។

ការទាមទារឯករាជ្យ អោយជាតិ ដោយប្រើគំនិត អ្នកជាតិនិយម ជាកម្លាំងជាតិ ត្រូវចាំបាច់ឈរលើលទ្ធិនយោបាយណាមួយឲច្បាស់។ នៅក្នុងសម័យនោះ អ្នកចេះដឹងខ្មែរមួយក្រុម នាំគ្នាជ្រើសរើស លទ្ធិប្រជាធិបតេយ្យសេរី ជាលទ្ធិនយោបាយជាតិ។ យើងអាចចាត់ទុកការជ្រើសរើសដំបូងនេះ ជាប្រភពនៃ «គំនិតជាតិ របស់អ្នកជាតិនិយម»។នៅពេលនោះជនបារាំងខ្លះ ដែលជាអ្នកយកចិត្តទុកដាក់លើ ជីវិតនយោបាយខ្មែរ យល់ឃើញថា ខ្មែរខ្វះ មនោគតិ គិតតែ យកគំនិតបស្ចិមប្រទេសមកធ្វើជា **បស្សូសៈ**[53] ទាំងស្រុង ដូចយ៉ាង រដ្ឋធម្មនុញ្ញ ខ្មែរឆ្នាំ ១៩៤៧ គឺជាការចំឡងទាំងស្រុងនៃ រដ្ឋធម្មនុញ្ញ របបសាធារណរដ្ឋទី៣ របស់បារាំង។ តែជនបារាំងទាំងនេះ និយាយបែបនេះ ភ្លេចថាទី១ នៅជំនាន់នោះ ខ្មែរនៅក្រោមអំណាចបារាំង នៅឡើយទេ, ទី២ ការតាក់តែងសរសេរ រដ្ឋធម្មនុញ្ញនេះទៀត គឺខ្មែរសរសេរជាមួយអាជ្ញាធរបារាំង នៅក្នុងគណកម្មការចំរុះ ខ្មែរ-បារាំង។ ពិតមែនតែ អាជ្ញាធរបារាំង គេបើកសេរីភាពឲបង្កើត សភាធម្មនុញ្ញ តែគេនៅតែមានឥទ្ធិពលខ្លាំងក្លា មកលើខ្មែរជានិច្ច ហើយខ្មែរយើង នៅមានការខ្លបខ្លាចជានិច្ចដែរ ព្រោះ ឃើញគេចាប់ លោក ស៊ឺង ង៉ុកថាន់, នាយករដ្ឋមន្ត្រីខ្មែរ, យកទៅដាក់គុកយ៉ាងងាយស្រួលបំផុត។ ចំពោះយើង នៅក្នុងចំណុចនេះ យើងយល់ឃើញថា ខ្មែរយើងមិនបានចំឡងច្បាប់បារាំងដោយសុទ្ធចិត្ត នោះឡើយ បើគ្មានបារាំងចូលជ្រៀតជ្រែក ដើម្បីការពារប្រយោជន៍បារាំង។ ហើយខ្មែរមិនត្រូវភ្លេចទេថា ក្រោយពីស្រុកខ្មែរ បានទទួលឯករាជ្យមក បារាំងនៅធ្វើជាគ្រូខ្មែរជានិច្ច នៅមហាវិទ្យាល័យនីតិសាស្ត្រ ហើយគ្រប់ពេលវេលា គ្រូបារាំងទាំងនោះ តែងតែបង្រៀនខ្មែរ ថា រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ ១៩៤៧ ជាច្បាប់ចម្លងពីបារាំងសុទ្ធសាត តែគេមិនបានលើក បរិបទ មកបកស្រាយ

[53] បស្សូសៈ =Aspiration។

នោះឡើយ។ សួរថា ការចម្លងនូវអ្វីមួយ ដែលនៅក្នុងនោះមាន អាចនាំមកនូវពន្លឺថ្មីសំរាប់ ឲតម្លៃដល់ប្រជាពលរដ្ឋ តើអាចទុកជា អាក្រក់ដាច់ខាតនោះឬ ? សំណួរនេះ ក៏អាចយកមក ប្រធានបទ សំរាប់ធ្វើការសិក្សា ជាជម្រៅ ដើម្បីស្វែងរកការពិតនោះដែរ។

យើងដឹងរួចហើយថា នៅពេលដែលយើងសួរអ្វីទៅលោកគ្រូ ហើយគាត់ឆ្លើយ ដដែលៗច្បាស់ជាយើងភ្លេចខ្លួនថា ចម្លើយរបស់គាត់ ជាការពិតទាំងអស់ មិនយកវាមកសិក្សាដើម្បីឲដឹងនៃជម្រៅនៃការពិតនោះ។  ខ្ញុំមិនមែនចង់ដើរតួជាអ្នកប្រឆាំងនឹង ការគាបសង្កត់តាមផ្លូវបញ្ញារបស់បារាំង មកលើអ្នកចេះដឹងខ្មែរ តែខ្ញុំគ្រាន់តែចង់ទាញចិត្តខ្មែរយើង ឲយកមកពិចារណាឡើងវិញ នូវអ្វីដែលយើងធ្លាប់ចេះ ពីការបកស្រាយរបស់គ្រូបរទេស ក្នុងផ្នែកគំនិតជាតិខ្មែរ។  ពិតណាស់ហើយ យើងមិនមែនចេះតែធ្វើការបដិសេធ គ្មានស្គាល់មុខក្រោយ នូវអ្វីដែលគេធ្វើការរិះគន់ មកលើចរិតខ្មែរនិងជាតិយើង តែយើងគាប់បី ធ្វើការពិនិត្យ លើការរិះគន់ ឬ យោបល់ណាមួយ ដើម្បីជាកញ្ចក់ សំរាប់ឆ្លុះមើលឲស្គាល់ខ្លួនឯកឲច្បាស់តែប៉ុណ្ណោះ។  បើថាការរិះគន់នេះ ជាការល្អ ក៏យកទុកជា មេរៀនសំរាប់អានាគត តែបើយល់ឃើញថាការរិះគន់នេះជាការឃោសនា ក៏ត្រូវធ្វើការប្រុងប្រយ័ត្នសំរាប់អានាគត។

ដូចខ្ញុំបានសរសេរក្នុងអត្ថបទមួយមានចំណងជើងថា «ប្រវត្តិសាស្ត្រ  អាចទុកជា  មេរៀន បានដែរឬទេ ?» ខាងក្រោមហ្នេះ ជាសេចក្ដីសង្ខេប របស់វា៖

*«អ្វីជា មេរៀន គឺ ជាចំណេះចេះដឹង ទុកជាអនុសារ សំរាប់យកវាមកអនុវត្ត តែ ប្រវត្តិសាស្ត្រមិនមែន ជាចំណេះជម្មតា ទោះបីវាមានលក្ខណ:ជាវិទ្យាសាស្ត្រ ព្រោះវា ជា ព្រឹត្តិការណេមានកើតឡើងក្នុងអតីតកាល  នៅក្នុងបរិបទមួយ  ដែលប្រវត្តិសាស្ត្រវិទូ  មិនអាចរកឃើញដោយអស់សេចក្ដីបាននោះឡើយ។  ហេតុនេះឯង  បានជាគេ  មិនអាចទុកទាំងស្រុងថា ប្រវត្តិសាស្ត្រ ជា មេរៀន បាននោះទេ តែវា ជាចំណេះ សំខាន់មួយ សំរាប់មនុស្សជាតិ សំរាប់ប្រជាជាតិ ដើម្បី ឲ មនុស្សលោក, ប្រជាពលរដ្ឋ មានសម្បជញ្ញ: នូវអត្តភាពខ្លួនក្នុងចរន្ត  នៃការវិវត្ត  នៃមនុស្សជាតិ,  ប្រជាជាតិ  ដែលខ្លួនកំពុងរស់នៅ។ ចំណេះប្រវត្តិសាស្ត្រ ជាជំនួយ ដល់នរណាម្នាក់ ដែលមានឆន្ទ: ស្វែងរកការពិត នូវព្រឹត្តិការណ៍អ្វីមួយ  ដែលមានកើតឡើងនៅក្នុងអតីតកាល  ដើម្បីយល់ដឹង  តែ  មិនអាចយកវា មកធ្វើជាអនុសារ សំរាប់ ធ្វើតាមបានទាំងស្រុងនោះទេ ព្រោះព្រឹត្តិការណ៍ដែលមានកើតនៅពេលនោះ វាមានកត្តាច្រើនណាស់ ដែលវាមិនដូចគ្នានឹងកាល:ទេស:ផ្សេងមួយទៀត ទោះបី ព្រឹត្តិការណ៍ដែលកំពុងកើតឡើង វាមានសភាពស្រដៀងគ្នានឹងអ្វីដែលធ្លាប់កើតឡើងក៏ដោយ។ ប្រវត្តិសាស្ត្រ វាមានការពិតរបស់វាតែមួយគត់ តែការពិតនោះជួនកាលវាប្រែច្រើនបែបយ៉ាង មាននៅក្នុងអារម្មណ៍ របស់អ្នកដែលបានអាន*

*វា ហើយ យកវាមកបកស្រាយទៅតាម ការយល់ឃើញ ឬ ផលប្រយោជន៍ របស់ខ្លួន។ ឧទាហរណ៍៖ ខ្មែរយើងមានមតិខុសៗគ្នា លើប្រវត្តិសាស្ត្រជាតិ ជាពិសេស លើ ព្រឹត្តិការណ៍នយោបាយ ដែលនាំឲខ្មែរយើងពិបាក រកការពិត»។*

យើងដឹងថា នៅមានភពសាលាគំនិតជាតិមួយទៀតគឺ «សាលាគំនិតជាតិ របស់ **អ្នកកុម្មុយនិស្តនិយម**»។ សាលានេះទទួលឥទ្ធិពលពីបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលមានពួកយួនកុម្មុនិស្តជាអ្នកដឹកនាំ។ នៅក្នុងអង្គប្រជុំលើកទី២ (១១ កុម្ភៈ ដល់ ១៩ កុម្ភៈ ឆ្នាំ១៩៥១) ក្នុងយុទ្ធសាស្ត្រនយោបាយថ្មី បក្សកុម្មុយនិស្ត ឥណ្ឌូចិន សំរេចបំបែកបក្សជាបីអង្គការៈ បក្សកុម្មុយនិស្តវៀតណាម, ខ្មែរ និង លាវ។ នៅទីនេះ ខ្ញុំគ្មានគោលបំណងចង់សរសេរអំពីប្រវត្តិសាស្ត្រ នៃបក្សកុម្មុយនិស្តឥណ្ឌូចិននោះទេ ព្រោះមានអ្នកឯកទេសជាច្រើន គាត់បានសរសេររឿងនេះរួចហើយ ជាពិសេសជាភាសាជាតិ និពន្ធដោយ លោកស្រី គីម ធី អ៊ួយ មានចំណងជើងថា អង្គការជានរណា ? តែខ្ញុំចង់សួរជាសំណួរថា តើលទ្ធិកុម្មុយនិស្ត អាចយកមកធ្វើជាកម្លាំងខ្មែរ បានដែរឬទេ ?

## I. **សាកល្បងសិក្សាអំពីកុម្មុយនិស្តយួន ឬ ឥណ្ឌូចិន**

### **ក. សេចក្តីសង្ខេប**

**ទី១**៖ កុម្មុយនិស្តឥណ្ឌូចិននេះ ខ្លះធ្លាប់ឲឈ្មោះថាកុម្មុយនិស្តយួន ខ្លះទៀតថាជាយួនខាងជើងខ្លះទៀតថាជាយៀកមិញ ខ្លះទៀតថាជាយៀកកុង។ ការពិតទាំងអស់នេះ មានតែមួយគត់ គឺកុម្មុយនិស្តដែលយើងឲឈ្មោះថា «កុម្មុយនិស្តឥណ្ឌូចិន» នេះឯង។

ដោយហេតុថាកុម្មុយនិស្តឥណ្ឌូចិននេះមានឫសមានគល់ជា «យួន» យើងគោងសិក្សាអំពីយួននេះក្នុងឋានៈជាជាតិសាសន៍មួយឲបានស្គាល់បន្តិចសិន។

#### **ក១. ដើមកំណើតនៃជនជាតិយួន**

ជនជាតិយួនមានដើមកំណើត នៅក្នុងស្រុកចិន ម្តុំខាងត្បូងសៀងហៃ តាមទំនាបនៃទន្លេ យ៉ង់ សេ (YANG TSE)។ ពួកនេះមានឈ្មោះដើមហៅថា ណាំវៀត (NAMVIET) ឬ យួវេ (YUE) ដែលខ្មែរឲឈ្មោះថាយួន។ សាសន៍យួននេះគ្មានជាប់ពូជអំបូរជាមួយខ្មែរមនទេ។

### **ខ. ការរាតត្បាតនៃជាតយួនមកលើដែនដីតុងកឹង**

ដែនដីតុងកឹង ឬ ដីទំនាបទន្លេក្រហម (Delta du fleuve rouge) ដែលយួនហៅថា «បាក់គី» (BAC KY) ឬ យួនកុម្មុយនិស្តនិយមហៅថា «បាក់បូ» (BAC BO) ជាដីរបស់កុលសម្ពន្ធ ម៉េវ (MEO) ម៉យ (Moïs) ថៃ មិន (MAN) ។ល។

លុះដល់ឆ្នាំ ១១១ មុន គ.ស. ទើបជនជាតិយួនវាតទីមកលើតំបន់នេះ។ គេតាំងធានីមួយឈ្មោះហៅថាក្រុងដុងគិញ (DONG KINH)ដែលក្រោយមកដូរឈ្មោះថាហាណូយ។ ចំណែកឯជនជាតិដើមក៏នាំគ្នាភៀសខ្លួនឡើងទៅនៅលើភ្នំអស់ទៅ។

តុងកឹង ឬ បាក់គីនេះគឺស្ថិតនៅក្រោមការត្រួតត្រាចិនប្រហែល ១០០០ ឆ្នាំ គឺពីឆ្នាំ ១១១ មុនគ.ស. រហូតដល់ឆ្នាំ ៩៣៩ នៃគ.ស.។

## គ. ការវាតទីនៃជនជាតយួនមកលើនគរចំប៉ា

នគរចាម ឬ ចំប៉ា លាតសន្ធឹងតាមឆ្នេរសមុទ្រចិន ចាប់ពីតាំងពីខែត្រក្វាប៊ិញ (QUANG BINH PHANTHIET) រហូតដល់ខែត្រ ផាន់ ធាត (QUANG ETIH-QUANHIET) ដែលមានធានីឈ្មោះពិជ័យ(VIJAYA)។

ជនជាតិយួនបានដណ្តើមយកនគរចំប៉ានេះពីចាមបាន ក្នុងកំឡុងពីឆ្នាំ គ.ស. ៦០៥ រហូតដល់ គ.ស. ១៤៧០។ គេប្រែឈ្មោះហៅថាអាណ្ណាម ឬ ដែលយួននិយមហៅថា «ទ្រុងគី» (TRUONG KY) ពួកកុម្មុយនិស្តហៅថា «ទ្រុងបូ» (TRUONG BO) ដែលមានធានីឈ្មោះក្រុងវេ (HUE)។

ក្នុងការដណ្តើមនគរចាមនេះ យួនគេប្រើមធ្យោបាយពិសេស៣យ៉ាងគឺៈ

- លបជ្រៀតជ្រែងចូលតាំងទីរស់នៅដោយសន្តិភាព,
- កាលណាចូលតាំងទីបានហើយគេនាំគ្នាធ្វើឲអំណាចកណ្តាលខ្សោយ,
- អន្តរាគមយោធា។

ក្រៅពីនេះ គេមានប្រើកលឧបាយផ្សេងៗ ដូចជាសំណូកសូកប៉ាន់ ជាស្ត្រីរូបស្អាត ឬ ជាវត្ថុមានដំឡៃ ។ល។ ឧទាហរណ៍ កាលពីឆ្នាំ ១៣០៦ ស្តេចយួនបានលើកកូនក្រមុំ ឈ្មោះនាង «ត្រាន»(HUYEN TRAN) ទៅថ្វាយស្តេចចាមឈ្មោះ ព្រះបាទ ឆេម៉ាន់ (CHEMAN) ដែលនាំឲចាមខាតបង់ខែត្រមួយយាងធំ គឺខែត្រ អូលី ឯកសារខ្លះថា អូ ជាខែត្រ ឯ លី ជាខែត្រមួយទៀតដែរ ដែលយួនប្រែឈ្មោះថា ធុយ អាន វ៉ា (THUAN HAO)។

## ឃ. ការរាតត្បាតនៃជនជាតយួនមកលើកម្ពុជាក្រោម

ក្នុងការដណ្តើមយកដីខ្មែរនៅកម្ពុជាក្រោមនេះ យួនប្រើមធ្យោបាយ ដូចកាលដែលគេប្រើដើម្បីដណ្តើមយកនគរចាមដូច្នេះដែរ។ គេបានប្រើពេលពីឆ្នាំ ១៩៤៩ ទើបយកកម្ពុជាក្រោមបាន។ ដីខ្មែរកម្ពុជាក្រោមបើរាប់ទាំងកោះត្រឡាច និង កោះត្រល់ផងមាន ២១ខែត្រ ដែលមានឈ្មោះដូចតទៅៈ

ឈ្មោះនៅខ្មែរៈ

ទួលតាម៉ូក (THUDAUMOT), ត្រពាំងស្រែកាត្រី (BIEN HOA), ស្រែអំបិល (BARIA), រាងដំរី(TAYNINH), ព្រៃនគរ (SAIGON), ដំបូកកោង (GOCONG), មេសរ (MYTHO), កំពង់ឫស្សី

(BENTRE) មាត់ជ្រូក (CHAUDOC), ពាមបារាជ (LONGYUEN), ផ្សារដែក (SADEC), ឡុងហោ (VINHLONG), ព្រះត្រពាំង (TRAVINE), ពាម (HATIEN), ក្រមួនសរ (RACHGIA), ព្រែកឫស្សី (CANTHO),ឃ្លាំង (SOCTRANG) ,ពលលាវ (BACLIEU), ទឹកខ្មៅ (CAMAU), កោះត្រល់ (PHU QUOC), កោះត្រឡាច (CONG SONG ou POULO CONDOR)។

គួរកត់សំគាល់ថា ឈ្មោះខែត្រទាំងនេះ ត្រូវបានយួនគេដូរឈ្មោះជាច្រើនលើកច្រើនសារ ប្រយោជន៍ដើម្បីបំបាត់ឲអស់នូវអនុស្សាវរីយ៍ទាំងឡាយរបស់ម្ចាស់ដើម។

មកដល់ត្រង់នេះយើងឃើញថា ក្នុងកំឡុងពេលវេលាប្រហែល ២០០០ឆ្នាំ ជនជាតិយួន បានដណ្តើមយកដី និង គេឯងបានជាច្រើន គឺប្រមាណ ៣៣៤.០០០ គ.ម²។ ព្រឹត្តិការណ៍នេះ អ្នកប្រាជ្ញប្រវត្តិសាស្ត្រ និយមឲឈ្មោះថា «មហាដំណើរនៃជនជាតិយួនឆ្ពោះទៅទិសខាងត្បូង»។

**ទី២៖ តើអ្នកណាខ្លះជាកុម្មុយនិស្តពេញលក្ខណ: ?**

បណ្តាអ្នកដឹកនាំធំៗ នៃកុម្មុយនិស្តមានតែ ហូជីមិញ មួយគត់ ដែលជាសមាជិកពេញលក្ខណ:នៃអន្តរជាតិទី៣ នៅក្រុងមូស្គូ។ អ្នកដឹកនាំឯទៀតៗ សុទ្ធតែជាអ្នកជាតិនិយមទាំងអស់។ប៉ុន្តែគេនាំគ្នាជ្រើសរើសយកលទ្ធិកុម្មុយនិស្តនេះ ដើម្បីជាមធ្យោបាយមួយ ដើម្បីសម្រេចនូវគោលបំណងគេ ក្នុងការបំរើ ដល់ប្រយោជន៍ប្រទេសជាតិគេតែប៉ុណ្ណោះ។

**ទី៣៖ គោលបំណងរបស់កុម្មុយនិស្តឥណ្ឌូចិន**

**ក**. ទាមទារយកដីកម្ពុជាក្រោមដោយយកលេសថា «ឯកភាព» នៃជនជាតិយួន (បង្រួបបង្រួមដំបន់បី៖ តុងកឹង,អាណ្ណាម និង កម្ពុជាក្រោម ឬ កូសាំងស៊ីន),

**ខ**. ទាមទារឯករាជឲប្រទេសយួន,

**គ**. ដេញបារាំងចេញពីឥណ្ឌូចិន,

**ឃ**. ត្រួតត្រាឥណ្ឌូចិនជំនួសបារាំងក្នុងឋានៈជាយួន។

គួរកត់សំគាលថា ហូជីមិញ បានផ្ញើញត្តិមួយក្នុងនាម «ឥណ្ឌូចិន» សុំចូលជួប លោកប្រធានាធិបតី វិល សុន (WILSON) នៅក្រុងប៉ារីស៍។

**ទី៤៖ បុព្វហេតុធំៗ ដែលនាំឲយួនជ្រើសរើសយកលទ្ធិកុម្មុនិស្ត មកធ្វើជា មធ្យោបាយ ដើម្បីដណ្តើមយកឥណ្ឌូចិន៖**

**ក. បដិវត្តន៍នៅប្រទេសចិន ឆ្នាំ ១៩១១៖**

ដើម្បីរំលំរបបរាជានិយមនោះ អ្នកដឹកនាំបដិវត្តន៍ចិន បានហៅអ្នកជំនាញការ រុស្ស៊ីជាច្រើនឲមកធ្វើការក្នុងប្រទេសខ្លួន។ ហូជីមិញ ក៏ត្រូវបានអង្គការអន្តរជាតិទី៣ នៅក្រុង

មូស្គូ ប្រើមកធ្វើការនៅក្នុងប្រទេសចិនដែរ ក្នុងឋានៈជាអ្នកប្រែភាសាឲ្យអ្នកជំនាញការរុស្ស៊ី។ អ្នកជំនាញការទាំងឡាយនោះ បានខិតខំប្រឹងប្រែងធ្វើសកម្មភាព បំរើចលនាកុម្មុយនិស្តអន្តរជាតិយ៉ាងខ្លាំង។ ដោយមានជំនួយពីហូជីមិញផង ពួកយួនដែលរស់នៅក្នុងប្រទេសចិនក៏បាក់ចិត្តបាក់គំនិត ដោយសារការឃោសនារបស់អ្នកជំនាញការទាំងនោះទៅ។

ម្យ៉ាងទៀត សមាជទី២ នៃអន្តរជាតិទី៣នៅឆ្នាំ ១៩២០ បានសម្រេចៈ

- បង្កើតការិយាល័យនយោបាយកុម្មុយនិស្តមួយនៅក្នុងក្រុង សៀងហៃ នៃប្រទេសចិន ដើម្បីងាយនឹងផ្តល់ជំនួយគ្រប់បែបយ៉ាងចំពោះកុម្មុយនិស្តអាស៊ី,
- «ជួយរំដោះ» ប្រទេសទាំងអស់ក្នុងលោកឲ្យផុតពីអាណានិគមចាស់,
- គាំទ្រចលនាស្នេហាជាតិទាំងអស់ក្នុងលោក,

**ខ. ព្រឹត្តិកាល[54] នៃកុម្មុយនិស្តចិនៈ**

គណបក្សកុម្មុយនិស្តចិន បានចាប់កំណើតនៅឆ្នាំ ១៩២១។ ពួកនេះដណ្តើមអំណាចពីលោកចាងកៃឆែក (Tchiang Kai Shek) បាននៅឆ្នាំ ១៩៤៩។ ចាប់តាំងពីពេលនោះមកកុម្មុយនិស្តចិនបានក្លាយទៅជាបង្អែកមួយយ៉ាងមាំបំផុតសំរាប់កុម្មុយនិស្តយួនឬឥណ្ឌូចិន។ ជំនួយខាងសម្ភារៈគ្រប់បែបយ៉ាងមកពីរុស្ស៊ីក្តី មកពីចិនក្តី មកពីប្រទេសកុម្មុនិស្តទៀតៗក្តី ត្រូវដឹកកាត់ប្រទេសចិនទាំងអស់។ មិនតែប៉ុណ្ណោះ ជ័យជំនះរបស់ម៉ៅសេទុង នេះ បានទៅជាបង្អែកខាងចិត្តសាស្ត្រមួយយ៉ាងធំរបស់ ហូជីមិញ។

**គ. រណសិរ្សប្រជាមានិតនៃប្រទេសបារាំងរបស់ លោក ឡេអុងប្លូម (Léon Blum)ៈ**

នៅឆ្នាំ ១៩៣៦ ពួកកុម្មុយនិស្តបារាំងបានឡើងកាន់អំណាចនៅប្រទេសបារាំង ក្រោមការដឹកនាំ របស់ ឡេអុងប្លូម។ ក្នុងឋានៈជាកុម្មុយនិស្តដូចគ្នា រណសិរ្សប្រជាមានិត របស់ឡេអុងប្លូមបានជ្រុំជ្រែងកុម្មុយនិស្តឥណ្ឌូចិនរបស់ហូជីមិញយ៉ាងច្រើន។

**ឃ. កត្តាហូជីមិញៈ**

កត្តាមួយដែលធំជាងគេក្នុងការដែលធ្វើឲ្យកុម្មុយនិស្តឥណ្ឌូចិនមានជីវិតបានរហូតដល់សព្វថ្ងៃនេះ គឺការប្រឹងប្រែងរបស់ហូជីមិញនេះឯងតែម្តង។

## II. ប្រវត្តិសង្ខេបនៃគណបក្សកុម្មុនិស្ត ឥណ្ឌូចិន

[54] ព្រឹត្តិកាល= Avènement។

### ទី១៖ សមាគមយុវជនបដិវត្តន៍យួន៖

ហូជីមិញ ដែលកាលណោះមានឈ្មោះជា ង្វៀងអៃកុក នៅឡើយ បានដឹកនាំអ្នកស្នេហាជាតិយួន ដើម្បីបង្កើតសមាគមនេះឡើងនៅក្រុងកង់តុង ក្នុងប្រទេសចិនក្នុងឆ្នាំ ១៩២៥។ សមាគមនេះបង្កើតឡើង ក្នុងគោលបំណង អប់រំជនជាតិយួន ឲមានស្មារតីជាតិនិយម។ សមាជិកសំខាន់ៗដែលបង្កើតសមាគមនេះគឺ ហូជីមិញ, ហូទុងម៉ៅ, ឡេហុងផុង, ហុងសុង, ផាំវ៉ាន់ដុង ។ល។

អង្គការដែលសំខាន់ជាងគេ របស់សមាគមនេះគឺ ទស្សនាវដ្ដី មួយមានឈ្មោះ «យុវជន» (Thanh Nien)។ នៅឆ្នាំដដែលនេះ ពួកអ្នកស្នេហាជាតិទាំងឡាយ ដែលទើបនឹងចេញពីកោះត្រឡាចបានបង្កើតគណបក្សមួយ ឈ្មោះ គណបក្សបដិវត្តន៍នៃយួនថ្មី។ ក្រោយមកគណបក្សនេះមានបំណងដូច ហូជីមិញ ក៏ចូលជាសមាជិកនៃសមាគមយុវជនបដិវត្តន៍យួនទៅ។

លុះឆ្នាំ ១៩២៧ លោក ចាងកៃឆែក បានដេញពួកជំនាញការរុស្ស៊ី ហើយនឹង ហូជីមិញ ឲត្រឡប់ទៅមូស្គូវិញ។ សមាជិកសំខាន់ៗខ្លះទៀតត្រូវបានចិនចាប់បាន ហើយដាក់គុក។

ដល់ឆ្នាំ ១៩២៩ ហុងសុង ដែលជាអ្នកទទួលខុសត្រូវចុះពោះសមាគម ជំនួស ហូជីមិញ បានកោះប្រជុំសមាជិក ដែលសល់ទាំងប៉ុន្មាន នៅក្រុងហុងកុង។ សមាគមនេះក៏ត្រូវរលាយនៅពេលនោះទៅ។ សមាជិក ឬ ទាំងប៉ុន្មានបែកគ្នា ជា៣ពួក ហើយបង្កើតគណបក្ស៣។

### ទី២៖ គណបក្សកុម្មុយនិស្តឥណ្ឌូចិន៖

គណបកសនេះកើតឡើងនៅខែមិថុនា ១៩២៩។ សមាជិកភាគច្រើនមកពីសមាគមយុវជនបដិវត្តន៍យួន ខ្លះទៀតមកពីគណបក្សយួនថ្មី ខ្លះទៀតមកពីសមាគមឥណ្ឌូចិនរបស់ង្វៀងអាននិញ។

### ទី៣៖ គណបក្សកុម្មុយនិស្តអាណ្ណាមីត៖

គណបក្សកុម្មុយនិស្តអាណ្ណាមីតនេះកើតឡើងកាលពីខែតុលា ១៩២៩។ អ្នកបង្កើតគ្មានគោលបំណងនយោបាយធំដុំទេ គឺគ្រាន់តែដើម្បីដេញដើង គណបក្សកុម្មុយនិស្តឥណ្ឌូចិនតែប៉ុណ្ណោះ។

### ទី៤៖ សហភាពកុម្មុយនិស្តឥណ្ឌូចិន៖

គណបក្សកើតនៅខែមករា ១៩៣០។ អ្នកដែលបង្កើតគឺ ភាគច្រើន ជាសមាជិកឆ្វេងនិយមនៃគណបក្សយួនថ្មី។ គោលបំណងរបស់គេ មិនខុសពីគោលបំណង របស់គណបក្សកុម្មុយនិស្តឥណ្ឌូចិននោះប៉ុន្មានទេ។ សមជិកនៃគណបក្សនេះច្រើនជា បញ្ញវន្ត

ដែលទទួលវប្បធម៌ និង អរ្យធម៌បារាំងសែស។ អ្នកដែលខ្ពះខ្នែងជាងគេគឺ ដាងថៃម៉ៃ និង យ៉ង្វៀងយ៉ាប់ ។ល។

**ទី៥៖ គណបក្សកុម្មុយនិស្តយួន៖**

ដំណឹងបាក់បែកគ្នានេះបានឮទៅដល់ ង្វៀងអៃកុក។ ពេលនោះ ង្វៀងអៃកុក ឬ ហូជីមិញ នេះពួនសម្ងំនៅប្រទេសសៀម។ គាត់ក៏កោះប្រជុំសមាជិកធំៗ នៃគណបក្សទាំង៣ ដែលទើបតែបង្កើតនេះនៅក្រុងហុងកុង កាលពីខែកុម្ភៈ ១៩៣០។ ពេលនោះគាត់បានសម្រុះសម្រួលសមាជិកធំៗ នៃគណបក្សទាំង៣នេះឲលប់គណបក្សខ្លួនចោលទាំងអស់ ហើយគាត់បង្កើតគណបក្សថ្មីមួយជំនួសវិញ។ គណបក្សថ្មីនេះ មានឈ្មោះថា គណបក្សកុម្មុយនិស្តយួន ដែលមានទីស្នាក់ការនៅក្រុងហៃហ្វុង។

**ទី៦៖ គណបក្សកុម្មុយនិស្តឥណ្ឌូចិន៖**

ដើម្បីឲសម្រេចគោលបំណងរបស់គេ ដែលចង់ត្រួតត្រាឥណ្ឌូចិនទាំងមូល ង្វៀងអៃកុកក៏សំរេចចិត្តជាមួយនឹង សហការីជំនិតៗខ្លះ ដូចជា ផាំវ៉ាន់ដុង យ៉ង្វៀងយ៉ាប់ ដាងថៃម៉ៃ ជាដើម ប្តូរឈ្មោះគណបក្សកុម្មុយនិស្តយួន ជាគណបក្សឥណ្ឌូចិនវិញ ក្នុងខែមេសា ១៩៣០។ ការប្រែឈ្មោះនេះមានន័យវែងឆ្ងាយណាស់ គឺនាំឲគេអាចធ្វើសកម្មភាពពេញប្រទេសទាំងឡាយនៃឥណ្ឌូចិននេះឯង។

គណបក្សកុម្មុយនិស្តឥណ្ឌូចិនក្រោយនេះត្រូវបានអន្តរជាតិទី៣ ទទួលស្គាល់កាលពីឆ្នាំ ១៩៣១។ពេលនោះគណបក្សមានសមាជិកសកម្មជាង ១៥០០ នាក់។

នៅរវាងឆ្នាំ ១៩៣០ នៅក្នុងពិភពលោកទាំងមូល មានវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងបំផុត។ ឆ្លៀតពេលដែលមានវិបត្តិយ៉ាងខ្លាំងនេះ គណបក្សកុម្មុយនិស្តឥណ្ឌូចិន ក៏សម្រេចធ្វើសកម្មភាពយ៉ាងខ្លាំង ដែលគេឲឈ្មោះថា «ចលនាសូវៀត» នៅខែត្រ ង៉ៃអាន ដែលជាខែត្រកំណើតរបស់ហូជីមិញ។ ប៉ុន្តែចលនានោះ ត្រូវបានទ័ពបារាំង បង្ក្រាបវិញយ៉ាងសាហាវ។ សមាជិកគណកម្មការកណ្តាល នៃគណបក្សនៅព្រៃនគរ ត្រូវបារាំងរកឃើញ ហើយក៏ចាប់យកទៅដាក់គុកនៅកោះត្រឡាច ឬ នៅលើភ្នំបាមីធួក។ ម្យ៉ាងទៀតង្វៀងអៃកុក ដែលបង្គោលយ៉ាងធំ របស់គណបក្ស បានលួចរត់ទៅស្រុកចិន ដែលអង់គ្លេសចាប់បាននៅក្រុងហុងកុង នៅឆ្នាំ១៩៣១ ហើយដាក់គុកនៅទីនោះទៅ។ ដូច្នេះពេលនោះ យើងឃើញថា គណបក្សកុម្មុយនិស្តឥណ្ឌូចិនស្ទើរតែរលាយរូប។

**ទី៧៖ គណបក្សជំទាស់ពេញលេញ៖**

ការពិតគណបក្សកុម្មុយនិស្តឥណ្ឌូចិន មិនរលាយទេ។ ដើម្បីបន្តសកម្មភាពទៅតាមកម្លាំងរបស់ខ្លួន សមាជិកខ្លះ ដែលនៅសល់ ជាពិសេស ត្រាន់វ៉ាន់គ្យោវ បានបង្កើតនៅចុងឆ្នាំ ១៩៣២នូវគណកម្មការពេញច្បាប់មួយ នៅក្រុងព្រៃនគរ។ គណកម្មការនេះ មានអង្គការសារព័ត៌មាន២ សំរាប់បំរើឧត្តមគតិរបស់គេ៖ ទង់ក្រហម និង ទស្សនាវដ្តីកុម្មុយនិស្ត។

## III. រណសិរ្ស របស់ គណបក្សកុម្មុនិស្ត ឥណ្ឌូចិន

ដើម្បីទ្រទ្រង់សកម្មភាពគណបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលរលាយទៅហើយនោះ ពួកកុម្មុយនិស្តយួនបានបង្កើតជា រណសិរ្សជាច្រើន។

**ទី១៖ រណសិរ្សប្រជាធិបតេយ្យឥណ្ឌូចិន៖** (Front démocratique indochinois)

នៅឆ្នាំ ១៩៣៦ នៅប្រទេសបារាំងឯណោះ ពួកកុម្មុយនិស្តបារាំង បានឡើងកាន់អំណាច ក្រោមការដឹកនាំ របស់ ឡេអុងព្លុម។ ឡេអុងព្លុម បានបង្កើត រណសិរ្សមួយឈ្មោះរណសិរ្សប្រជាមានិតុ។ ឆ្លៀតឱកាស ដែលពួកកុម្មុយនិស្តបារាំង ឡើងកាន់អំណាចនេះពួកកុម្មុយនិស្តយួន ក៏បង្កើតជារណសិរ្សមួយដែរ ដែលមានឈ្មោះជារណសិរ្សប្រជាធិបតេយ្យឥណ្ឌូចិន។ រណសិរ្សយួននេះ មានបំណងធំបំផុតគឺ ធ្វើយ៉ាងណា ឲពួកកុម្មុយនិស្តបារាំង ដោះលែងអ្នកទោសនយោបាយជាតិយួន ដូចជា ង្វៀងអៃកុក ផាំវ៉ាន់ដុងជាដើម។ ប៉ុន្តែ រណសិរ្សនេះត្រូវរលាយខ្លួនទៅវិញចាមួយនឹងរណសិរ្សប្រជាមានិតុបារាំង។

**ទី២៖ រណសិរ្សប្រជាមានិតរួម៖**

ឆ្នាំ ១៩៣៩ ជាឆ្នាំដែលបារាំង កំពុងតែជាប់ដៃជាមួយនឹងអាឡឺម៉ង់ ក្នុងសង្គ្រាមលើកទី២។ ឆ្លៀតពេលដែលបារាំងកំពុងមានបញ្ហាសង្គ្រាមយ៉ាងធំនេះ ពួកកុម្មុយនិស្តយួន ក៏នាំគ្នាបង្កើត រណសិរ្សប្រជាមានិតុ មួយទៀត ឈ្មោះ រណសិរ្សប្រជាមានិតុរួម។ រណសិរ្សនេះបានរៀបចំធ្វើបាតុកម្ម និង ការបេះបោរ  ផ្សេងៗ ជាច្រើន។ បារាំងដែលកំពុងជាប់ដៃធ្វើសង្គ្រាម ជាមួយ អាឡឺម៉ង់ មិនអាចដោះស្រាយបញ្ហាយួន ដែលបង្កើតឡើងដោយរណសិរ្សប្រជាមានិតុរួមនេះបានឡើយ។ អាស្រ័យហេតុនេះហើយ បានជាពួកជនជាតិយួនជាច្រើន ជាពិសេសកម្មករ និង កសិករ នាំគ្នាចូលជាសមាជិកគណបក្សកុម្មុយនិស្តឥណ្ឌូចិន។

**ទី៣៖ រណសិរ្សយៀកមិញ៖** (Front Vietnam Doc Lap Minh)

ង្វៀងអៃកុក ដែលគេស្មានថាតែស្លាប់កាលពីឆ្នាំ ១៩៣២ នៅក្រុងហុងកុង ទៅហើយនោះ ក៏បានលេចមកក្នុងឆាកនយោបាយវិញ ដោយផ្លាស់ឈ្មោះជា ហូជីមិញ។ នៅឆ្នាំ ១៩៤១ ហូជីមិញ បានកោះហៅសហការីសំខាន់ៗ របស់គាត់នៅក្នុងគណបក្សកុម្មុយនិស្តឥណ្ឌូចិន ទៅប្រជុំជាសមាជិកនៅក្រុងស៊ីនស៊ី នៃប្រទេសចិន។ សមាជិកនេះក៏បានសម្រេចបង្កើតរណសិរ្សមួយមានឈ្មោះជា អក្សរកាត់ ជារណសិរ្សយៀកមិញ។ គោលបំណងរបស់គេគឺប្រមូលជនជាតិយួនគ្រប់ជាន់ថ្នាក់ដើម្បី៖

ទី១ - វាតត្បាតលុកលុយកម្ពុជាក្រោម - ប្រទេសខ្មែរ និង លាវ។

ទី២ - ច្បាំងកំចាត់បារាំង ហើយនិង ជប៉ុន។

ដូច្នេះយើងឃើញថា ពួកកុម្មុយនិស្តឥណ្ឌូចិនមានអង្គការប្រយុទ្ធ ខាងនយោបាយផង និងខាងយោធាផង។ ដោយសា រណសិរ្សវៀតមិញនេះ ពួកកុម្មុយនិស្តបានរាតត្បាតពេញប្រទេសទាំងឡាយនៅឥណ្ឌូចិន «យួន-កម្ពុជាក្រោម-ខ្មែរ-លាវ»។

ក្រោយមក នៅថ្ងៃទី ២ កញ្ញា ១៩៤៥ ក្រោយដែលជប៉ុនបានប្រកាសចុះចាញ់ក្នុងសង្គ្រាមលោកលើកទី២ ហូជីមិញ បានប្រកាសឯករាជឲ្យប្រទេសយួន និង ប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យយួន។ - ចំណែកព្រះចៅ បៅដោយ ជាទីព្រឹក្សាជាន់ខ្ពស់នៃសាធារណរដ្ឋ -។ ពេលនោះ ដើម្បីឲមានការគាំទ្រពីប្រទេសចិន អាមេរិកាំង អង់គ្លេស។ល។ និងពលរដ្ឋយួន ដែលមិនស្រឡាញ់លទ្ធិកុម្មុយនិស្តនោះ ហូជីមិញ ក៏បានប្រកាសលប់គណបក្សកុម្មុយនិស្តចោល កាលពីខែវិច្ឆិការ១៩៤៥។

**<u>សេចក្តីសង្កេត</u>** :

ដើម្បីឲរុស្ស៊ី-ចិនកុម្មុយនិស្ត របស់ ម៉ៅ សេទុង «សមមិត្ត» របស់គាត់មានការទុកចិត្តហូជីមិញ បានបង្កើត សមាគមមួយ ជំនួសគណបក្សកុម្មុយនិស្តឥណ្ឌូចិន។ សមាគមនោះ ឈ្មោះសមាគមឥណ្ឌូចិនខាងសិក្សាលទ្ធិមាក្ស (Association Indochinoise pour les Etudes Marxistes) ដែលមានសកម្មភាពដូចគណបក្សកុម្មុយនិស្តឥណ្ឌូចិនដដែល។ ម្យ៉ាងទៀតអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រជាច្រើន បានសំគាល់ថា ឆ្នាំ ១៩៤១ គឺជាឆ្នាំដែលឥណ្ឌូចិនទី១ ចាប់ផ្តើមឡើងជាដំបូង។ ហេតុថា ពួកវៀតមិញបានធ្វើការលុកលុយប្រទេសទាំងឡាយនៅឥណ្ឌូចិន។

### ទី៤៖ រណសិរ្សលៀចវៀត ១៩៤៦៖

ខែមករា ១៩៤៦ ហូជីមិញ បានជាប់ឆ្នោតជា ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យយួន។ ពេលនោះ ហូជីមិញ បានរៀបចំធ្វើជា រណសិរ្ស បង្រួបបង្រួមជាតិមួយ ឈ្មោះជា រណសិរ្សលៀចវៀត។ គណបក្សនយោបាយផ្សេងទៀតជាច្រើនបានចូលទៅក្នុងរណសិរ្សលៀចវៀតនេះផងដែរ។ ចាប់តាំងពីពេលនេះមកហើយ ដែលគេឃើញរដ្ឋាភិបាល របស់ហូជីមិញចាប់ផ្តើមរៀបចំអនុវត្តន៏ នូវនយោបាយរបស់ខ្លួន ឲប្រទេសទៅតាមកម្មវិធីរបស់គណបក្សកុម្មុនិស្តឥណ្ឌូចិន គឺ៖

- ទាមទារដីកម្ពុជាក្រោម

- ឯករាជនឹងឯកភាពយួន

- ដេញបារាំងពីណ្ឌូចិន

- ត្រួតត្រាឥណ្ឌូចិនជំនួសបារាំង។

ក្នុងការទាមទារដីកម្ពុជាក្រោមនេះ ហូជីមិញ បានប្រើកលល្បិចយ៉ាងប៉ិនប្រសប់បំផុត។ ខ្មែរយើងមិនទាំងដឹងខ្លួនស្រួលបួលផង ហូជីមិញ បានចុះហត្ថលេខាលើសេចក្តីព្រមព្រៀងជាមួយបារាំងចំនួនបីលើករួចជាស្រេចទៅហើយគឺ៖

- សេចក្តីព្រមព្រៀងនៅហាណូយ ចុះថ្ងៃទី ៦មិនា ១៩៤៦។ សេចក្តីព្រមព្រៀងនេះជាលទ្ធផលនៃការចរចារយ៉ាងស្វិតស្វាញរវាង ហូជីមិញ នឹងបារាំងអំពីបញ្ហាកម្ពុជាក្រោម ឯករាជឯកភាពយួន ។ល។

- សេចក្តីព្រមព្រៀងក្រុងដាឡាត់ ចុះថ្ងៃទី ២៤ មេសា ១៩៤៦។ សេចក្តីព្រមព្រៀងនេះជាលទ្ធផលនៃសន្និសីទក្រុងដាឡាត រវាង គណប្រតិភូបារាំង នឹងគណប្រតិភូយៀកមិញ ស្តីអំពីការអនុវត្តន៍ នូវសេចក្តីព្រមព្រៀងចុះថ្ងៃទី ៦ មិនា ១៩៤៦។

- សន្ធិសញ្ញាបណ្តោះអាសន្ន (Modus Vivendi) នៅក្រុងហ្វុងតែណឺប្លូ ចុះថ្ងៃទី១៤កញ្ញា ១៩៤៦៥។

សន្ធិសញ្ញាបណ្តោះអាសន្ននេះ បានមកពីសន្និសីទមួយយ៉ាងយូរ និង យ៉ាងលំបាក រវាងយួននឹងបារាំង ស្តីអំពីកម្ពុជាក្រោម ឯករាជ និង ឯកភាពយួន បញ្ហាសហពន្ធឥណ្ឌូចិន ។ល។

គួរកត់សំគាល់ថា សេចក្តីព្រមព្រៀង ឬ សន្ធិសញ្ញាបណ្តោះអាសន្នទាំង៣លើកនេះ សុទ្ធតែជាបញ្ហាដែលទាក់ទងមកនឹងប្រទេសខ្មែរទាំងអស់ ប៉ុន្តែគេចុះហត្ថលេខា មិនឲខ្មែរយើងចូលរួមជាមួយផងទេ គឺគេដើរ «ខ្សែលើ» លើយើងរហូត។ នេះហើយជាកលល្បិចមួយរបស់កុម្មុយនិស្តឥណ្ឌូចិនក្នុងការរៀបត្រួតត្រាប្រទេសទាំងអស់នៅឥណ្ឌូចិន។ មកដល់ត្រង់ណេះយើងឃើញថាយៀកមិញបានប្រើល្បិចខ្លះទៀតក្រៅផ្លូវច្បាប់។

ម្យ៉ាងទៀតដោយហេតុថា គោលបំណងរបស់គេខាងលើនេះ មិនបានសម្រេច ពួក កុម្មុយនិស្ត ក៏បានចាប់ផ្តើមវាយបារាំងចេញមុខមែនទែនតាំងពីថ្ងៃ ១៩ ធ្នូ ១៩៤៦។ ក្នុងការប្រយុទ្ធជាមួយបារាំងនេះ រណសិរ្សវៀតមិញ បានដើរតួរយ៉ាងសំខាន់នៅក្នុងស្រុកយួន ចំណែកពួកយៀកមិញ វិញ គេខំប្រឹងប្រែងយ៉ាងសម្ងៀម នៅកម្ពុជាក្រោម នៅប្រទេសខ្មែរ និង លាវ។

ចម្បាំង រវាង យួន នឹងបារាំងបានចប់ (ក្រោយដែលបារាំងចាញ់នៅ ឌៀងប្រៀងភូ កាលពីពីថ្ងៃ ៧ ឧសភា ១៩៥៤) ដោយសន្និសីទក្រុង ហ្សឺណែវ ស្តីអំពីបញ្ហាឥណ្ឌូចិនដែលបានបញ្ចប់កិច្ចការរបស់ខ្លួននៅ ថ្ងៃ ២០ កក្កដា ១៩៥៤ ដោយចែកប្រទេសយួនជា ២ តាមបណ្តោយខ្សែស្របទី១៧។

## ប្រវត្តសាស្ត្រ ជាសង្ខេប នៃ កុម្មុយនិស្តខ្មែរ

កុម្មុយនិស្តខ្មែរ បង្កើតឡើង ដោយ កុម្មុយនិស្តយួន សំរាប់បំរើ ប្រយោជន៍កុម្មុយនិស្តយួន។ ហេតុនេះឯង បានជា ពួកកុម្មុយនិស្ត មិនដែលមាន ទ្រឹស្តី និង យុទ្ធសាស្ត្រ របស់ខ្លួនពិតប្រាកដ សំរាប់ធ្វើបដិវត្តន៍ រកប្រយោជន៍ឲប្រជាជាតិខ្មែរបាននោះឡើយ។ ចាប់ពីឆ្នាំ១៩៧០កុម្មុយនិស្តខ្មែរ រស់នៅក្នុងការប្រទាញប្រទង់ រវាង គំរូ ចិន នឹងយួន កុម្មុយនិស្តនាំបង្កើតអធិករណ៍ ចេញមុខ ជាមួយ ប្រទេសយួន ដោយមានជំនឿជាក់ច្បាស់ថា ចិនកុម្មុយនិស្ត ស្ថិតនៅពីក្រោយខ្លួន ជានិច្ច រាល់ស្ថានការណ៍ ដែលខ្លួននឹងអាចជួប

ប្រទះ ក្នុង ទំនាស់ រវាងខ្លួននឹងកុម្មុយនិស្តយួន។ នៅក្នុង សៀវភៅខ្មៅ[55] របស់ របបកម្ពុជាប្រជាធិបតេយ្យ ឬ របបខ្មែរក្រហម ពួកកុម្មុយនិស្តខ្មែរ ខំប្រឹងបង្ហាញ នូវធាតុទំនាស់ រវាងខ្លួន នឹង សមមិត្ត យួន មានតាំងពីកំណើត នៃកុម្មុយនិស្តខ្មែរ មកម្លេះ។ គេបែងចែកជា ៥ដំណាក់កាលៈ

- ១៩៣០-១៩៤៥ៈ យួន យក គណបក្សកុម្មុយនិស្រឥណ្ឌូចិន ជាអ្នកដឹកនាំចលនាកុម្មុយនិស្ត កើតមាននៅឥណ្ឌូចិន,

- ១៩៤៥-១៩៥៤ៈ កុម្មិយនិស្តយួនចូលមកធ្វើសកម្មភាពឃោជាក្នុងស្រុកខ្មែរ និង លាវ ប្រើទង់អ្នករំដោះអាណានិគមបារាំងឲចេញពីឥណ្ឌូចិន,

- ១៩៥៤-១៩៧០ៈ ក្រោយពីសន្ទិសីទក្រុងហ្សឺណែវ កុម្មុយនិស្តយួន ត្រូវដកខ្លួនចេញពីកម្ពុជា តែគេនៅតែរក្សាយុទ្ធសាស្រ្តឥណ្ឌូចិន ដែលនាំបង្កើតជាទំនាស់ជាមួយ ខ្មែរបន្ទាត់នយោបាយជាមួយនឹង គណបក្សកុម្មុយនិស្តខ្មែរ ចាប់ពីឆ្នាំ ១៩៦០ ដែលជាឆ្នាំបង្កើតគណបក្សនេះ។ដោយអាស្រ័យមានការអនុញ្ញាតចូលមកតាំងទីទ័ពក្នុងទឹកដីខ្មែរក្នុងឆ្នាំ ១៩៦៥ ពូកកុម្មុយនិស្តយួន ចាប់ផ្តើមធ្វើគ្រប់សកម្មភាព ដើម្បីបំផ្លាញបដិវត្តន៍ខ្មែរ,

- ១៩៧៥-១៩៧៨ៈ ដោយមានការសមគំនិត ពីចក្រពត្រអាមេរិកាំង កុម្មុយនិស្តយួន ធ្វើសកម្មភាពបង្ក្ខិនបង្ខោច និង ការប៉ុនប៉ង ធ្វើរដ្ឋប្រហារ ដើម្បីរំលំ កម្ពុជាប្រជាធិបតេយ្យ។ក្នុងឆ្នាំ ១៩៧៧ កុម្មុយនិស្តយួន ប្រើកម្លាំងទ័ព ១៤ កងពលធំ វាយចូលប្រទេសខ្មែរក្នុងគោលបំណង ចូលកាន់កាប់ទឹកដីខ្មែរតែម្តង ដោយប្រើយុទ្ធសាស្រ្ត «ការវាយប្រហារផ្ទេកបន្ទោរ-ជ័យជំនះផ្ទេកបន្ទោរ»។

**ហិរិ**[56] នេះ រិតតែបញ្ជាក់ឲឃើញថា ពួកកុម្មុយនិស្តខ្មែរ ធ្វើសហការ ជាមួយនឹងកុម្មុយនិស្តយួននៅក្នុងយុទ្ធសាស្រ្តយួន បំរើប្រយោជន៍យួន តាំងពីដើមទីមកម្លេះ ដូចយ៉ាងកុម្មុយនិស្តយួនជាអ្នកបង្កើត ចលនាកុម្មុយនិស្តខ្មែរៈ

- **ចលនា ខ្មែរឥស្សរៈ** បង្កើតឡើង នៅក្នុងខែ មិថុនា ១៩៤១ តាមការសម្រេចនៃការប្រជុំ (Plénum) លើកទី៨ នៃគណកម្មាធិការកណ្តាលនៃគណបក្សកុម្មុយនិស្តឥណ្ឌូចិន,

- **គណបក្សប្រជាជនខ្មែរ** បង្កើតឡើង នៅថ្ងៃទី ២៥ មិថុនា ១៩៥១ តាមការសម្រេចចិត្តនៃសមាជលើកទី២ នៃគណបក្សកុម្មុយនិស្តឥណ្ឌូចិន,

---

55 សៀវភៅខ្មៅ ស្តីអំពី អង្គហេតុ និង ភស្តុតាង នៃអំពើឈ្លានពាន និង ការបញ្ចូលជាឧបសម្ព័ន្ធ នៃយួន ប្រឆាំងនឹងខ្មែរ។ ឯកសារនេះផ្សាយចេញពីក្រសួង កិច្ចការបរទេស នៃកម្ពុជាប្រជាធិបតេយ្យ ក្នុងខែ កញ្ញា ១៩៧៨ នៅពេលដែលទ័ពយួនរៀបចំវាយខ្មែរ។

56 ហិរិ= ការដឹងនូវអ្វីដែលជាអំពើអាក្រក់ ; Conscience ce qui est mal។

- **គណបក្សកុម្មុយនិស្តខ្មែរ** បង្កើតឡើងនៅក្នុងឆ្នាំ ១៩៦០ ដោយមានការអនុញ្ញាតពីកុម្មុយនិស្តយួន នៅក្នុងយុទ្ធសាស្ត្រយួន។

- **រណសិរ្សបង្រួបបង្រួមជាតិខ្មែរ និង រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិខ្មែរ**[57]៖ អង្គការទាំងពីរនេះ បង្កើតឡើងនៅថ្ងៃទី ២៤ មិនា ១៩៧០ ដែលមាន កុម្មុយនិស្ត ចិន/យួន ជាអ្នកផ្តើមគំនិត និង ជាអ្នកឧបត្ថម។ បង្កើតឡើង ដើម្បីបង្កើតសង្គ្រាមនៅស្រុកខ្មែរ ដែលមានទ័ពកុម្មុយនិស្ត ជាអ្នកធ្វើសង្គ្រាម ដោយយកលេសថា មកជួយ សីហនុ វាយដេញចក្រពត្រអាមេរិកាំងឲចេញពីកម្ពុជា និង វាយរំលំ សាធារណរដ្ឋខ្មែរ។

នៅថ្ងៃទី១៧ មេសា ១៩៧៥ រណសិរ្សបង្រួបបង្រួមជាតិខ្មែរ បានទទួលជ័យជំនះ លើសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ហើយប្តូរឈ្មោះប្រទេសខ្មែរ ជា កម្ពុជាប្រជាធិបតេយ្យ ដែលមាន គណបក្សកុម្មុយនិស្ត ជាអ្នកដឹងនាំ ផ្តាច់មុខ អនុវត្តន៍ នយោបាយ ប្រល័យជាតិសាសន៍ឯង នាំឲជាតិខ្មែរបាត់កម្លាំងសំរាប់ការពារជាតិ នៅចំពោះមុខមហិច្ចិតាពាន់ឆ្នាំ របស់អ្នកដឹកនាំយួនគ្រប់សម័យ។ នយោបាយសំពឹកនេះហើយ ដែលអាចឲកងទ័ពយួន វាយចូលកាន់កាប់ប្រទេសខ្មែរ បានងាយស្រួល ហើយទទួលជ័យជំនះជាស្ថាពរ នៅថ្ងៃទី ៧ មករា ១៩៧៩។

នៅក្នុងបេសកកម្មឃោជានេះ ទ័ពយួន បានបង្កើតអង្គការពីរ ដើម្បីជាទម្រ នូវភាពពេញច្បាប់របស់គេ លើឆាកអន្តរជាតិ គឺមាន៖

- **រណសិរ្សសង្គ្រោះជាតិកម្ពុជា និង គណបក្សប្រជាជនបដិវត្តកម្ពុជា**៖ អង្គការទាំងពីរ បង្កើតឡើង នៅថ្ងៃទី ២ ធ្នូ ១៩៧៨។

គណបក្សប្រជាជនបដិវត្តកម្ពុជានេះ ជាគណបក្សដឹកនាំប្រទេសខ្មែរ មានឈ្មោះជាសាធារណរដ្ឋប្រជាមានិតុកម្ពុជា ដែលជាប្រទេសនៅក្រោមការកាន់កាប់ឃោជាយួន។ ការកាន់កាប់នេះត្រូវសហគមន៍អន្តរជាតិ ថ្កោលទោសយ៉ាងខ្លាំង ព្រោះជាការបំពានជាក់ស្តែង លើច្បាប់អន្តរជាតិ ទោះបី អាចជួយជីវិតប្រជាជនខ្មែរ ឲរួចពីការសម្លាប់រង្គាលពីសំណាក់របបខ្មែរក្រហមក៏ដោយ។

ការកាន់កាប់យួន នៅស្រុកខ្មែរ នាំឲមានបន្តសង្គ្រាម រវាងកងទ័ពយួន នឹងក្រុមខ្មែរតស៊ូរ ដេញកងទ័ពយួនឲចេញពីកម្ពុជា។ ក្រុមនេះមានបីភាគី រួមគ្នាជារណសិរ្សរំដោះតែមួយ៖

- **រណសិរ្ស រំដោះប្រជាពលរដ្ឋខ្មែរ៖** រណសិរ្សនេះ បង្កើតឡើង ដោយ លោក សឺន សាន នៅថ្ងៃទី៩តុលា ១៩៧៩ មានយោធាប្រមាណ ១១.០០០ នាក់,

57 FUNK et GRUNK។

- **រណសិរ្សរួបរួមបង្រួមជាតិ ដើម្បី កម្ពុជា ឯករាជ្យ អព្យាក្រិត, សន្តិភាព និង សហការ (ហ្វុនស៊ីនប៉ិច)៖** សម្តេច សីហនុ ជាអ្នកបង្កើត រណសិរ្សនេះ ប្រកាសឡើង នៅក្នុងខែ មិនា ១៩៨១នៅក្រុង Pyongyang។ បន្ទាប់មក ព្រះអង្គ បានបង្កើត **កងទ័ពអ្នកសីហនុនិយម** មាន យោធា ប្រមាណ ៥.០០០នាក់,

- **ភាគី កម្ពុជាប្រជាធិបតេយ្យ** ឬ ភាគី ខ្មែរក្រហមដែលជា អតីត រដ្ឋកម្ពុជាប្រជាធិបតេយ្យ។ ភាគីនៅមានសល់ចំនួនយោធា ប្រមាណ ២០.០០០ នាក់។ ភាគីបន្តការតស៊ូ រំដោះកម្ពុជា ពីការកាន់កាប់ យោធាយួន។

- **គណបក្សប្រជាជនកម្ពុជា៖** គណប្រជាជនបដិវត្តកម្ពុជា (គ.ប.ប.ក.) ត្រូវបានប្តូរឈ្មោះមកជា គណបក្សប្រជាជនកម្ពុជា នៅក្នុងការសម្រេចចិត្ត នៃមហាសន្និបាតវិសាមញ្ញ តំណាងទូទាំប្រទេស នៅថ្ងៃទី ១៨ តុលា ១៩៩១ សំរាប់ឆ្លើយនឹងសភាពការណ៍ថ្មី ក្នុងឋានៈ ជាគណបក្សនយោបាយមួយ ក្នុង ផែនការក្របខ័ណ្ឌ នៃកិច្ចព្រមព្រៀងរួម នៃភាគីខ្មែរ របស់គណកម្មការអចិន្ត្រៃយ៍ នៃក្រុមព្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

ភាគីទាំងបី ធ្វើការប្រយុទ្ធ តទល់នឹង កងទ័ពយួន នៅស្រុកខ្មែរ មានចំនួន២០០.០០០នាក់ ហើយមានទីតាំងខុសគ្នានៅតាមបណ្តោយព្រំដែន ខ្មែរ/ថៃ។ទទួល ការឧបត្ថម ជាលុយកាក់ក្តីជាសម្ភារៈក្តី ពីសំណាក់ ចិនប្រជាមានិត្, សហរដ្ឋអាមេរិក និង គ្រប់ប្រទេសជា សមាជិក អាសេអាន (ASEAN)។

**សេចក្តីសង្កេត** :

សង្គ្រាមថ្មីនេះ ជាសង្គ្រាមចម្លែកមួយ ព្រោះនៅក្នុងជួរអ្នករំដោះ មាន ឃាតករសម្លាប់ជាតិឯង គឺពួកខ្មែរក្រហម ជាភាគីសំខាន់ជាងគេ ដែលនាំឲប្រជាជនខ្មែរ រស់នៅក្រោមការត្រួតត្រាយួន មានអារម្មណ៍ហួសចិត្ត មិនអាចយល់បានអំពីសារជាតិនៃពាក្យរំដោះទោះបីខ្លួន ស្អប់យួនយ៉ាងណាក៏ដោយ។ អារម្មណ៍ហួសចិត្តនេះឯង ដែលនាំឲខ្មែរភាគច្រើន មិនគាំទ្ររណសិរ្សរំដោះជាតិនេះឡើយ ដែលនាំឲទ័ពយួនកាន់កាប់ស្រុកខ្មែរមានលទ្ធភាពត្រួតត្រាស្រុកខ្មែរបានយ៉ាងងាយបំផុត។ ទោះបី ចិនប្រជាមានិត្ ខំប្រឹងយកឈ្មោះ សីហនុ មកតែងលំអ ទ្វាររផ្ទះយ៉ាំងណាក៏ដោយ តែក្លិនឆ្អាបរបស់ពួកខ្មែរក្រហម វាភាយក្នុងអាកាសស្រុកខ្មែរ ធ្វើឲខ្មែរ សល់ពីស្លាប់ **ឆ្អិតទ្រូង**[58]ឬទុកវត្តមានភាគីខ្មែរក្រហមនេះ ជា ការប្រមាថ ចំពោះខ្លួនតែម្តង។ សង្គ្រាមថ្មីនេះ មិនមែនជាសង្គ្រាមប្រជាជននោះឡើយ វាមានធាតុពិត ជាសង្គ្រាម របស់សហគមន៏អន្តរជាតិ ផ្អែកលើគោលច្បាប់អន្តរជាតិ គឺការមិនទទួលស្គាល់ លទ្ធជ័យជំនះ[59] របស់កងទ័ពយួននៅក្នុងស្រុកខ្មែរ ដែលគេទុកជាការឈ្លានពាន របស់ប្រទេសមួយ ទៅលើប្រទេសមួយទៀ

---

58 ឆ្អិតទ្រូង= មិនសប្បាយចិត្តជាខ្លាំង ; Profondément mécontent។
59 លទ្ធជ័យជំនះ= ការទទួលបានជ័យជំនះរួចស្រេច ; Victoire acquise។

ត។មួយវិញទៀត ជាសង្គ្រាម រវាង ចិន នឹងយួន ដើម្បី អារកាត់ លក្ខន្តិក: កម្ពុជា នៅចន្លោះ ចិននឹងយួន។ ចំពោះ លោកសេរី សង្គ្រាមនេះ ជាសង្គ្រាម ទប់ទល់ ដំណើររសាយលទ្ធិកុម្មុយនិស្ត ចូលទៅក្នុងប្រទេស ថៃ ម៉ាឡេស៊ី ភូមា ជាអាថ៌។ ប្រទេស អ្នកផ្តល់ សព្វាវុធ ដល់យុទ្ធការី មិនដែលមានជំនឿថា សង្គ្រាមនឹងបញ្ចប់ ដោយមានអ្នកឈ្នះ អ្នកចាញ់ តាមមធ្យោបាយយោធានោះឡើយ ព្រោះគូរប្រយុទ្ធទាំងសងខាង គ្មានការគាំទ្រ ពីប្រជាជនដូចគ្នា ហើយគ្មានមធ្យោបាយផ្ទាល់ខ្លួន សំរាប់ធ្វើសង្គ្រាមនោះផង។ អស់រយៈពេលមួយទស្សវត្សរ៍ សង្គ្រាមនេះ នាំបង្កើតតែទុក្ខវេទនា ដល់ប្រជាពលរដ្ឋ មិនអាចពិពណ៌នាបាន។ តែនៅក្នុង ទុក្ខវេទនា ខ្មែរនេះ កុម្មុយនិស្តយួន ថ្មែឲបានជាភាគចំណេញ គឺ ការបញ្ជូលជនជាតិយួន មករស់នៅក្នុងស្រុកខ្មែរ រាប់លាននាក់។ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ១៩៩១ ចំពោះយួន ជាមហាជោគជ័យមួយ ព្រោះគេអាចបញ្ជូលសាធារណរដ្ឋប្រជាមានិតុកម្ពុជា ដែលជា របប រណបគេដាច់ថ្លៃ ឲក្លាយជា ភាគីខ្មែរពេញមុខមួយ ក្នុងការ រកដំណោះស្រាយតាមផ្លូវនយោបាយ នៃសង្គ្រាមនៅកម្ពុជា។

យើងឃើញថា បញ្ហារបស់ខ្មែរ ហើយ ដំណោះស្រាយ របស់វា វារបូតពីដៃខ្មែរទាំងស្រុង ដែលនាំឲប្រជាពលរដ្ឋ ទទួលរងជានិច្ច អំពី «**នយោបាយប្រាកដនិយម**[60]»របស់មហាអំណាច។ ទោះបីមានអន្តរាគមន៍ ពីអង្គការសហប្រជាជាតិយ៉ាងណាក៏ដោយ តែនៅពីក្រោយ នៃអន្តរាគមន៍នេះ មានយុទ្ធសាស្ត្រ នៃនយោបាយ របស់មហាអំណាច ឈរលើ «នយោបាយប្រាកដនិយម» រកចែកចំណេញ ដើម្បី រកសមតា នៃនយោបាតទូតនិងសេដ្ឋកិច្ច របស់មហាអំណាច។ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ គឺធ្វើឡើងក្នុងគំនិតនេះឯង ដែលនាំឲមានគុណវិបត្តិក្នុងការអនុវត្ត ដែលនាំឲវៀតណាមដែលជាអ្នកឈ្លានពានកម្ពុជា ឆ្លៀត រក្សាអំណាចខ្លួននៅកម្ពុជាជានិច្ច ដោយប្រើនាដការខ្មែរ ដូចយ៉ាង សម្តេច សីហនុ និង លោក ហ៊ុន សែន ជាអ្នកប្រតិបត្តិ នូវនយោបាយរបស់គេ។

## សេចក្តសន្និដ្ឋាន

បើប្រសិនណា គំនិតនយោបាយខ្មែរ ដែលបានរៀបរាប់ខាងលើនេះ ឈរលើគំនិតជាតិពិតនោះ គំនិតខុសគ្នា វាគ្រាន់តែមានលក្ខណៈជា **វិធីសាស្ត្រ**[61] ក្នុងគោលដៅរួម តែប៉ុណ្ណោះ ហើយ វាឥតអាចមានគ្រោះថ្នាក់អ្វីដល់ប្រជាជាតិខ្មែរនោះឡើយ ព្រោះវិធីសាស្ត្រទាំងនោះ តែងតែលំអោនជានិច្ចទៅតាមសេចក្តីត្រូវការពិត នៃប្រជាជាតិ។ ការមានមនោគមវិជ្ជានយោបាយក្នុងខ្លួន មិនទុកជាអវិជ្ជាមាននោះដែរ ព្រោះមនោគមវិជ្ជា

[60] Realopitik។

[61] វិធីសាស្ត្រ =Approche។

នយោបាយ នាំឲបុគ្គលម្នាក់ៗ ចេះគិតពិចារណាដោយជម្រៅ នូវអ្វីដែលខ្លួនមានជំនឿលើវា។ គ្រប់ការអប់រំមនុស្ស តែងតែយក សីលធម៌ជាគោលដៅ ក្នុងដំណើរលើផ្លូវល្អ សំដៅរក ការរំដោះខ្លួនចេញពី ការវេទនា តណ្ហា និងអវិជ្ជា ដែលជា **សីល**[62] សំរាប់មនុស្សលោក។

តែមនោគមវិជ្ជានយោបាយ អាចប៉ះទង្គិចគ្នា ក្នុងប្រការបីយ៉ាងៈ ១. ការធ្វើវិភាគ ; ២. គោលវិធីអនុវត្តន៍ ; ៣. ចរិតនៃមនុស្ស ; ៤. គោលការណ៍ នៃគំនិត និង ទីដៅ នៃគោលគំនិត។

មនោគមវិជ្ជា នៃគណបក្សកុម្មុយនិស្តខ្មែរ គ្រប់និន្នាការនយោបាយ មិនដែលទុកប្រយោជន៍ជាតិជាធំនោះឡើយ ដូចបានជំរាបខាងលើនេះ ដូច្នេះ វិធីសាស្ត្រ នៃគណបក្សនេះ មិនអាចជាកម្លាំងសំរាប់ កសាងជាតិខ្មែរបាននោះទេ។ ខ្មែរយើងជឿជាក់ច្បាស់ថា មានតែលទ្ធិប្រជាធិបតេយ្យសេរី ដែលខ្មែរអាចទុកជាកម្លាំងខ្មែរ ដើម្បីធ្វើសមិទ្ធិកម្ម នូវបំណងនៃប្រជាជាតិខ្មែរ គឺ ឯករាជ្យជាតិ និង សេរីភាព នៃពលរដ្ឋខ្មែរ។ ការពិសោធ របស់ លទ្ធិកុម្មុយនិស្តនៅស្រុកខ្មែរ មិនអាចបន្តទៅមុខបាននោះឡើយ ព្រោះលទ្ធផល នៃការពិសោធ វាជា វិនាដកម្មមួយ ដល់ជាតិខ្មែរ ដែលនាំឲ ប្រទេសវៀតណាម គេជាអ្នកទទួលផល រហូតមកដល់សព្វថ្ងៃនេះ។

62 សីល =Conduite éthique។



# លទ្ធិប្រជាធិបតេយ្យ

ដូចពួក អ្នកទុទន្ដិនិយម ជាពិសេស ពួកបារាំង ដែលធ្លាប់បានមក ត្រួតត្រាខ្មែរ នៅសម័យ អាណានិគម តែងមានជំនឿថា ភ័ព្វអាក្រក់ របស់ស្រុកខ្មែរ គឺការយកមកអនុវត្តន៍ នូវលទ្ធិប្រជាធិបតេយ្យ នៃប្រទេស មហាអំណាច និយមលទ្ធិប្រជាធិបតេយ្យសេរី ដោយមិនចេះធ្វើការអប់រំ ដល់ មហាជន នូវគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ។ ពួកទាំងនេះយល់ឃើញថែមទៀតថា ប្រជាជនខ្មែរ មានទម្លាប់ ដូចប្រជាជាន ដទៃឯទៀត នៅដំបន់អាស៊ី ទទួលរង នូវទម្ងន់ រាប់ម៉ឺនឆ្នាំ នៃរបបអត្តាធិបតេយ្យ ដែលនាំឲខ្លួន មានការលំបាក សម្របសម្រួលខ្លួននឹង របបលទ្ធិប្រជាធិបតេយ្យ។

សំណួរដែលខ្ញុំសួរ គឺៈ តើ លទ្ធិប្រជាធិបតេយ្យ ជាចំណេះ នៃវិទ្យាស្សង្ស ដែលចាំបាច់តម្រូវឲប្រជារាស្ត្រ ធ្វើការសិក្សាវា ជាមុន មុននឹងយកវាមកអនុវត្តន៍ នោះឬ ? សំណួរមួយទៀត គឺៈ ហេតុអ្វី គេតែងតែ ធ្វើការចោទប្រាកាន់ជានិច្ច ដល់ប្រជារាស្ត្រ នៅពេលណា មានបញ្ហា ក្នុងការអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យ ? សំណួរជាទីបញ្ចប់ គឺៈ តើលំអាន នៃលទ្ធិប្រជាធិបតេយ្យ របស់មហាអំណាច ជាលំអាន ដែលចៀសមិនរួច ក្នុងការយកមកអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យ នោះឬ ? ចម្លើយនឹងសំណួរទាំងឡាយនេះ នាំឲយើង ស្វែងរក សារជាតិ នៃលទ្ធិប្រជាប្រជាធិបតេយ្យ។

**តើអ្វីទៅ ជា លទ្ធិប្រជាធិបតេយ្យ ?**

ហេតុអ្វី បានជា ប្រជាពលរដ្ឋខ្មែរ មានការពិបាកក្រៃពេក ក្នុងការអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យ ដែលខ្លួនជាប្រជាពលរដ្ឋមួយ ធ្លាប់ឆ្លងកាន់ក្នុងប្រវត្តិសាស្ត្រ ស្គាល់នូវភាពរុងរឿង និង អម៉ាស់មុខ ដែលជាការពិសោធ សំរាប់ ដំណើរ នៃការវិវត្តន៍ តាមចរន្តនៃសេចក្ដីចម្រើន នៃមនុស្សជាតិ ? តើ លទ្ធិប្រជាធិបតេយ្យ ជា វិធី នៃការត្រិះរិះ របស់មស្ទីមប្រទេស ? តើវិធីនេះ ចុះនាម (s’inscrit) ក្នុងការវិវត្តន៍ ជាធម្មជាតិ នៃការលូតលាស់នៃមនុស្សជាតិ ? តើប្រវត្តិសាស្ត្រខ្មែរ មានទុកស្នាម នៃលទ្ធិប្រជាធិបតេយ្យ ដែរឬទេ ?

ក្នុងឆ្នាំ ១៩៤៦ នៅប្រទេសខ្មែរ មានអ្នកចេះដឹង បែបវិទ្យាស្សង្ស តិចតួចបំផុត គឺប្រមាណ ១០០ នាក់ នៅក្នុងប្រទេសមួយ មានប្រជាជន ប្រមាណ ៥ លាននាក់ ហើយនៅក្រោមអាណានិគមបារាំង ចំនួន ៩០ ឆ្នាំ មានលទ្ធផលតិចតួចបំផុត សំរាប់ចាក់គ្រិះនៃពន្លឺបញ្ញា សំរាប់សង្គមខ្មែរ។ ការណ៍ (Fait) ហ្នេះ នាំឲខ្មែរយើង ចោទសួរជាសំណួរ

ថា អាណានិគមបារាំង បានធ្វើអ្វីខ្លះ សំរាប់ លើកកំពស់ នៃការចេះដឹងខ្មែរ ក្នុងវិស័យ វិទ្យាសស្ត្រ និង គោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ ?

គួរខ្មែរយើងដឹងដែរ អំពីបេសកកម្ម នៃអាណានិគមបារាំង នៅស្រុកខ្មែរ។

អាណានិគម មាន បេសកកម្មពីរះ

១. សង្គ្រោះ ស្រុកខ្មែរ ដែលបារាំងគេទុកជា «រាជាណាចក្រ មានភាពស្ងប់ជារឿងព្រេង» (un royaume calme légendaire) នៅចំពោះមុខ ការកំរាមកំហែង ពីសំណាក់ប្រទេសជិតខាង មានប្រទេសយួន និង សៀម។

លោក សាស្ត្រាចារ្យ បារាំងម្នាក់ ឈ្មោះ Armand ROUSSEAU បានសរសេរថា «អន្តរាគមន៍បារាំងនៅក្នុងស្រុកខ្មែរ គ្មានលក្ខណៈ ជាការបង្ខំ ពីសំណាក់បារាំង នោះឡើយ គឺជាការចូលមកជួយ ដោយមានការស្នើរសុំ ជា សយម្ភូ (Spontané) ពីមហាក្សត្រខ្មែរ ដើម្បីជួយសង្គ្រោះ ស្រុកខ្មែរ និង រក្សា មកុដរាជ្យព្រះអង្គ ដែលកំពុងតែរលាយបាត់បង់។ ដោយសារតែអន្តរាគមន៍បារាំងនេះឯង ដែលអាចឲ្យ ស្តេច នរោត្តម ទ្រង់អាចសោយព្រះទិវង្គត ជាមហាក្សត្រខ្មែរ ក្រោយពីព្រះអង្គបានសោយរាជ្យ អស់រយៈពេលយ៉ាងយូរ ក្នុងនគរមានសន្តិភាព និងមាន វិបុលភាព ដែលស្រុកខ្មែរ បាន បាតបង់ អស់ច្រើនសតវត្សមកហើយ។

២. ជាការរំលឹក ដល់ប្រជាពលរដ្ឋខ្មែរ ថា ស្រុកខ្មែរជាស្រុកធ្លាប់មានអារ្យធម៌រុងរឿងក្នុងសម័យអង្គ ដែលត្រូវគេបំភ្លេចវាចោល ដោយអយុត្តិធម៌ជាទីបំផុត។

ពិតមែនថា របបរាជានិយមខ្មែរ យល់ស្របទាំងស្រុង នូវគំនិតទី១ នៃបេសកកម្មបារាំង តែ សម្តេច សីហនុ កាលព្រះអង្គ នៅជាព្រះប្រមុខរដ្ឋ នៃ រាជាណាចក្យ កម្ពុជា ថ្លែងនៅពេលសន្និសីទ នៅមហាវិទ្យាល័យច្បាប់ នៅទីក្រុង បារីស នាថ្ងៃទី២៩ មិថុនាឆ្នាំ ១៩៦៤ថា៖

«ការមកដល់ស្រុកខ្មែរ នៃអាណាព្យាបាលបារាំង នៅឆ្នាំ ១៨៦៣ ជាការសង្គ្រោះប្រជាជាតិខ្មែរ ពីការរលាយរូប ពិត តែក៏ជាការដាក់ ប្រទេសខ្មែរ ឲនៅក្រោមភាពអំណាចជិះជាន់មួយដែរ។ បើយោងតាមស្ថានភាពនៅស្រុកខ្មែរ ក្នុងពេលនោះ ខ្មែរអាចទទួលយកបាន នូវអាណាព្យាបាលបារាំង តែ កិច្ចសន្យា ក្នុងឆ្នាំ ១៨៨៤ ជាការបង្ខំដោយប្រើអំណាច ទៅលើ ព្រះមហាក្សត្រខ្មែរ ដាក់ រដ្ឋបាលខ្មែរ ឲនៅក្រោមការត្រួតត្រាបារាំងផ្ទាល់ ដែលជាអំពើ បង្អាប់បន្ថោក ដល់ ព្រះមហាក្សត្រខ្មែរ ឲព្រះអង្គក្លាយជា អាយ៉ង និង នាំប្រទេសខ្មែរ ឲក្លាយជាប្រទេសអាណានិគមបារាំង។ ការសំគាល់ បែបដូចយនេះ

ហើយដែល រាជានិយមខ្មែរ ទទួលស្គាល់ នូវតួនាទី ដ៏វិសេសវិសាល របស់ ព្រះវរៈក្សត្រ នរោត្តម ដែលជាអ្នកបើកទ្វារប្រទេសខ្មែរ ចំពោះ មស្ជីមប្រទេស»។

តែគេអាចសួរបានថា ការបើកទ្វារនេះ មានធាតុដូចគ្នានឹង ការបើកទ្វារ នៃប្រទេស ជប៉ុន ក្នុងឆ្នាំ ១៨៦៨ នៅដើម សករាជ ម៉េហ្ស៊ី (Maiji) ឬទេ ?

តែគ្មានអ្វីជាការពិបាកយល់នោះឡើយ បើយើងយក សន្និសញ្ញាអាណាព្យាបាលបារាំង មកអានពិនិត្រមើល យើងឃើញថា ការអភិវឌ្ឍន៍ នៃលទ្ធិប្រជាធិបតេយ្យ មិនមាន ថែងចង់(composer) ជាវត្ថុអ្វីនោះឡើយ។ ហើយត្រូវយើងដឹងថា នៅស្រុកបារាំងជំនាន់ នោះ ខ្លួនក៍មិនមែនជាប្រទេសប្រជាធិបតេយ្យនិយមនោះដែរ ដូច្នេះបារាំងគ្មានលទ្ធ ភាពឯណា លើកយក គោលការណ៍ នៃលទ្ធិនេះ មកស្នើរ ឲរាជានិយមខ្មែរ អនុវត្តន៍នោះ ឡើយ។

នៅទីនេះ យើងមិនរក ធ្វើការប្រៀបធៀប រវាង ប្រទេសខ្មែរ ជាមួយ ជប៉ុន ព្រោះប្រជា ជន និង ប្រទេសទាំងពីរនេះ មានលក្ខណ:ខុសគ្នា។ តែយើងមានបំណងយ៉ាងងាយ ស្រួលគឺ បង្ហាញនូវឆន្ទ: នៃប្រទេសទាំងពីរនេះ ក្នុងការបើកទ្វារប្រទេស ចំពោះ មស្ជីមប្រទេស នៅក្នុងពេលវេលាប្រហាក់ហែលគ្នា។ គួរដឹង អំពីដើមហេតុផល នៃការបើក ទ្វារប្រទេសទាំងពីរនោះដែរ៖ ចំពោះប្រទេសជប៉ុន គឺ មិហិច្ឆិតា ធ្វើ ទំនើបភាវូបនី យកម្ម គ្រប់វិស័យ៖ សេដ្ឋកិច្ច, បច្ចេកទេស, នយោបាយ និង ការអប់រំជាតិ ផ្អែកលើមូល ដ្ឋាន «ព្រលឹងជាតិ» (Esprit national) ដែលយើងអាចសង្ខេបជាឃ្លាខ្លីមួយថា៖ «គំនិត ជប៉ុន និង បច្ចេកទេសមស្ជីមប្រទេស» គឺថា គំនិតជាតិ ត្រូវដាក់លើ គំនិតបរទេស ជា និច្ច។ ទោះបី ការបើកទ្វារនេះ នាំបង្កើតសង្គ្រោមស៊ីវិលក្តី តែវាមានជោគជ័យជាក់ស្តែ ង គឺនាំឲប្រទេសជប៉ុន ក្លាយជាប្រទេស មានកំពស់បញ្ញា ស្មើនឹងមស្ជីមប្រទេស។ របប ថ្មីនេះ ប្រព្រឹត្តជាសុក្រិតភាព ក្នុងប្រទេស ដែលមានតម្លៃប្រពៃណីជាតម្លៃ នៃសង្គម ជាតិជប៉ុន។ នៅពេលដែល ប្រទេសជប៉ុន ចាញ់សង្គ្រាម អាមេរិកាំងទោះបីរាជានិយម ជប៉ុន មានជាប់ពាក់ពន្ធដោយចំពោះ ក្នុងសេចក្តីសម្រេចចិត្តធ្វើសង្គ្រាម ក៍ ដោយ ក៍ អាមេរិកាំង នៅតែរក្សារបបរាជានិយម ដដែល តែគេ ធ្វើកំណែទម្រង់ នូវ លក្ខណ: នៃសក្តិភូមិនិយម ឲក្លាយជារាជានិយម សម័យ តម្រូវតាម នូវការបង្ខំ នៃលទ្ធិ ប្រជាធិបតេយ្យសេរី។ ត្រូវដឹងថា រាជានិយម ជាប្រពៃណីជាតិ រីឯ សក្តិភូមិនិយម ជាវិធី ដឹកនាំជាតិ របស់រាជានិយម។ ដូច្នេះអាមេរិកាំងយល់ឃើញថា គេអាចរក្សា រាជា និយម តែ ត្រូវដូរ វិធីដឹកនាំជាតិ។ ការប្តូររបបដឹកនាំនេះ មានផលទៅលើប្រជាជនជ ប៉ុនផ្ទាល់ គឺថា ជនជប៉ុនម្នាក់ៗ ទទួលនូវសេរីភាពក្នុងការស្វែងរក ការលើកជីវភាពរស់ នៅរបស់ខ្លួន និង សេរីភាព ក្នុងការសំដែងមតិ នៅក្នុងសង្គម។ ការឲស្ត្រីមានសិទ្ធិបោះ

ឆ្នោត ជាការពន្លិចបំថែមទៀត នូវតម្លៃ នៃជីវិតនយោបាយ ក្នុងសង្គម។ ត្រូវដឹងថាអាមេរិកាំង បង្ខំឲ្យប្រទេសជប៉ុន យកលទ្ធិប្រជាធិបតេយ្យ មកអនុវត្តន៍  ក្នុងគោលបំណងតែមួយគត់ គឺ ការចម្រើនលូតលាស់ នៃប្រជាជនជប៉ុន។ គេដឹងថា បើមានគោលបំណងមិនល្អ គឺ មានលទ្ធផល មិនល្អ នោះឯង។

ត្រឡប់មកមើលស្រុកខ្មែរវិញម្តង។ ថ្ងៃទី ១១ កក្កដា ឆ្នាំ ១៨៦៣ ព្រះមហាក្សត្រខ្មែរជាមួយអ្នកតំណាង នៃរដ្ឋាភិបាលបារាំង បានស្រុះស្រួលគ្នា ចុះហត្ថលេខា លើសិទ្ធិសញ្ញាអាណាព្យាបាល ដាក់ប្រទេសខ្មែរ ក្រោមការការពារ របស់បារាំង។ បើយើង ពិនិត្យ មើលយ៉ាងល្អិតល្អន់ នូវសិទ្ធិសញ្ញានេះ យើងឃើញថា នៅក្នុងជំនាន់នោះ បារាំង គេមានគោលបំណងតែមួយគត់ គឺ ស្វែងរក អត្ថប្រយោជន៍គេ នៅក្នុងដំបន់ ដោយប្តូរ នូវ សេវា នៃការការពារ តាមមធ្យោបាយ យោធា ដល់ព្រះមហាក្សត្រខ្មែរ។ ជាការពិតណាស់ហើយថា សិទ្ធិសញ្ញានេះ អាចរារាំង ប្រទេស សៀម និង យួន មិនឲបន្ត ឈ្លានពានទឹកដីកម្ពុជា តែគេដឹងថា ប្រទេសខ្មែរ ក្រោយពីបានឯករាជ្យ នៅក្នុងឆ្នាំ ១៩៥៣ បានជួបប្រទះ នូវបញ្ហា ព្រំដែន ជាច្រើន នៅខាងកើត ក៏ដូច ខាងលិច ដែលបារាំងគេទុកឲដោះស្រាយ។ ទឹកដីខ្មែរប្រមាណជាងពាក់កណ្តាល ត្រូវបានប្រទេសជិតខាង គេយកទៅបញ្ចូលក្នុងទឹកដីរបស់គេជាស្ថាពរ។

មួយវិញទៀត ជំនួបស្រុក ខ្មែរ ជាមួយ បារាំង ដែលគេចាត់ទុកជាប្រទេស នៃសិទ្ធិមនុស្ស និង សេរីភាព មិនបានកាត់បន្ថយ នូវឥទ្ធិពល នៃអំណាចផ្តាច់ការ ដែលគេដឹងថា អវសាន នៃអំណាចនេះ អាចនឹងនាំបង្កើតឲមានការរីកចំរើនលូតលាស់ក្នុងសង្គមជាតិ ដែលអំណាចផ្តាច់ការ គេតែងតែទុកវា ជាកត្តា បន្ទាប់បន្សំ បើប្រៀបធៀបនឹងកត្តា នូវរមណីយអំណាច របស់ពួកអ្នកផ្តាច់ការនិយម។ សង្គមខ្មែរ ក្រោមអំណាច អាណានិគម ចំនួន៩០ឆ្នាំ មាន ស្ថេរភាព ដ៏ប្រសើរ មាន សុខុមាលភាព ដ៏ស្ងប់ស្ងាត់ចិត្ត ពិតប្រាកដមែន តែសេចក្តីសុខនេះ វាកើតឡើងពី ពួកអ្នកចេះដឹង នាំគ្នាខ្លាចអំណាច និង បាតប័ត្រ (résignation)[63] នៃមហាជន តែប៉ុណ្ណោះ។ ភាពកម្លាចនិងបាតប័ត្រនេះ ទុកជាភាពរុងរឿង នៃច្បាប់សីលធម៌ របស់សង្គមប្រពៃណីដែលមានប្រជាជន មួយចំនួន ជាអ្នកជឿព្រហ្មលិខិតបណ្តោយខ្លួនតាមវាសនា ជាអ្នកខំថែរក្សា ព្រោះមានចែងក្នុងជំនឿសាសនា ជាពិសេសមាននៅក្នុង គោលការណ៍ នៃ «បុណ្យ

63 បាតប័ត្រ= ការលះបង់សិទ្ធឲអ្នកណាម្នាក់, ការទ្រាំទ្រ អត់ធ្មត់។

បាប» ដែលជាផលា នៃអំពើល្អ ឬ អាក្រក់ ដែលមនុស្សម្នាក់ៗ បានប្រព្រឹត្តនៅក្នុង អតីតជាតិខ្លួន។ ក្នុងចំណុចនេះឯង ដែលខ្មែរយើង មិនអាចចោទបារាំង ថាជាអ្នកទទួលខុសត្រូវ តែម្នាក់ឯង នូវនិច្ចលភាព នៃសង្គមប្រពៃណីខ្មែរ ក្រោមអាណានិគមបារាំង។ អ្នកដឹកនាំ និង ប្រជាជនខ្មែរ ក៍មានការទទួលខុសត្រូវមួយចំណែកធំដែរ នៅចំពោះមុខស្ថានភាពនេះ គួយ៉ាង ការសម្លាប់មហាជន ក្នុងរបប ខ្មែរក្រហម មិនអាចទុកវា ជា មរតក នៃអាណានិគមបារាំងបាននោះឡើយ។

ហេតុនេះឯង បានជាខ្មែរយើងមួយចំនួន ទទួលយល់ព្រម ថា អាណានិគមបារាំង ជាអំពើវិជ្ជមាន ខ្លះដែរ សំរាប់ស្រុកខ្មែរក្នុងសម័យសន្ធាកាល។ ជម្រើសយកបារាំងជាអ្នកការពារ ជាជម្រើស តាមពិចារណាមួយ (choix de raison) ព្រោះវានាំមកនូវ សន្តិភាព និង **សេចក្តីថ្លៃថ្នូរ** (dignité) ខ្មែរ រកឃើញឡើងវិញ នៅក្នុងប្រវត្តិសាស្ត្រជាតិខ្លួន។ កត្តាទាំងនេះជាជំនួយមួយ សំរាប់ជា ឧទ័យ[64] (émergence) នៃការលូតលាស់ ក្នុងវិស័យ សម្ភារៈ គឺ សុខាភិបាល សាធារណៈ (santé publique), ហេដ្ឋារចនាសម្ព័ន្ធ, លើកកំពស់ការចេះដឹងប្រជាជន តាមការអប់រំជាតិ និង ការភ្ជាក់ខ្លួន លើ សតិសម្បជញ្ញៈជាតិ។

ការភ្ជាក់ខ្លួន លើ សតិសម្បជញ្ញៈជាតិ នេះឯង ដែលនាំឲ មហាជន យល់ដឹងថា ព្រេងវាសនា របស់ខ្លួន នឹងអាចមានភាពប្រសើរលើសមុនបាន បើខ្លួនចេះប្រើអំណាចរបស់ខ្លួន ហើយ អ្នកចេះដឹង យល់ថាសេរីភាព និង បច្ចេកទេស ជា ទស្សនវិស័យ គ្មានទីបញ្ចប់ សំរាប់ សកម្មភាពគ្រប់បែបយ៉ាង នៃមនុស្ស ដែលនាំឲរំគាល សង្គមរមណីយ (société harmonieuse) អសកម្ម ដែលហុចឲ ជាគុណប្រយោជន៍ ដល់សង្គមថ្មីដើរសំដៅទៅរក ការលូតលាស់។ យើងដឹងថា សង្គមរមណីមិនមែន ជាសង្គម ដែលប្រជាពលរដ្ឋ ត្រូវបោះបង់ចោល នូវសទ្ធិរបស់ខ្លួន តែជាសង្គមដែល ពលរដ្ឋម្នាក់ៗ ចេះរកឃើញ សមតា ក្នុង វិវិធ (différend) នូវការប្រើ នៃសិទ្ធិរបស់ខ្លួន និង សេរីភាព សាធារណៈ (liberté publique) របស់ប្រជាពលរដ្ឋ។

ក្រោយពីប្រទេសអាណានិគម នៅក្នុងពិភពលោក បានទទួល ឯករាជ្យ គេនាំគ្នាយល់ឃើញថា សេរីភាព ជា ការរីកចំរើន ហើយនាំគ្នា យក លទ្ធិប្រជាធិបតេយ្យសេរី ជា វិធីដឹកនាំជាតិ។ ប្រហែលនៅចុងសតវត្សទី២០ គេសង្កេតឃើញថា ជម្រើសនេះ មានការវិវត្តន៍ដ៏ប្រសើរ ដែលអាចរំលំ អំណាចផ្តាច់ការខ្លាំងក្លាបាន ទោះបីជាអំណាច យោធា

---

64 ឧទ័យ= ផុសឡើង, អណ្តែតឡើង។

និយម ក្ដី កុម្មុនិស្ដនិយម ក្ដី។ ដូច លោក Francis Fukuyama អ្នកនិពន្ធ ជនជាតិអាមេរិកាំង សរសេរថា ក្រោយពីការរំលំ លទ្ធិកុម្មុយនិស្ដ នៅ អឺរ៉ុប និង សហភាពសូវៀត មក នៅសល់តែលទ្ធិប្រជាធិបតេយ្យសេរី ទេ ដែលជា បស្សាសៈ នយោបាយ មានភាពរឹងប៉ឹង តែមួយគត់ សំរាប់ ប្រជាពលរដ្ឋ រស់នៅ ក្នុងដំបន់  និង មាន វប្បធម៌ ខុសគ្នាៗ នៅលើ **ភូគោល** (globe terrestre)។ លើសពីនេះទៅទៀត គេឃើញថា គោលការណ៍ នៃសេដ្ឋកិច្ចសេរី «ផ្សារសេរី» រាលដាល ពាសពេញ ពីភពលោក ហើយ ផលិត នូវវិបុលភាព លើសលុប ក្នុងវិស័យសម្ភារៈ ទាំងនៅក្នុងប្រទេសមានការជឿនលឿន ក្នុងផ្នែកឧស្សាហកម្ម និង នៅក្នុងតតីយលោក។ ជោគជ័យ នៃលទ្ធិប្រជាធិបតេយ្យសេរីនេះ ជាផល នៃដង្ហើមនៃសេរីភាពរួម របស់មនុស្សជាតិ ដែលទុកដាក់ តម្លៃមនុស្ស ស្របគ្នានឹងដំណើរ នៃសេចក្ដីរីកចម្រើន គ្រប់វិស័យ ជាពិសេស ក្នុងវិស័យ បរិស្ថាន ដែល លោក Edgar Morin អ្នកនិពន្ធ ជនជាតិបារាំង ឲឈ្មោះថា «នយោបាយ នៃមនុស្សជាតិ»។ នយោបាយនេះឈរលើ ទស្សនៈ «ដែនដី-មាតុភូមិ» ត្រកង ដោយខ្លួនឯង នូវសតិសម្បជញ្ញៈ នៃវាសនាតែមួយ អត្តសញ្ញាណតែមួយ មានដើមកំណើតជាមនុស្សលោកតែមួយ នៃមនុស្សជាតិ។

សួរថា តើ លទ្ធិប្រជាធិបតេយ្យសេរី នឹងអាចជា របបនយោបាយ តែមួយ ដែលនឹងអាចឲមនុស្សលោក រស់នៅ សមស្របពិត តាមតម្លៃ នៃ សេចក្ដីថ្លៃថ្នូរ នៃមនុស្សលោក បានដែរឬទេ។ តាមការយល់ឃើញរបស់ លោក Hegel ទស្សនវិទូរ សរសេរថា ? សេចក្ដីថ្លៃថ្នូរនេះ ដឹកនាំមនុស្ស ក្នុងដើម នៃសតវត្ស ឲប្រយុទ្ធលុះដល់មរណា ដើម្បីយកវាឲបាន។ គេដឹងថា ការប្រយុទ្ធ គ្មានពេលសំរាក អស់ច្រើនសតវត្ស ត្រូវបានទទួលជ័យជំនះ ក្នុងឆ្នាំ១៩៤៨ ដែលមានការប្រកាសជាសាកល នៃសិទ្ធិមនុស្ស ពីសំណាក់ ប្រទេសចំនួន ៥៨ដែលជា សមាជិក នៃអង្គការសហប្រជាជាតិ។ ចាប់ពីពេលនោះមក «សេចក្ដីថ្លៃថ្នូរនៃមនុស្សលោក» ត្រូវគេទទួលស្គាល់ ជាតម្លៃរួម របស់ជីវិត គ្រប់ បុគ្គលិកលក្ខណៈនៃមនុស្ស។ គឺជាតម្លៃ សជ្ឈន្តិកៈ[65] (intrinsèque) របស់ មនុស្សលោកម្នាក់ៗ។ តាមលោក Hegel តម្លៃនេះ ជា ចលករ នៃដំណើរ ជាប្រវត្តិសាស្ត្រ នៃមនុស្សលោកទាំងអស់។ ហើយ មនុស្សលោក គឺជា បេះដូងជានិច្ច នៃមនុស្សជាតិ។

នៅក្នុងឆ្នាំ ១៩៤៦ ស្រុកខ្មែរ ជារដ្ឋ ជាសមាជិក សហភាព បារាំង បានជ្រើសរើស លទ្ធិប្រជាធិបតេយ្យសេរី ជារបបដឹកនាំជាតិ។ សួរថា តើជម្រើសនេះ មានសុភនិច្ច័យ ដែរ

---

[65] សជ្ឈន្តិកៈ= ដែលមាននៅក្នុងខ្លួន។

ឬទេ ? តើ លទ្ធិប្រជាធិបតេយ្យសេរី ត្រូវល្មមនឹង ស្ថានភាព នៃសង្គមខ្មែរ ដែលកំពុងមានការផ្លាស់ប្តូរ និង ជាសង្គម នៃអន្តរភាព ?

យើងលើកសំណួរ អម្បាមាន ខាងលើនេះមកសិក្សា ដើម្បី ស្វែងរកចម្លើយថា ហេតុអ្វីបានជាការអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យសេរី ទទួល នូវបរាជ័យ នៅក្នុងរយៈពេលពីឆ្នាំ ១៩៤៦ ដល់ឆ្នាំ ១៩៥២ ? ចម្លើយនេះត្រូវបាន លោក បណ្ឌិត កឿង  គុន  ដោះស្រាយយ៉ាងក្បោះក្បាយ នៅក្នុង និក្ខេបបទ សំរាប់សញ្ញាប័ត្របណ្ឌិត របស់លោក ដូច្នេះយើងគ្រាន់តែយក ទន្និ្ឋករណ៍ របស់ លោក កឿង គុន មកសិក្សា ហើយបញ្ចេញ នូវ វិស័យមតិរបស់យើង។ ជាជម្មតា យើង សិក្សាទន្និ្ឋករណ៍ នេះ នៅក្នុង **ស៊ុម**  (cadre) នៃប្រវត្តិសាស្ត្រនយោបាយ ដោយមានជាអាទ៍ នៃការវិវត្តិ នៃលទ្ធិប្រជាធិបតេយ្យ នៅក្នុងស្រុកខ្មែរ។ យើងសិក្សាជាសង្ខេបដែរ អំពីសង្គមខ្មែរ ដោយសាកល្បងឆ្លើយនឹងសំណួរថា តើគេអាចយកលទ្ធិប្រជាធិបតេយ្យសេរី ពីបស្ចឹមប្រទេស មកដាំនៅក្នុងស្រុកខ្មែរបានដែរឬទេ ? នៅទីបញ្ចប់ យើងលើកយក វិស័យមតិ ផ្សេងៗទៀត មកបង្ហាញ ដើម្បីឲបានយល់ អំពី បញ្ហា នៅជុំវិញ ការអនុវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យសេរី នៅស្រុកខ្មែរ។

បន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទី២មក ស្រុកខ្មែរ ក្នុងចំណោម ប្រទេសអតិតអាណានិគ ជាច្រើន មិនអាចគេញផុតពី ទ្វេបាតុភូតនៃការវិវត្តិ៖ កំណើតនៃចលនារំដោះជាតិ  និង ការដួរ ដ៍សំខាន់ នៃការទាក់ទង រវាងចលនារំដោះជាតិ នឹង អាជ្ញាធរអាណានិគម ដែលមានហេតុ ចេញពីឆន្ទៈ នៃប្រជាពលរដ្ឋចំណុះ ចង់រំដោះខ្លួនចេញពីឥទ្ធិពលបរទេស។ ឆន្ទៈនេះ ទង្គិចខ្លាំង យ៉ាងប្រាកដ នឹងឆន្ទះ នៃអ្នកត្រួតត្រា ដែលមានបំណងចង់ថែរក្សា ការទាក់ទង ក្នុងលក្ខខណ្ឌជាអ្នកត្រួតត្រា លើ អ្នកនៅក្រោមការត្រួតត្រារបស់ខ្លួន តែគ្រាន់តែកំណែទំរង់ នូវរបៀបត្រួតត្រាខ្លះ ដើម្បីបំភាន់ ដល់អ្នកនៅក្រោមអំណាចខ្លួន ថាមានការផ្លាស់ប្តូរ ដើរទៅមុខ ទៅរកការជឿនលឿន។

នៅស្រុកខ្មែរ ក្នុងឆ្នាំ ១៩៤៩ បារាំងបានស្នើរដល់រដ្ឋាភិបាលខ្មែរ នូវលក្ខន្តិកៈថ្មីមួយ៖ គឺប្រគល់ឯករាជ្យ នៅក្នុង សហភាពបារាំង។ ព្រះមហាក្សត្រខ្មែរ យល់ព្រមភ្លាម ចុះហត្ថលេខា លើសន្ធិសញ្ញានេះ ជាមួយបារាំង តែរដ្ឋសភាខ្មែរជំនាន់នោះ មិនព្រមអនុម័នដោយសំអាងថា វាមិនស្របនឹង បស្សាសៈ (សេចក្តីប្រាថ្នា) នៃប្រជាជាតិខ្មែរ។ចំណុច នៃការខ្វែងគំនិតគ្នានេះ នាំបង្កើត ទំនាស់ រវាង ព្រះមហាក្សត្រ នឹង  រដ្ឋសភា ដែលមានទំនាក់ចិត្ត គឺ ចង់បាន ឯករាជ្យជាតិ ទាំងអស់ ឬ ឯករាជ្យជាតិ ទំនឹមនឹងប្រទេស ជាសមាជិក Commonwealth នៃចក្រភពអង់គ្លេស។ ការបដិសេធ ពីសំណាក់បារាំងប្រគល់ឯករាជ្យទាំងអស់ ឲប្រជាជាតិខ្មែរ ហើយនឹង ការខ្វែងគំនិតគ្នារវាង ព្រះមហា

ក្សត្រ នឹង រដ្ឋសភា តើអាចចាត់ទុកជា ដើមហេតុ នៃវិបត្តិនយោបាយ នៅស្រុកខ្មែរ និង ជាមួយ បារាំង បានដែរឬទេ ?

តាមការសិក្សា របស់ លោក ភឿង តុន កត្តាទាំងពីរ នេះជា ដើមហេតុពិត នៃវិបត្តិនយោបាយ ក្នុងប្រទេស និង ក្រៅប្រទេស ដែលនាំឲមានកើត ចលនាខ្មែរ ទាមទារឯករាជ្យ និង ការតស៊ូ របស់អ្នកជាតិនិយម ប្រឆាំងនឹង ព្រះមហាក្សត្រផង។ ក្រុមអ្នកទី១ ប្រើអាវុធ លទ្ធិប្រជាធិបតេយ្យ រីឯ ព្រះមហាក្សត្រ វិញ ព្រះអង្គ ប្រើអំណាចប្រពៃណី។ ការទុលមុខគ្នានេះ ជាការប្រយុទ្ធ រវាង សម័យ នឹង បុរាណ ក៏ដូចជា ការទង្គិចគ្នា នៃឆ្នាំងដី នឹង ឆ្នាំងដែក ដល់ទីបញ្ចប់ នាំបង្កើតវិបត្តិរដ្ឋធម្មនុញ្ញពីរដងៈ

**វិបត្តិលើកទី១**ៈ មានដើមហេតុពី ការខ្វែងគំនិតគ្នា រវាង ព្រះមហាក្សត្រ នឹង រដ្ឋសភា ដូចបានជំរាបខាងលើរួចមកហើយ គឺថា ព្រះមហាក្សត្រ សុខចិត្ត ចុះហត្ថលេខា(៨ វិច្ឆិការ ១៩៤៩) លើសន្ធិសញ្ញា ជាមួយបារាំង ទទួលយកឯករាជ្យជាតិខ្មែរ នៅក្នុង លក្ខន្តិកៈជា រដ្ឋសមាជិក របស់ សហភាពបារាំង ដែលជាសន្ធិសញ្ញា គ្មានសេចក្ដីយល់ព្រម ពីរដ្ឋសភា។ ដើម្បីរកសុពលភាព ឲសន្ធិសញ្ញានេះបាន ព្រះមហាក្សត្រ សម្រេចចិត្ត រំលាយរដ្ឋសភាដោយព្រះអង្គ មានសង្ឃឹមថា ការបោះឆ្នោតថ្មី អាចមាន រដ្ឋសភា មួយយល់ស្របនឹងសន្ធិសញ្ញានេះ ហើយសុខចិត្ត **អោយសច្ចាប័ន** (entériner)។ តែការរំលាយនោះ ចោទជាបញ្ហា នៃការគោរពច្បាប់នៃរដ្ឋធម្មនុញ្ញ ព្រោះក្នុងមាត្រទី៦៩ **បដិញ្ញាត**[66] ថា ការរំលាយរដ្ឋសភា អាចធ្វើបាន លុះត្រាតែមានការសម្រេច ពីអង្គជំនុំនៃគណរដ្ឋមន្ត្រីហើយ មានយោបល់ពីប្រធានរដ្ឋសភា ពេលនោះ ទើបព្រះមហាក្សត្រអាចប្រកាស រំលាយរដ្ឋសភាបាន។ សួរថា តើព្រះមហាក្សត្រ ព្រះអង្គបានគោរពមាត្រានេះដែរឬទេ ?

**វិបត្តិលើកទី២**ៈ វិបត្តិលើកទី២នេះ មានរូបរាង ជា រដ្ឋប្រហារ នៃរដ្ឋធម្មនុញ្ញ មានកើតឡើងនៅថ្ងៃទី ១៥ មិថុនា ឆ្នាំ ១៩៥២។ ត្រូវដឹងថាការបោះឆ្នោត រើសសមាជិករដ្ឋសភាថ្មី មិនបានឆ្លើយស្របនឹងបំណង របស់ព្រះមហាក្សត្រនោះឡើយ ព្រោះ រដ្ឋសភាថ្មី ក៏នៅតែមិនព្រមអោយសច្ចាប័ន ដល់សន្ធិសញ្ញានោះដដែល ដែលនាំព្រះមហាក្សត្រ ទុករដ្ឋសភា ជាសត្រូវនយោបាយ របស់ព្រះអង្គ។ ឆ្លៀតឱកាស នៅពេល លោក ស៊ឺង ង៉ុកថាញ់ រត់ភាសខ្លួន ចូលព្រៃ ដោយហេតុថា លោកទទួលនូវការគំរាមកំហែង ពីសំណាក់ អាជ្ញាធរបារាំង ដែលគេទុក លោក ជាអ្នកប្រឆាំងមតិនយោបាយ។ នៅពេលនោះឯង ព្រះ

[66] Stipuler។

មហាក្សត្រ សម្រេចចិត្ត ផ្តួល រាជរដ្ឋាភិបាល ដឹកនាំដោយ លោក ហុយ កន្ទល់ ពីហេតុថា មិនខ្មះខ្មែង ឃ្លាំងមើល លោក ស៊ឹង ង៉ុកថាញ់ បណ្តោយឲ គាត់រត់ចូលព្រៃដើម្បីបង្កើត ចលនាតស៊ូប្រឆាំងនឹងព្រះអង្គ។ ការផ្តួល រដ្ឋាភិបាលនេះ ជា កិច្ច (acte) ផ្ទុយនឹងរដ្ឋ ធម្មនុញ្ញ សុទ្ធសាត។ ក្នុងមាត្រទី២១ ដែលព្រះមហាក្សត្រ យកមកបកស្រាយ ថាព្រះអង្គ មានសិទ្ធិ អាចផ្តួល រដ្ឋាភិបាលបាន ជាការបកស្រាយមួយ ផ្ទុយនឹងច្បាប់។ តាមច្បាប់ រដ្ឋធម្មនុញ្ញ មានតែរដ្ឋសភា តែមួយគត់ អាចមានអំណាច ផ្តួលរដ្ឋាភិបាលបានដែល មានចែងនៅក្នុង មាត្រាទី៨៤ និង ៨៥៖ រដ្ឋសភា បោះឆ្នោតដកសេចក្តីទុកចិត្តពី រដ្ឋា ភិបាល តាម ញត្តិ នៃការទិតៀន ដល់រដ្ឋាភិបាល។ ការផ្តួលរដ្ឋាភិបាល ដោយព្រះមហា ក្សត្រនេះ ជា ការរំលោភជាក់ស្តែង លើរដ្ឋធម្មនុញ្ញ ដែល លោក ភឿង តុន ផ្តល់គុណ សម្បត្តិលក្ខណ: ដល់កិច្ចនេះថា ជារដ្ឋប្រហារ រដ្ឋធម្មនុញ្ញ ត្រង់ៗតែម្តង។

សួរថា តើត្រូវមាន **លក្ខណ: គ្រប់គ្រាន់ជាមុនសិន** (conditions prérequise) សំរាប់ ប្រជាជន ទើប អាចអនុវត្តិ លទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសមួយ បាននោះឬ ?

ព្រោះថា លោក Philippe PRESCHEZ, ជនជាតិបារាំង, បានសរសេរនៅក្នុងការសាក ល្បងពិចារណា របស់លោកមួយ ថា[67] រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ១៩៤៩ ដែលបានចម្លងផ្ទាល់ពី រដ្ឋធម្មនុញ្ញបារាំង ឆ្នាំ១៩៤៦ យកមកអនុវត្តន៍ នៅក្នុងប្រទេសកម្ពុជា ដែលមិនដែល ស្គាល់សោះ នូវជីវិតនយោបាយប្រជាធិបតេយ្យ ដោយគ្រាន់តែមានគោលដៅតែមួយ គត់ គឺប្រគល់អំណាចឲទៅគណបក្សនយោបាយឈ្នះឆ្នោតប៉ុណ្ណោះ។ កិច្ចនេះ ប្រាកដជា ចោទជាបញ្ហាសំខាន់មួយ គឺការមិនស្គាល់ នូវឥទ្ធិពល នៃរាជានិយមខ្មែរ ដែលមាន កិត្យានុភាពខ្លាំងក្លាលើសរាជានិយមដទៃទៀត មាននៅក្នុងលោក។ កិច្ចនេះ បង្ហាញឲ ឃើញថាខ្មែរ មិនស្គាល់ប្រវត្តិសាស្ត្រជាតិឯង។ ត្រូវដឹងថា ការលូតលាស់ នៃលទ្ធិប្រជាធិប តេយ្យ នៅប្រទេសបារាំង មានកើតឡើងពីការតស៊ូបង្ហូរឈាម បង្ហូរញើសនិងធនធាន នៃប្រជាជន។ នៅក្នុងឆ្នាំ ១៧៨៧ ប្រជាជនបារាំង ក៍មិនដែលស្គាល់នោះដែរ នូវជីវិត នយោបាយប្រជាធិបតេយ្យ ប៉ុន្តែ ប្រជាពលរដ្ឋ គ្មានរេរាធ្វើបដិវត្តន៍ ហើយបដិវត្តន៍នេះ មានចំហាយសាយពាសពេញសាកលលោក៖ ព្រោះជាការកើតគំនិតថ្មីមួយ នៃមនុស្ស

---

[67] Philippe Preschez : Essai sur la démocratie du Cambodge, publié dans la revue « Fondation Nationale des Sciences Politiques », n° 4, octobre 1961.

ជាតិ គឺគំនិតប្រជាធិបតេយ្យ ហើយបន្ទាប់ក្រោយបន្តិចមក មានកើតរដ្ឋាភិបាល ប្រជាធិបតេយ្យ។

លោក Philippe PRESCHEZ មានយោបល់ថា ខ្មែរមិនស្គាល់ប្រវត្តិសាស្ត្រខ្លួន បានជាមិនស្គាល់កិត្យានុភាព រាជានិយមខ្មែរ។ គំនិតនេះ ជាការទាញយោបល់ លឿនរហ័សពេក។ ដោយសារខ្មែរស្គាល់ រាជានិយមខ្មែរ ច្បាស់លាស់ពេក បានជា ប្រជាពលរដ្ឋខ្មែរបោះឆ្នោតឲគណបក្សប្រជាធិបតេយ្យ ដែលជាគណបក្ស នាំមកនូវគំនិតថ្មី គឺ លទ្ធិប្រជាធិបតេយ្យ ដើម្បីឲបង្កើត រដ្ឋាភិបាលប្រជាធិបតេយ្យ ដែលមានប្រជាពលរដ្ឋជាម្ចាស់នៃអំណាច។ ព្រឹត្តិការណ៍នេះ អាចមានកើតឡើងបាន ព្រោះថា មានអ្នកស្នេហាជាតិបានរៀបចំតាំងពីឆ្នាំ១៩៣៦(ឆ្នាំបង្កើតសាព័ត៍មាន នគរវត្ត) ដើម្បី ធ្វើឲប្រជាពលរដ្ឋ មានការចាប់អារម្មណ៍ទៅលើគំនិត ឯករាជ្យជាតិ ដោយប្រើអំណាច និង កម្លាំងខ្លួន ជាពលរដ្ឋ ដណ្តើមយក សេរីភាព និង ទាមទារ ឯករាជ្យជាតិ ពីអាណានិគមបារាំង។ លទ្ធផលជាវិជ្ជមាននៃយុទ្ធការ នៃវេទយិត (campagne de sensibilité) នេះឯង ដែលអាចឲ ប្រជាជនខ្មែរមាន បក្កភាព (maturité) ដើម្បីជ្រើសរើស នៅពេលបោះឆ្នោតថ្នាក់ជាតិ គណបក្សប្រជាធិបេតយ្យ ដែលជាគណបក្ស នាំមក នូវ គំនិតថ្មី[68] ដូចជាផ្កាម្លិះ **សម្ផូល្ល**(ផ្ការីក) សាយនូវ **សារគន្ធ** (ក្លិនក្រអូប) ពាសពេញនគរខ្មែរ។ ស្រុកខ្មែរជំនាន់នោះ មិនចាំបាច់ធ្វើបដិវត្តន៍បង្ហូរឈាម ដូចលោក Philippe PRESCHEZ ទុកវាជា លក្ខណៈគ្រប់គ្រាន់ជាមុនសិន ដើម្បីដាំ លទ្ធិប្រជាធិបតេយ្យ នៅស្រុកខ្មែរ។ ដូច្នេះ បរាជ័យនៃដំណើរ នៃលទ្ធិប្រជាធិបតេយ្យនៅស្រុកខ្មែរ តាំងពីឆ្នាំ ១៩៥២ មក មិនមែនជាកំហុសរបស់ប្រជាពលរដ្ឋ ដែល មិនស្គាល់ប្រវត្តិសាស្ត្រ នៃប្រជាជាតិខ្លួននោះឡើយ ផ្ទុយទៅវិញ វាកើតចេញពីកិត្យានុភាព សិប្បនិម្មិត នៃរាជានិយម នោះវិញទេ។ រាជានិយម ចាប់ពីសតវត្ស ទី១៩មក លែងមានតួនាទី ជារបបដឹកនាំ ប្រកបដោយ ទសពិធរាជធម៌ ដែលនាំឲខ្លួនបាត់បង់នូវកិត្យានុភាព ចំពោះ ប្រជាពលរដ្ឋ។

តាមយោបល់ ជាការរិះគន់ របស់ លោក ភឿង គុន **សម្ប៍្បណាជ្ញាសិទ្ធរាជ្យ** (រាជានិយមផ្តាច់ការ) អាចធ្វើអ្វីបានទាំងអស់ ទៅតាមចំណង់ចិត្តដែលខ្លួនចង់បាន។ នៅចំពោះមុខ

---

68 ត្រូវដឹកថា ការបោះឆ្នោត នៅថ្ងៃទី១ កញ្ញា ឆ្នាំ ១៩៤៦ ជាការបោះឆ្នោត បង្ហាញនូវបក្កតា នៃប្រជាជនខ្មែរ ព្រោះថា ចំនួន ៦០% បានចូលរួមបោះឆ្នោត បើប្រៀបធៀបទៅនឹងការបោះឆ្នោតនៅស្រុកសៀមក្នុងជំនាន់នោះ មានចំនួនប្រជាជន តែ ១០% ទៅ ១៥% ដែលចូលរួមបោះឆ្នោត។ គណបក្សប្រជាធិបតេយ្យ ជាអ្នកឈ្នះឆ្នោត បានទទួលអាសនៈនៅក្នុងរដ្ឋសភាធម្មនុញ្ញ ចំនួន ៥០ ក្នុងចំនួន អាសនៈ ទាំងអស់ ៦៥។ គណបក្សឯទៀតៗ ទទួលបានអាសនៈ ១៦។

ជនប្រើអំណាចផ្តាច់ការ ដែលមានឥទ្ធិពលសម្បើម គ្មានកម្រិត មានប្រជារាស្ត្រស្លូតខ្លាច ខ្វះការចេះដឹង ទទួលនូវការអប់រំខ្លាំង ក្នុងធម៌សាសនា គោរពប្រតិបត្តិគ្មានការពិចារណា។ ប្រជារាស្ត្របែបនេះ ស្គាល់តែករណីកិច្ច មានសិទ្ធិតិចតួចបំផុត តើឲ្យគាត់អាចចេះដឹងអ្វី អំពី សេរីភាពនយោបាយ (សេរីភាព បុគ្គល, វិស័យមតិ និង បញ្ចេញមតិ,សារព័ត៌មាន, ជំនឿ, សមាគម ។ល។) ម្យ៉ាងទៀត ប្រជារាស្ត្រ ភាគច្រើន គាត់មិនទាំងចេះអក្សរ តើសេរីភាពនេះ វាមានប្រយោជន៍អ្វីសំរាប់គាត់ ក្រៅតែពីធម៌សាសនាដែលគាត់ប្រតិបត្តិជាទម្លាប់ផង កាតព្វកិច្ចផង ព្រោះអ្នកដឹកនាំ គេលើកដំកើងសាសនា ជាជំនឿ របស់រដ្ឋ។ទាសភាព និង ការលក់ដូរ កុមារ ជាការប្រព្រឹត្តជាធម្មតា ក្លាយជា ស្ថាប័នជាតិ ដែលនាំឲ្យគ្រួសារទាំងមូល ក្លាយជាអ្នកងារ (domesticité) ដាច់ថ្លៃ ហើយ កម្រនឹង រំដោះខ្លួនចេញបាននោះឡើយ។ ស្ត្រី និង កុមារ គ្មានច្បាប់ពិសេសសំរាប់ការពារ រស់នៅក្រោម អំណាចរបស់ ស្វាមី បិតា ជាមេគ្រួសារ ដែលខ្លួន ត្រូវពឹងផ្អែងទាំងស្រុង។

ប្រជារាស្ត្រ គ្មានភ័ព្វកុសល លើផ្នែននយោបាយ ហើយ ក៏មិនដែលបានស្គាល់សោះដែរ នូវសំណាងល្អក្នុងវិស័យសម្ភារៈ។ គាត់ រស់ក្នុងនៅក្នុងប្រទេសមួយ មានទ្រព្យ ដីមានជីជាតិ តែគាត់ មិនបានទាញយកគុណប្រយោជន៍អ្វីបន្តិបន្តួចនោះឡើយ។ ម្យ៉ាងទៀត ភាពសម្បូណ៌នេះក៏គ្មានមានការបែងចែក ឲមាន សមធម៌ ដល់ប្រជារាស្ត្រ នោះដែរ។ នៅពេលណាមានការស្ងួតហែងម្តងៗ ដោយគ្មានភ្លៀង នៅដំបន់ណាមួយ ប្រជាកសិករតែងតែជួបប្រទះនូវទុរ្ភិក្ស បណ្តាលឲគ្រួសារបែកបាក់គ្នា, ចាកចេញពីស្រុកកំណើតស្វែងរករស់, ក្លាយជាអ្នកសុំទានដើម្បីចិញ្ចឹមជីវិត។ តែគ្រោះទុរភិក្សជាធម្មជាតិនេះ មិនសុទ្ធជាដើមហេតុ នៃទុក្ខរបស់ប្រជារាស្ត្រ តែមួយនោះឡើយ គឺជួនកាល មានបន្ថែមនូវ ជម្ងឺឆ្លង និង ជម្ងឺគ្រប់បែបយ៉ាងដែលច្រើនមានកើតឡើងនៅក្នុងដំបន់ក្តៅ ដែលអាចរាតត្បាតពាសពេញដំបន់នាំឲមានស្លាប់មនុស្សសន្ធឹក ព្រោះខ្វះ ការព្យាបាល តាមវិទ្យាពេទ្យ។ តែទុក្ខខ្មែរ ក៏មានដើមហេតុ ពីការលុកលុយ ជាញឹកញាប់ នៃ **សាមន្ត**ប្រទេស (ប្រទេសជិតខាង) មានសៀម និង យួន ក្នុងកំឡុងសតវត្សទី១៥ ហើយ យើងអាចរាប់បន្ថែម ដើម្បីបំពេញតារាង នៃទុក្ខខ្មែរ គឺ មាន ការងារដ៏លំបាកលំបិនគ្មានកម្រៃ (corvée) ដែលប្ររាស្ត្រខ្មែរ មានកាតព្វកិច្ច ត្រូវធ្វើ ហើយ ត្រូវបង់ពន្ធដារ ចំពោះរដ្ឋ។ ម្យ៉ាងទៀត ប្រជាកសិករ ធ្វើស្រែចិញ្ចឹមជីវិត លើដី ដែលខ្លួនមិនមែនជាម្ចាស់ដី ព្រោះដីទាំងអស់ ក្នុងរាជាណាចក្រ ជាទ្រព្យ របស់ព្រះមហាក្សត្រ។

អ្នកខ្លះយល់ឃើញថា សង្គមខ្មែរ មាន ស្តេច នាម៉ឺន វណ្ណៈអភិជន ភិក្ខុរាវ អ្នកជាអ្នកងារ ជារូបសំណាកស្រដៀងគ្នានឹង សង្គមបារាំង ក្នុងសម័យសក្តិភូមិ ដូច្នេះ ត្រូវតែមានកើត បដិវត្តន៍ រំលំសង្គមចាស់ ដើម្បី សាង របបនយោបាយថ្មី សំរាប់ឲ ប្រជារាស្ត្រខ្មែរ មាន សោមនស្សនឹង វាសនាខ្លួន។ តែការយល់បែបណា គ្មានការពិត ព្រោះគេ

សង្កេតឃើញថា ប្រជារាស្ត្រខ្មែរគាត់បែរជា នាំគ្នារស់ អត់ធ្មត់ សុខចិត្តទ្រាំទ្រ រស់ក្នុងទុក្ខរបស់ខ្លួនទៅវិញ។ បាតុប័ត្រនេះមានដើមហេតុវាជាច្រើន ដូចយ៉ាងះ

១. ប្រជារាស្ត្រខ្មែរ ទទួលឥទ្ធិពលខ្លាំងក្លា ពីពុទ្ធសាសនា ដែលអប់រំ ឲស្រឡាញ់ សន្តិភាព កុំឲផ្អែកអារម្មណ៍ច្រើនទៅលើ ជិវិតសម្ភារៈ មាននៅក្នុងលោកនេះ ត្រូវទទួលយកទុក្ខជាកម្មផល នៃអំពើ ពីអតិតជាតិ ហើយខំកសាងកុសលជានិច្ច ដើម្បីទទួលរង្វាន់ល្អក្នុងកំណើតថ្មី នៅឋានសួគ៍។ ប្រជារាស្ត្រខ្មែរ មានជំនឿណាស់ លើទស្សនៈ កម្មផល ដូច្នេះគាត់ទទួលអត់ទ្រាំរស់ ក្នុងការឈឺចាប់ក្នុងចិត្ត និង កាយ គ្មានការក្តៅក្រហាយទៅលើអ្នកប្រព្រឹត្តិអំពើអយុត្តិធម៌មកលើខ្លួន ហើយ ចេះតែនឹកសង្ឃឹមជានិច្ចថា ជាតិក្រោយខ្លួននឹងមាន ជិវិតប្រសើរជាពុំខាន។

២. មានការទុកចិត្ត ទៅលើ រាជានិយមះ ទុកព្រះមហាក្សត្រជា អ្នកថែរក្សា នៃសមធម៌ និង យុត្តិធម៌ ជាអ្នកការពារ ឯករាជ្យជាតិ ដូច្នេះ គ្រប់កិច្ចប្រឆាំងនឹងរបបដឹកនាំគឺជាការបះពាល់ ដល់កិត្យានុភាព នៃព្រះមហាក្សត្រ ដែលខ្លួន មិនដែលមានការសង្ស័យអ្វីនោះឡើយ ទៅលើគុណសម្បត្តិលក្ខណៈ នៃសីលធម៌ របស់ព្រះអង្គ។

៣. អារម្មណ៍ អំពីគ្រោះថ្នាក់ ដែលបរទេសជាអ្នកបង្កើតះ  នៅចំពោះមុខគ្រោះថ្នាក់នេះ ប្រជាជនខ្មែរ សុខចិត្ត ទ្រាំរស់ ក្រោមទម្ងន់ នៃការឈ្លានពាន ពីសំណាក់ប្រទេសជិតខាងព្រោះយល់ឃើញថា បើនាំគ្នាបះបោរប្រឆាំងនឹង អាជ្ញាធរខ្មែរ ដែលខ្លួនមើលឃើញថា ខ្វះសមត្ថភាពការពារជាតិ គឺរិតតែបណ្តាលឲបរទេសឆ្លៀតចំណេញថែមទៀត លើជម្លោះ រវាងខ្មែរគ្នាឯង។

៤. ប្រជាពលរដ្ឋខ្មែរ រស់ក្នុងអនុស្សាវរិយ៍ នូវសម័យកិត្តិគុណ នៃមហានគរ ហើយតែងតែមមាយ (សុបិនជានិច្ច) ថា សម័យនេះ នឹងអាចមានកើតដោយខ្លួនឯងឡើងវិញ ក៍នាំគ្នារស់ ហ៍តហោង(silence inquiétante)ក្នុងមហាទុក្ខ នៃជីវិតបច្ចុប្បន្ន របស់ខ្លួន រង់ចាំសម័យមហានគរ។

៥. កង្វះមធ្យោបាយ គ្រប់បែបយ៉ាង ដើម្បីបះបោរប្រឆាំងនឹង សម្ប៉ូណាជ្ញាសិទ្ធរាជ្យ (monarchie absolue) ដែលមានកងទ័ព មានអានុភាព អាចកំទេចបានងាយស្រួលនូវគ្រប់ចលនា ដែលចង់សាកល្បងប្រឆាំងនឹងខ្លួន។

លោក ភឿង តុន ធ្វើសេចក្តីសន្និដ្ឋានថា ស្ថានភាព ដែលមាននៅស្រុកខ្មែរ ក៍មានដែរ នៅគ្រប់ប្រទេសប៉ែកបូ៌ា ដែលមានរបបដឹកនាំជាតិ ជារបប ដែលមាន ពួកអ្នករាជការ ជាអ្នក  ស៊ីសំណូក ពុករលួយ ផ្តាច់ការ ប្រព្រឹត្តអំពោះប្រជាហិង្សា។ របបបែបនេះ នាំ

បង្កើត ឲមានវណ្ណៈ នៃពួកនាម៉ឺន មានឯកសិទ្ធិ ប្រើអំណាច នៃមុខងារ រាល់ខ្លួន ដើម្បីទាញយកប្រយោជន៍ពីធនធានរបស់ប្រជាពលរដ្ឋ ដោយសារអំណាចមជ្ឈឹមខ្វះសម្ថភាពគ្រប់គ្រងពួកខ្លួន ហើយដឹងថា អំណាចកំពូលក៍ប្រព្រឹត្តអំពើពុករលួយនោះដែរ គឺថា « ធំស៊ីតាមធំ តូចស៊ីតាមតូច»។

ការវែលញែក របស់ លោក ភឿង តុន ស្តីពី ដើមហេតុ នៃភ័ព្វអាក្រក់ របស់ប្រជាពលរដ្ឋខ្មែរខាងលើនេះ ជាទស្សនៈពួកខ្មែរ អ្នកជឿនលឿននិយម នៅក្នុងទស្សវត្សរ៍ ៥០។  ពួកខ្មែរកុម្មុយនិស្តនិយម ចែករំលែក នូវគំនិតនេះ ព្រោះជាទស្សនៈឈរលើ ការជិះជាន់វណ្ណៈ និង អកម្មភាព នៃប្រជាជនខ្មែរ នៅចំពោះមុខ ភ័ពអាក្រក់របស់ខ្លួន។ ប៉ុន្តែ ពួកអ្នកប្រជាធិបតេយ្យនិយម មិនចែករំលែក ទាំងអស់ នូវទស្សនៈ ខាងលើនេះទេ ព្រោះមានការពិសោធ ជាវិជ្ជមាន នៃការអនុវត្តន៍ លទ្ធិប្រជាធិបតេយ្យ នៅស្រុកខ្មែរ ដែលមាននៅក្នុងពេលបោះឆ្នោត ក្នុងឆ្នាំ ១៩៤៦ បង្ហាញ នូវបក្កភាព នៃប្រជាពលរដ្ឋ ក្នុងជម្រើស ប្រកបដោយសុភនិច្ឆ័យ  គឺថា រើសសម្រាំងយក អ្នកប្រជាធិបតេយ្យនិយម ជាដឹកនាំជាតិ។ ប៉ុន្តែខ្មែរ គ្រប់និន្នាការនយោបាយ មានគំនិតរួមមួយ គឺទុក រាជានិយមផ្តាច់ការ ជាឧបសគ្គ នាំទំនញ់ គ្រប់កំណែទម្រង់ នៃ នយោបាយ និង សង្គមខ្មែរ។ តែក្រុមនិមួយៗ មានវិធីសាស្ត្រ ខុសគ្នា ដើម្បីរំលាយឧបសគ្គនេះ តួយ៉ាង ពួកអ្នកកុម្មុនិស្តនិយម ជ្រើសរើស **បដិវត្តន៍** ជាចម្លើយ ដែលវាខុសពី អ្នកប្រជាធិបតេយ្យនិយម ដែលយក **កំណែទំរង់** ជាមធ្យោបាយ ដែល លោក ភឿង ទុក ឲឈ្មោះថា បដិវត្តន៍ នៃលទ្ធិប្រជាធិបតេយ្យ (révolution de démocratie)។ ចំពោះយើង យើងឲឈ្មោះ វិធីសាស្ត្រកំណែទំរង់នេះថាជាបដិវត្តន៍អហិង្សា។ ដូចបានជំរាបខាងលើរួចមកហើយថា រដ្ឋប្រហារដែលព្រះមហាក្សត្រធ្វើនៅ ខែ មិថុនា ឆ្នាំ ១៩៥២ បានរំលាយ នូវជំនឿប្រាកដក្នុងចិត្តរបស់អ្នកប្រជាធិបតេយ្យនិយម ថា អាចដូរ របបដឹកនាំជាតិ បាន តាមមធ្យោបាយកំណែទំរង់ ហើយនាំឲពួកអ្នកកុម្មុយនិស្តនិយម មានជំនឿ កាន់តែ **មាំ** (solide) ឡើងនូវភាពចាំបាច់ នៃការធ្វើបដិវត្តន៍ តាមការប្រយុទ្ធវណ្ណៈ ដើម្បីរលំ រាជានិយម សាសនា និង វណ្ណៈនាម៉ឺន ដែលពួកគេទុកជាពួកបញ្ចើក្អែក បំផ្លាញជាតិ។

មួយវិញទៀត ពួកអ្នកឆ្វេង និង កុម្មុយនិស្តនិយម គ្មានជំនឿ លើការបោះឆ្នោតសាកលនៅក្នុងប្រទេស មានសង្គមហួសសម័យ ដែលនាំឲ របបតំណាង (régime représentatif) រៀចខូច នាំឲ ពួកវរជន និង អភិជន ឆ្លៀតរកចំណេញ លើប្រជារាស្ត្រ ជាអ្នកបោះឆ្នោតដែលមិនទាន់មាន បក្កភាពនយោបាយ គ្រប់គ្រាន់ ដូចមាននយោបាយវិទូខ្លះ យល់ឃើញថា៖ ការបោះឆ្នោតជាសាកល មិនដែលជា ឧបករណ៍ នៃការជឿនលឿន ដែលពួកអ្នកអទិករ (អ្នកផ្តើមផ្ទី) តែងតែស្រមៃចង់បាន ព្រោះដោយសារថា នៅពេលណាប្រជារាស្ត្រ ខ្វះការអប់រំ និង ពន្លឺបញ្ញា។ ការបោះឆ្នោតក្នុង

លក្ខខណ្ឌបែបនេះ មិនមែនជាអំពើវិជ្ជមាន ដល់ការធ្វើអភិវឌ្ឍន៍ជាតិ ពិតប្រាកដ នោះឡើយ។

តែយើងអាចសួរជាសំណួរមួយថា តើប្រជាពលរដ្ឋខ្មែរ តាំងពីឆ្នាំ ១៩៤៦ ចង់បានអ្វីពិតប្រាកដ ? ៖ សេរីភាព ? សុភមង្គល ? សុខុមាលភាព ? ទំនាន់ចិត្ត ទាំងឡាយនេះ តើត្រូវប្រជារាស្ត្រ រៀនសូត្រ លទ្ធិប្រជាធិបតេយ្យ ដូចជា វិទ្យាស្សង្ស ? តើត្រូវចេះអានសៀវភៅ ដើម្បី ជ្រើសរើស តំណាងខ្លួន ដើម្បី ដឹកនាំជាតិ ?



# នៅមានបន្ត